**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ
# ឆ្នាំ២០១៩ - ២០២៥

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ**
**នាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩**

**រាជរដ្ឋាភិបាលកម្ពុជា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# បុព្វកថា

ការសម្រេចបានសន្តិភាពពេញលេញរបស់ព្រះរាជាណាចក្រកម្ពុជាបានផ្ដល់ឱកាសឲ្យរាជរដ្ឋាភិបាលផ្ដោតការយកចិត្តទុកដាក់លើការអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងសង្គម ហើយសម្រេចបានសមិទ្ធផលគួរជាទីមោទនៈជូនជាតិមាតុភូមិ។ ក្នុងចំណោមសមិទ្ធផលទាំងនោះ កម្ពុជាទទួលបានជោគជ័យលើការជំរុញកំណើនសេដ្ឋកិច្ច កំណើនមូលធនសង្គម និងកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័ស។ ជាក់ស្ដែង ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ សេដ្ឋកិច្ចកម្ពុជាទទួលបានកំណើនខ្ពស់ ចំណាត់ថ្នាក់ទី៦នៅលើពិភពលោក ហើយអត្រាភាពក្រីក្របានថយចុះជាមធ្យមប្រមាណជាង១%ក្នុងមួយឆ្នាំ ដែលធ្វើឲ្យកម្ពុជាជាប់ចំណាត់ថ្នាក់ទី៤ នៅលើពិភពលោកលើការទទួលបានជោគជ័យក្នុងការកាត់បន្ថយភាពក្រីក្រ ដែលជាគោលដៅចម្បងមួយក្នុងចំណោមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់អង្គការសហប្រជាជាតិ។

បរិយាបន្នហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ថាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ការផ្ដល់លទ្ធភាពដល់ប្រជាជនឬសហគ្រាសធុនតូចនិងមធ្យមដែលមិនទាន់ទទួលបានសេវាហិរញ្ញវត្ថុក្នុងតម្លៃសមរម្យ បានបង្កើតនិងពង្រីកសក្ដានុពលសកម្មភាពសេដ្ឋកិច្ចនៅគ្រប់វិស័យ ហើយមានឥទ្ធិពលដោយផ្ទាល់និងដោយប្រយោល ដល់ការកាត់បន្ថយភាពក្រីក្រក្នុងសង្គម។ រហូតមកដល់បច្ចុប្បន្នកម្ពុជាបានខិតខំប្រឹងប្រែងលើការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ តាមរយៈការអភិវឌ្ឍនិងបញ្ញត្តិកម្មនៃវិស័យហិរញ្ញវត្ថុនៅទូទាំងប្រទេស ស្របតាមតម្រូវការទីផ្សារ ការលើកកម្ពស់ការអប់រំផ្នែកហិរញ្ញវត្ថុលើគ្រប់រូបភាព ការបន្ថយកម្រៃលើការប្រើប្រាស់សេវាហិរញ្ញវត្ថុឲ្យស្ថិតក្នុងកម្រិតសមស្របនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុអំណោយផលសម្រាប់ធ្វើឲ្យលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុកាន់តែមានភាពងាយស្រួលនិងមានប្រសិទ្ធភាព។

ទោះយ៉ាងណា បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជាមានកម្រិតនៅឡើយនិងទាមទារឲ្យក្រសួង ស្ថាប័នវិស័យឯកជន ដៃគូអភិវឌ្ឍ និងគ្រប់ភាគីពាក់ព័ន្ធនានា ចូលរួមបន្តទៀតជាសារវន្ត ជាពិសេស ក្នុងស្ថានភាពដែលការអភិវឌ្ឍវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកាន់តែមានសមាហរណកម្មស៊ីជម្រៅទៅក្នុងតំបន់ ក្រោមការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាក្នុងសម័យឌីជីថល។ ក្នុងហេតុផលនេះ ការបង្កើតឲ្យមានយុទ្ធសាស្ត្រជាតិស្ដីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ មានលក្ខណៈសមស្របនឹងសភាពការណ៍បច្ចុប្បន្ននិងអនាគតហើយនិងអនុញ្ញាតឲ្យភាគីពាក់ព័ន្ធទាំងអស់ចូលរួមសហការអនុវត្តផែនការសកម្មភាពដែលមានក្នុងយុទ្ធសាស្ត្រប្រកបដោយសង្គតិភាពនិងប្រសិទ្ធភាពខ្ពស់។ យុទ្ធសាស្ត្រជាតិស្ដីពីបរិយាបន្នហិរញ្ញវត្ថុនេះ ក៏ត្រូវបានរៀបចំឡើងដោយផ្អែកលើស្មារតីនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ និងស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល។ ខ្ញុំជឿជាក់ថាយុទ្ធសាស្ត្រជាតិនេះនឹងបន្ត

ចូលរួមកាត់បន្ថយភាពក្រីក្រនិងវិសមភាពនៅកម្ពុជា ជាពិសេស ចំពោះស្ត្រីនិងសហគ្រាសធុនតូចនិងមធ្យម ព្រមទាំងគាំទ្រយ៉ាងសកម្មដល់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រកបដោយចីរភាពនិងបរិយាបន្ន។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅនិងកោតសរសើរចំពោះ ក្រសួង ស្ថាប័ន វិស័យឯកជន ដៃគូអភិវឌ្ឍ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេស ធនាគារជាតិនៃកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបានរួមចំណែកក្នុងការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥នេះឡើង សម្រាប់ជាមគ្គុទ្ទេសក៍និងក្របខ័ណ្ឌសម្របសម្រួលមួយដ៏សំខាន់ក្នុងការអនុវត្ត គោលនយោបាយ វិធានការ និងសកម្មភាពនានាដែលមានគោលដៅរួមតែមួយក្នុងការលើកកម្ពស់ បរិយាបន្នហិរញ្ញវត្ថុនៅទូទាំងប្រទេស។

ខ្ញុំជឿជាក់យ៉ាងមុតមាំថា ក្រសួង ស្ថាប័ន វិស័យឯកជន ដៃគូអភិវឌ្ឍ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ នឹងបន្តខិតខំប្រឹងប្រែងចូលរួមចំណែកនិងសហការធ្វើឲ្យការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥នេះទទួលបានជោគជ័យនិងប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ចន្ទ ៤ រោច ខែ ស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៩

**ហ៊ុន សែន**

# មាតិកា


**អារម្ភកថា** ..... i

**អក្សរកាត់** ..... iii

**ខ្លឹមសារសង្ខេប** ..... vi

**ជំពូក១ : សេចក្តីផ្តើម** ..... ១

**ជំពូក២ : បរិបទវិស័យហិរញ្ញវត្ថុនៅកម្ពុជា** ..... ៣

I. បរិបទប្រទេសកម្ពុជា ..... ៣

II. ស្ថានភាពបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា ..... ៨

III. ឧបសគ្គចំពោះបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា ..... ១៥

IV. កត្តាជំរុញទីផ្សារ ..... ១៧

**ជំពូក៣ : ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា** ..... ២២

I. ទីផ្សារគោលដៅ ..... ២២

II. ការកំណត់គោលដៅសម្រាប់បរិយាបន្នហិរញ្ញវត្ថុ ..... ២៤

**ជំពូក៤ : សកម្មភាពអាទិភាព** ..... ២៦

I. វិស័យធនាគារ ..... ២៦

II. វិស័យមិនមែនធនាគារ ..... ៣០

III. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ..... ៣៣

IV. ការកសាងសមត្ថភាព ..... ៤២

**ជំពូក៥ : ការអនុវត្តយុទ្ធសាស្ត្របរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥** ..... ៤៤

I. អត្ថប្រយោជន៍ដែលរំពឹងទុក ..... ៤៤

II. ផែនការសកម្មភាពក្នុងបរិបទគោលនយោបាយហិរញ្ញវត្ថុបច្ចុប្បន្ន ..... ៤៥

III. ការអនុវត្តនិងការវាយតម្លៃ ..... ៤៦

IV. ការវាស់វែង ..... ៤៧

V. អ្នកសម្របសម្រួលការអនុវត្ត ..... ៤៧

**ជំពូក៦ : សេចក្តីសន្និដ្ឋាន** ..... ៤៨

**ជំពូក៧ : ផែនការសកម្មភាពយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥** ..... ៥០

**ឧបសម្ព័ន្ធ** ..... ៦៧

**សន្ទានុក្រម** ..... ៧២

**ឯកសារយោង** ..... ៧៧

# អារម្ភកថា

នៅក្នុងបរិបទសុខសន្តិភាពពេញលេញរបស់កម្ពុជា ការអភិវឌ្ឍនានាបាននិងកំពុងរីកដុះដាលលើគ្រប់វិស័យ ជាមួយសមិទ្ធផលដែលទទួលបាន តាមរយៈការរីកចម្រើននៃវិស័យសេដ្ឋកិច្ចនិងសង្គមកិច្ច។ ស្នាដៃទាំងនេះបានលេចចេញជារូបរាងឡើងក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដឹកនាំនាវាកម្ពុជាឆ្ពោះទៅរកសុខដុមរមនានិងវឌ្ឍនភាព ក្រោមដំបូលសុខសន្តិភាពនិងស្ថិរភាពនយោបាយ។ ក្នុងកំលុងពេលជាងពីរទសវត្សរ៍កន្លងមក កម្ពុជាទទួលបានចំណាត់ថ្នាក់ជាប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្ពស់និងលឿនបំផុតលំដាប់ទី៦នៅលើពិភពលោក ដោយសម្រេចបានកំណើនជាមធ្យមជាង៧%ក្នុងមួយឆ្នាំ ហើយអត្រានៃភាពក្រីក្រក៏បានធ្លាក់ចុះពីប្រមាណ៥៣%ក្នុងឆ្នាំ២០០៤ មកនៅត្រឹមប្រមាណ១០%ក្នុងឆ្នាំ២០១៨។ ក្នុងដំណើរខិតខំដើម្បីរក្សាបានកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា បានបន្តដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ គោលនយោបាយអភិវឌ្ឍន៍តាមវិស័យ និងវិធានការដាក់ស្តែងជាអាទិភាពនានា។ ក្នុងន័យនេះ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ បានបន្តធ្វើជាមគ្គុទ្ទេសក៍សម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា ដែលក្នុងនោះ ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុត្រូវបានកំណត់ជាគោលដៅអាទិភាពមួយ។

បរិយាបន្នហិរញ្ញវត្ថុ គឺជាលទ្ធភាពទទួលបាននិងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការទាន់ពេលវេលាសមស្របតាមតម្រូវការ មានតម្លៃសមរម្យ និងមានកិច្ចការពារតាមផ្លូវច្បាប់។ ទន្ទឹមនេះ ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនឹងផ្តល់ផលប្រយោជន៍ជាច្រើន ទាំងផ្នែកសង្គម-សេដ្ឋកិច្ច ដល់សហគ្រាសធុនតូចនិងមធ្យម និងប្រជាជនដែលពុំទាន់មានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ។ ចំពោះប្រជាជន ផលប្រយោជន៍ទាំងនេះ រួមមាន ការជួយសម្រួលដល់ជីវភាពរស់នៅ ការផ្តល់លទ្ធភាពឲ្យមានការសន្សំហិរញ្ញវត្ថុនិងការបង្កើនឱកាសធុរកិច្ច ដែលនាំឲ្យប្រជាជនកាន់តែមានលទ្ធភាពច្រើនជាងមុនក្នុងការទទួលបានសេវាចាំបាច់នានា ដូចជា ការលើកកម្ពស់ការអប់រំ សេវាសុខភាព អនាម័យ និងទឹកស្អាត ជាដើម។ ចំពោះសហគ្រាសធុនតូចនិងមធ្យម ផលប្រយោជន៍មានដូចជា ការបង្កើនលទ្ធភាពវិនិយោគ ការទទួលបានសេវាប្រឹក្សាជាដើម។ ដូច្នេះ ការរៀបចំឲ្យមានយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ គឺពិតជាចាំបាច់ក្នុងការសម្រេចបាននូវផលប្រយោជន៍ទាំងនេះ។

យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុត្រូវបានរៀបចំឡើងក្នុងក្របខ័ណ្ឌជាគោលនយោបាយជាតិដែលអនុញ្ញាតឲ្យមានការចូលរួមពេញលេញពីសំណាក់ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងឡាយ និងការដាក់ចេញនូវផែនការសកម្មភាពគ្រប់ជ្រុងជ្រោយនិងច្បាស់លាស់។ យុទ្ធសាស្ត្រជាតិនេះជាឧបករណ៍ទ្រទ្រង់ដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ ដែលមានគោលបំណងសម្រេចបាននូវប្រព័ន្ធហិរញ្ញវត្ថុមួយមានស្ថិរភាព ប្រសិទ្ធភាព និងពិពិធកម្មទីផ្សារហិរញ្ញវត្ថុ ប្រកបដោយបរិយាបន្ន ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការសេវាហិរញ្ញវត្ថុក្នុងប្រទេស គាំទ្រដល់ចីរភាពនៃកំណើនសេដ្ឋកិច្ច បង្កើនប្រាក់ចំណូលដល់ប្រជាជន និងកាត់បន្ថយភាពក្រីក្រ។

ឯកសារ "យុទ្ធសាស្ត្រជាតិស្តីពីបរិយាប័ន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥" ត្រូវបានរៀបចំឡើងដោយ គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងក្រុមការងាររៀបចំយុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ (អន្តរក្រសួង) ដែលមានសមាសភាពមកពី ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី និងគណៈកម្មការមូលបត្រកម្ពុជា។ ក្រុមការងារបរិយាប័ន្នហិរញ្ញវត្ថុ របស់ធនាគារជាតិនៃកម្ពុជា ដែលជាសេនាធិការរបស់ក្រុមការងាររៀបចំយុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ បានសហការជាមួយក្រុមការងារជំនួយបច្ចេកទេស របស់មូលនិធិអភិវឌ្ឍន៍មូលធនអង្គការសហប្រជាជាតិ (UNCDF) តាមរយៈរបាយការណ៍វិភាគស្ថានភាពបរិយាប័ន្នហិរញ្ញវត្ថុ ឆ្នាំ២០១៧ ដែលផ្តោតលើបរិយាប័ន្នហិរញ្ញវត្ថុ ជាពិសេស សម្រាប់ប្រជាជនមានប្រាក់ចំណូលទាប និងសហគ្រាសធុនតូចនិងមធ្យមដែលគ្រប់គ្រងដោយស្ត្រី។

បន្ទាប់ពីគោលនយោបាយត្រូវបានកំណត់ ហើយយុទ្ធសាស្ត្រជាតិស្តីពីបរិយាប័ន្នហិរញ្ញវត្ថុត្រូវបានអនុម័ត យុទ្ធសាស្ត្រនេះនឹងត្រូវបានប្រើប្រាស់ជាមគ្គុទេសក៍សម្រាប់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍នានា និងវិស័យឯកជនអនុវត្តរួមគ្នា តាមរយៈការផ្តោតការយកចិត្តទុកដាក់លើវិធានការចាំបាច់ទាំងឡាយសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។ ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្ម និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ជាស្ថាប័នដឹកនាំការអនុវត្ត នឹងជួយសម្របសម្រួលការអនុវត្តផែនការសកម្មភាព និងធានាឲ្យមានកិច្ចសហការរវាងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសម្រេចគោលដៅបរិយាប័ន្នហិរញ្ញវត្ថុ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងមូលនិធិអភិវឌ្ឍន៍មូលធនអង្គការសហប្រជាជាតិ (UNCDF) ដែលបានរួមសហការគ្នាយ៉ាងសកម្មក្នុងការរៀបចំនិងផ្តល់នូវធាតុចូលនានាសម្រាប់ការរៀបចំឯកសារ "យុទ្ធសាស្ត្រជាតិស្តីពីបរិយាប័ន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥" និងជឿជាក់ថា យុទ្ធសាស្ត្រនេះនឹងក្លាយជាមគ្គុទេសក៍សម្រាប់លើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា ឲ្យសម្រេចបានប្រកបដោយជោគជ័យ និងលទ្ធផលល្អប្រសើរ។

ថ្ងៃ[illegible] [illegible] ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**អគ្គទេសាភិបាល**
**ធនាគារជាតិនៃកម្ពុជា**

**ជា_ចាន់តូ**

# អក្សរកាត់

| | | |
|---|---|---|
| ABC | សមាគមធនាគារនៅកម្ពុជា | Association of Banks in Cambodia |
| ABIF | ក្របខ័ណ្ឌសមាហរណកម្មវិស័យធនាគារអាស៊ាន | ASEAN Banking Integration Framework |
| AFI | សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ | Alliance for Financial Inclusion |
| APN | បណ្តាញទូទាត់តំបន់អាស៊ី | Asian Payment Network |
| ASAPCP | ផែនការសកម្មភាពជាយុទ្ធសាស្ត្រអាស៊ានសម្រាប់កិច្ចការពារអតិថិជន | ASEAN Strategic Action Plan for Consumer Protection |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ | Association of Southeast Asian Nations |
| ATM | ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ | Automated Teller Machine |
| CAFIU | អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | Cambodia Financial Intelligence Unit |
| CBC | ការិយាល័យឥណទានកម្ពុជា | Credit Bureau of Cambodia |
| CDD | ការយកចិត្តទុកដាក់ស្គាល់អតិថិជន | Customer Due Diligence |
| CMA | សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា | Cambodia Microfinance Association |
| CSS | ខេមបូឌានស៊ែស្វ៊ីច | Cambodian Shared Switch |
| EFT | ការផ្ទេរមូលនិធិជាអេឡិចត្រូនិក | Electronic Fund Transfer |
| FATF | ក្រុមការងារហិរញ្ញវត្ថុ | Financial Action Task Force |
| FDI | វិនិយោគផ្ទាល់បរទេស | Foreign Direct Investment |
| FI | គ្រឹះស្ថានហិរញ្ញវត្ថុ | Financial Institution |
| FMT | ភ្នាក់ងារ ហ្វីនម៉ាក ត្រាស់ | FinMark Trust |
| FSP | អ្នកផ្តល់សេវាហិរញ្ញវត្ថុ | Financial Service Provider |
| FSDS | យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ | Financial Sector Development Strategy |
| G2P | រដ្ឋាភិបាលទៅបុគ្គល | Government to Person |
| GDP | ផលិតផលក្នុងស្រុកសរុប "ផ.ស.ស." | Gross Domestic Product |
| HDI | សន្ទស្សន៍អភិវឌ្ឍន៍ធនធានមនុស្ស | Human Development Index |
| IME | ក្រុមហ៊ុន International Money Express | International Money Express |
| IMWG-FISF | ក្រុមការងាររៀបចំយុទ្ធសាស្ត្របរិយាបន្នហិរញ្ញវត្ថុ (អន្តរក្រសួង) | Inter-Ministerial Working Group on Financial Inclusion Strategy Formulation |

| | | |
|---|---|---|
| KHR | ខ្មែររៀល (៛) | Khmer Riel |
| KYC | ការស្គាល់អតិថិជន | Know Your Customer |
| LPCO | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា | Liquidity Providing Collateralized Operation |
| LVPS | ប្រព័ន្ធទូទាត់តម្លៃធំ | Large Value Payment System |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | Ministry of Agriculture, Forestry and Fisheries |
| MAP | គម្រោង Making Access Possible | Making Access Possible |
| MDI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | Microfinance Deposit Taking Institution |
| MEF | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | Ministry of Economy and Finance |
| MFI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | Microfinance Institution |
| MIH | ក្រសួងឧស្សាហកម្មនិងសិប្បកម្ម | Ministry of Industry and Handicraft |
| M&E | ការតាមដាននិងវាយតម្លៃ | Monitoring and Evaluation |
| MO | ប្រតិបត្តិករទូរស័ព្ទចល័ត | Mobile Operators |
| MOC | ក្រសួងពាណិជ្ជកម្ម | Ministry of Commerce |
| MOEYS | ក្រសួងអប់រំ យុវជន និងកីឡា | Ministry of Education, Youth and Sport |
| MOI | ក្រសួងមហាផ្ទៃ | Ministry of Interior |
| MOJ | ក្រសួងយុត្តិធម៌ | Ministry of Justice |
| MOP | ក្រសួងផែនការ | Ministry of Planning |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | Ministry of Social Affairs, Veterans and Youth Rehabilitation |
| MOWA | ក្រសួងកិច្ចការនារី | Ministry of Women's Affairs |
| MPTC | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | Ministry of Posts and Telecommunications |
| NCD | មូលបត្រអាចជួញដូរបាន | Negotiable Certificate of Deposit |
| NCS | ប្រព័ន្ធផាត់ទាត់ជាតិ | National Clearing System |
| NBC | ធនាគារជាតិនៃកម្ពុជា | National Bank of Cambodia |
| NIS | វិទ្យាស្ថានជាតិស្ថិតិ | National Institute of Statistics |
| NPL | ឥណទានមិនដំណើរការ | Non-Performing Loan |
| OID | បំណុលលើសលប់ | Over Indebtedness |

| | | |
|---|---|---|
| OTC | រំលងបញ្ជរ | Over the Counter |
| P2G | បុគ្គលទៅរដ្ឋាភិបាល | Person to Government |
| POS | បណ្តាញទូទាត់ "POS" | Point of Sale |
| PPP | ភាពជាដៃគូរវាងវិស័យរដ្ឋនិងឯកជន | Public Private Partnership |
| PSI | គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | Payment Service Institution |
| PSPF | វេទិកាសម្រាប់គ្រឹះស្ថានផ្តល់សេវាទូទាត់ | Payment Service Provider Forum |
| RCI | គ្រឹះស្ថានឥណទានជនបទ | Rural Credit Institutions |
| RS | យុទ្ធសាស្ត្រចតុកោណ | Rectangular Strategy |
| RTGS | ប្រព័ន្ធទូទាត់ដុលភ្លាមៗ | Real Time Gross Settlement |
| SDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | Sustainable Development Goal |
| SECC | គណៈកម្មការមូលបត្រកម្ពុជា "គ.ម.ក" | Securities and Exchange Commission of Cambodia |
| SME | សហគ្រាសធុនតូចនិងមធ្យម | Small and Medium Enterprises |
| STR | ការចុះបញ្ជីប្រតិបត្តិការដែលមានកិច្ចធានា | Secured Transaction Registry |
| TPP | អ្នកដំណើរការតតីយភាគី | Third Party Processors |
| TRC | និយ័តករទូរគមនាគមន៍កម្ពុជា | Telecommunication Regulator of Cambodia |
| UNCDF | មូលនិធិអភិវឌ្ឍន៍មូលធនអង្គការសហប្រជាជាតិ | United Nations Capital Development Fund |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ | United Nations Development Programme |
| USD | ដុល្លារអាមេរិក | United States of America Dollar |
| USSD | ទិន្នន័យសម្រាប់ "Unstructured Supplementary Service" | Unstructured Supplementary Service Data |
| VAT | អាករលើតម្លៃបន្ថែម | Value Added Tax |
| VCF | ហិរញ្ញប្បទានខ្សែចង្វាក់តម្លៃ | Value Chain Financing |
| VSLA | សមាគមសន្សំនិងកម្ចីតាមភូមិ | Village Saving and Loan Associations |

# ខ្លឹមសារសង្ខេប

i. បរិយាបន្នហិរញ្ញវត្ថុបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច កាត់បន្ថយវិសមភាព និងកាត់បន្ថយអត្រាភាពក្រីក្ររបស់ប្រទេសទាំងមូល។ ការទទួលបានសេវាហិរញ្ញវត្ថុជាឧបករណ៍គោលនយោបាយដ៏សំខាន់សម្រាប់អ្នករៀបចំគោលនយោបាយ ទាំងថ្នាក់ជាតិ ទាំងថ្នាក់សកល។ នៅពេលដែលប្រជាជនមិនទទួលបានសេវាហិរញ្ញវត្ថុ នោះការកៀរគរប្រាក់បញ្ញើឬប្រាក់សន្សំត្រូវបានបាត់បង់សម្រាប់ការផ្តល់ឥណទាននិងការបង្គរដើមទុន ដែលនេះជាការខាតបង់ដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ ការលុបបំបាត់របាំងបរិយាបន្នហិរញ្ញវត្ថុមានឥទ្ធិពលយ៉ាងខ្លាំង និងដោយផ្ទាល់ដល់ផលិតភាពនិងកំណើនផលិតផលក្នុងស្រុកសរុប តាមរយៈការបែងចែកធនធានប្រសើរជាងមុននិងការធ្វើកិច្ចសន្យាហិរញ្ញវត្ថុកាន់តែមានប្រសិទ្ធភាព ហើយជាលទ្ធផលធ្វើឲ្យកើនឡើងនូវសកម្មភាពសហគ្រិននិងអាជីវកម្មថ្មីៗ។ ស្ថានភាពជាក់លាក់របស់ប្រទេសនីមួយៗមានឥទ្ធិពលយ៉ាងខ្លាំងលើប្រសិទ្ធភាពនៃការលុបបំបាត់របាំងបរិយាបន្នហិរញ្ញវត្ថុ ដូច្នេះ ការស្វែងយល់ឲ្យបានស៊ីជម្រៅពីស្ថានភាពរបស់ប្រទេសមួយពិតជាមានសារៈសំខាន់ក្នុងការទទួលបានលទ្ធផលជាអតិបរមាពីការរៀបចំគោលនយោបាយបរិយាបន្នហិរញ្ញវត្ថុ។ សេវាហិរញ្ញវត្ថុគឺជាមធ្យោបាយមួយក្នុងការឈានទៅសម្រេចបាននូវបរិយាបន្នហិរញ្ញវត្ថុ ហើយការអភិវឌ្ឍវិស័យហិរញ្ញវត្ថុត្រូវយកចិត្តទុកដាក់លើភាពងាយរងគ្រោះនិងទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានផ្សេងៗដែលអាចកើតឡើងជាយថាហេតុ។ ទីផ្សារហិរញ្ញវត្ថុដែលប្រកបដោយបរិយាបន្ននិងប្រសិទ្ធភាពផ្តល់នូវសក្តានុពលក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន កាត់បន្ថយចំណាយប្រតិបត្តិការ ជំរុញសកម្មភាពសេដ្ឋកិច្ច និងធ្វើឲ្យប្រសើរឡើងនូវការផ្តល់អត្ថប្រយោជន៍សង្គមនានា និងនវានុវត្តន៍វិស័យឯកជនដែលជារួម ជួយដល់ការសម្រេចបាននូវ "គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០"។

ii. យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ ចង្អុលបង្ហាញពីផែនការសកម្មភាពដែលត្រូវអនុវត្តដើម្បីសម្រេចឲ្យបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើនបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា ដូចមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥។ យុទ្ធសាស្ត្រជាតិនេះត្រូវបានរៀបចំដោយផ្អែកលើទិន្នន័យបានមកពីរបាយការណ៍វិភាគស្ថានភាពបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៧[1] ដែលបានវិភាគទៅលើទិន្នន័យបែបបរិមាណ បានមកពីសំណាកគំរូតំណាងឲ្យទូទាំងប្រទេសចំនួន៣ ១៥០នាក់ ព្រមទាំងទិន្នន័យនិងព័ត៌មានតាមរយៈការសម្ភាសដោយផ្ទាល់ជាមួយអ្នកផ្គត់ផ្គង់សេវាហិរញ្ញវត្ថុចំនួន២៧៦គ្រឹះស្ថាន និងការសម្ភាសជាមួយភាគីពាក់ព័ន្ធផ្នែកផ្គត់ផ្គង់ផ្សេងទៀតចំនួន១៥២គ្រឹះស្ថាន ដែលធ្វើឡើងដោយភ្នាក់ងារ ហ្វីនម៉ាក ត្រាស់ (FinMark Trust) ក្នុងឆ្នាំ២០១៥ និងដោយភ្នាក់ងារ សេនហ្វ្រី(Cenfri)ក្នុងឆ្នាំ២០១៦ សហការជាមួយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។ របាយការណ៍វិភាគស្ថានភាពបរិយាបន្នហិរញ្ញវត្ថុនេះ

និងជួយដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តផែនការសកម្មភាពនៃបរិយាបន្នហិរញ្ញវត្ថុ ដោយកំណត់បញ្ហាប្រឈមនិងកាលានុវត្តភាពនាពេលបច្ចុប្បន្ន និងដាក់ចេញនូវវិធានការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុបន្ថែមទៀត។ យុទ្ធសាស្ត្រជាតិនេះគឺជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយនិងបង្កើតក្របខ័ណ្ឌអនុវត្តសម្រាប់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។

iii. ប្រជាជនពេញវ័យនៅកម្ពុជាប្រមាណ៥៩%ទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ(ក្នុងនោះ ១៧%ពីគ្រឹះស្ថានធនាគារ និង៤២%ពីគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត) ១២%ទទួលបានសេវាហិរញ្ញវត្ថុក្រៅផ្លូវការ និង២៩%មិនបានប្រើប្រាស់សេវាហិរញ្ញវត្ថុទាំងផ្លូវការនិងក្រៅផ្លូវការ តែបើធៀបនឹងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ឃើញថាការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការមានភាពប្រសើរឡើងច្រើន។ ការប្រើប្រាស់សេវាហិរញ្ញវត្ថុមានកម្រិតខ្ពស់នៅក្នុងចំណោមប្រជាជនដែលមានចំណូលច្រើន។ ប្រភពចំណូលចម្បងត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការបែងចែកប្រជាជនពេញវ័យជា៥ក្រុមគោលដៅ ដែលមានលក្ខណសម្បត្តិនិងតម្រូវការប្រហាក់ប្រហែលគ្នា។ ក្នុងនោះ ក្រុមកសិករដែលជាទីផ្សារគោលដៅធំជាងគេនៅកម្ពុជា មានចំណូលប្រចាំខែជាមធ្យម២៥០ ០០០រៀល (ប្រមាណ៦១,៥ដុល្លារអាមេរិក) គឺស្ថិតក្នុងចំណោមចំណូលកម្រិតទាបបំផុត ហើយទីផ្សារគោលដៅដែលមានចំណូលខ្ពស់បំផុត ដូចជា ក្រុមមានមុខរបរផ្លូវការ គឺជាអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការក្នុងកម្រិតខ្ពស់បំផុត។ កម្រិតបរិយាបន្នហិរញ្ញវត្ថុជារួមសម្រាប់ប្រជាជនទាំងពីរភេទ គឺប្រហាក់ប្រហែលគ្នា ដោយស្ត្រីមាន៧៣% ខ្ពស់ជាងបុរសបន្តិចដែលមាន៦៩%[២]។

iv. ឧបសគ្គចម្បងនៃបរិយាបន្នហិរញ្ញវត្ថុ គឺការយល់ដឹងនិងចំណេះដឹងផ្នែកហិរញ្ញវត្ថុនៅកម្ពុជាមានកម្រិតទាប។ លទ្ធភាពក្នុងការស្វែងយល់អំពីព័ត៌មានសេវាហិរញ្ញវត្ថុ គឺជាកត្តាសំខាន់ក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព។ ប្រជាជនភាគច្រើនប្រមាណ៧៥%មានចំណូលតិចជាង១លានរៀល(ប្រមាណ២៤៦ដុល្លារអាមេរិក)ក្នុងមួយខែ(ប្រាក់ចំណូលអាចប្រើប្រាស់បាន) ដែលជាកម្រិតទាបសម្រាប់ចំណាយលើសេវាហិរញ្ញវត្ថុ។ ទោះបីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រីកប្រតិបត្តិការនិងជំរុញការប្រើប្រាស់សេវាហិរញ្ញវត្ថុក៏ដោយ ក៏ការទទួលបានសេវាហិរញ្ញវត្ថុនៅតាមទីជនបទដាច់ស្រយាល ដូចជា នៅតាមភូមិនិងឃុំ នៅតែមានគម្លាត ហើយសេវាផ្តល់ដោយគ្រឹះស្ថានទាំងនេះនៅមានកម្រិតនៅឡើយ។ ដើម្បីជំរុញការប្រើប្រាស់បន្ថែមទៀតសេវាហិរញ្ញវត្ថុទាំងនេះត្រូវកែសម្រួលឲ្យស្របទៅនឹងស្ថានភាពនិងតម្រូវការសេដ្ឋកិច្ចសង្គមរបស់ទីផ្សារគោលដៅ។ កត្តានេះបានធ្វើឲ្យប្រជាជនដែលមិនបានទទួលសេវាហិរញ្ញវត្ថុពីគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ ងាកទៅរកការប្រើប្រាស់បណ្តាញក្រៅផ្លូវការឬមិនប្រើប្រាស់សេវាហិរញ្ញវត្ថុតែម្តង។

v. មកដល់បច្ចុប្បន្ន វិស័យធានារ៉ាប់រងមានប្រតិបត្តិករធានារ៉ាប់រងចំនួន៦៩ដែលកំពុងផ្តល់និងចែកចាយសេវាធានារ៉ាប់រង រួមមាន ការធានារ៉ាប់រងទូទៅ ការធានារ៉ាប់រងអាយុជីវិត និងការធានារ៉ាប់រងខ្នាតតូច។ អត្រានៃការប្រើប្រាស់សេវាធានារ៉ាប់រងបានកើនឡើង ក្នុងនោះប្រជាជនពេញវ័យបាន

ប្រើប្រាស់សេវាធានារ៉ាប់រងប្រមាណ២៨%ក្នុងឆ្នាំ២០១៨ និងអត្រានៃចំណូលពីសេវាធានារ៉ាប់រងធៀបនឹងផ.ស.ស. បានកើនឡើងពី០,៦១%នៅឆ្នាំ២០១០ ទៅ០,៨៣%នៅឆ្នាំ២០១៨ ហើយក្នុងកំលុងពេលដូចគ្នាដែរ ដង់ស៊ីតេធានារ៉ាប់រងបានកើនឡើងពី១,៧៣ដុល្លារអាមេរិកក្នុងម្នាក់ទៅ១២,០៤ដុល្លារអាមេរិកក្នុងម្នាក់។

vi. យុទ្ធសាស្រ្តនានាដែលគាំទ្រដល់គោលដៅជាតិក្នុងការបង្កើនកម្រិតបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជាបានបង្ហាញយ៉ាងលម្អិតនៅក្នុងយុទ្ធសាស្រ្តជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ ដោយផ្តល់នូវក្របខ័ណ្ឌក្នុងការកំណត់ បែងចែកកម្រិតអាទិភាព សម្របសម្រួល វាស់វែង និងតាមដានការអនុវត្តវិធានការទាំងនេះ។ យុទ្ធសាស្រ្តជាតិនេះ លើកឡើងនូវគោលនយោបាយដែលចង្អុលបង្ហាញពីគោលដៅ ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ដូចខាងក្រោម៖

**បង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការដែលមានគុណភាព កាត់បន្ថយអត្រាស្រ្តីដែលមិនទាន់ទទួលបានសេវាហិរញ្ញវត្ថុឲ្យបានពាក់កណ្តាលពី២៧%មក១៣% និងពង្រីកការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការពី៥៩%ទៅ៧០% ត្រឹមឆ្នាំ២០២៥ ព្រមទាំងធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាពគ្រួសារ និងគាំទ្រកំណើនសេដ្ឋកិច្ច តាមរយៈសកម្មភាពអាទិភាព ដូចខាងក្រោម៖**

១- លើកទឹកចិត្តឲ្យមានការសន្សំនៅតាមគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ
២- ជំរុញនវានុវត្តន៍សេវាឥណទាន សម្រាប់សហគ្រាសធុនតូចនិងមធ្យម
៣- ពង្រីកសមត្ថភាពប្រព័ន្ធទូទាត់
៤- ពង្រីកការផ្តល់សេវាធានារ៉ាប់រងឲ្យបានទូលំទូលាយ
៥- ពង្រឹងសមត្ថភាពនិយ័តករវិស័យហិរញ្ញវត្ថុ និង
៦- លើកកម្ពស់សិទ្ធិនិងបង្កើនកិច្ចការពារអតិថិជន ព្រមទាំងបង្កើនតម្លាភាពក្នុងវិស័យហិរញ្ញវត្ថុ។

vii. សកម្មភាពអាទិភាពខាងលើត្រូវបានកំណត់ ផ្អែកលើរបាយការណ៍វិភាគស្ថានភាពបរិយាបន្នហិរញ្ញវត្ថុដោយពិចារណាលើតម្រូវការរបស់អតិថិជន និងឧបសគ្គដែលរារាំងដល់ការទទួលបាននិងការប្រើប្រាស់សេវាហិរញ្ញវត្ថុ។ វិធានការឈានទៅសម្រេចសកម្មភាពអាទិភាពនឹងត្រូវអនុវត្តស្របតាមយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥។ ការកំណត់សកម្មភាពអាទិភាពទាំងនេះក៏ពិចារណាផងដែរទៅលើគំនិតផ្តួចផ្តើមនៃបរិយាបន្នហិរញ្ញវត្ថុដែលមាននាពេលបច្ចុប្បន្ន។

viii. ផ្អែកលើសកម្មភាពអាទិភាពនៅក្នុងយុទ្ធសាស្រ្តជាតិ ផែនការសកម្មភាពត្រូវបានរៀបចំឡើងដោយរួមមាន សកម្មភាពរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ក្នុងគោលដៅរួមចំណែកដល់ការសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាល។ ផែនការសកម្មភាពនៃយុទ្ធសាស្រ្តជាតិនេះមានគោលដៅសម្រេចឲ្យបាននូវសកម្មភាពអាទិភាពទាំង៦ដែលគ្របដណ្តប់

ផ្នែកសំខាន់ៗនៃបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។ ទន្ទឹមនេះ ការអនុវត្តជាក់ស្តែងនៃផែនការសកម្មភាព នឹងមានឥទ្ធិពលលើវិស័យហិរញ្ញវត្ថុនិងសេដ្ឋកិច្ចកម្ពុជាទាំងមូល។

ix. យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥នឹងត្រូវបានប្រើប្រាស់ជាទិសដៅ សម្រាប់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍនានា និងវិស័យឯកជន អនុវត្តរួមគ្នា និងផ្តោតការយកចិត្ត ទុកដាក់ទៅលើផ្នែកដែលទាមទារឲ្យមានវិធានការជាបន្ទាន់។ ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងមហាផ្ទៃ ដែល ជាស្ថាប័នដឹកនាំការអនុវត្តនឹងជួយសម្របសម្រួលការអនុវត្តផែនការសកម្មភាព និងជានាំឲ្យមាន កិច្ចសហការរវាងភាគីពាក់ព័ន្ធទាំងអស់ដើម្បីសម្រេចគោលដៅបរិយាបន្នហិរញ្ញវត្ថុ។

# ជំពូក១

# សេចក្តីផ្តើម

១- រាជរដ្ឋាភិបាលបានទទួលស្គាល់តួនាទីរបស់វិស័យហិរញ្ញវត្ថុ ក្នុងការជំរុញកំណើនសេដ្ឋកិច្ច តាមរយៈការបង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ។ ដូច្នេះ រាជរដ្ឋាភិបាលបានកំណត់គោលដៅលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ស្របតាមគោលនយោបាយលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ដូចមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥។ វិស័យហិរញ្ញវត្ថុដែលដំណើរការល្អ ជាមូលដ្ឋានក្នុងការផ្តល់លទ្ធភាពឲ្យគ្រួសារដែលមិនទាន់ទទួលបានសេវាហិរញ្ញវត្ថុនិងទទួលបានតិចតួច អាចប្រើប្រាស់សេវាហិរញ្ញវត្ថុសមស្របនិងមានតម្លៃសមរម្យ។

២- ការសិក្សាបានបង្ហាញថា បរិយាបន្នហិរញ្ញវត្ថុនិងកំណើនសេដ្ឋកិច្ចមានទំនាក់ទំនងជាវិជ្ជមានជាមួយគ្នាជាពិសេស តាមរយៈការពង្រីកប្រតិបត្តិការសេវាហិរញ្ញវត្ថុ ភាពងាយស្រួលក្នុងការស្វែងរកនិងការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត។ ទន្ទឹមនេះ ទីផ្សារហិរញ្ញវត្ថុដែលមានលក្ខណៈរឹតត្បិតបានរារាំងដល់ការសន្សំ កាត់បន្ថយប្រសិទ្ធភាពនៃការបែងចែកធនធានហិរញ្ញវត្ថុបង្កើនចម្រៀកទីផ្សារហិរញ្ញវត្ថុ និងបង្អាក់ដល់ការវិនិយោគ។ ដូច្នេះ ការគ្រប់គ្រងរឹតត្បិតនៃទីផ្សារហិរញ្ញវត្ថុបានធ្វើឲ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច[១]។

៣- ការបង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុត្រូវបានផ្សារភ្ជាប់ទៅនឹងកំណើនសេដ្ឋកិច្ច ស្ថិរភាពចំណូល និងការកាត់បន្ថយភាពក្រីក្រ[២]។ ការទទួលបានសេវាហិរញ្ញវត្ថុដែលមានតម្លៃសមរម្យនឹងជួយឲ្យប្រជាជនដែលមានចំណូលទាបអាចគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនបានប្រសើរជាងមុន និងបង្កើនផលវិជ្ជមានដល់សេដ្ឋកិច្ច[៣]។ ភាពស៊ីជម្រៅនៃសេវាហិរញ្ញវត្ថុជួយពន្លឿនកំណើនសេដ្ឋកិច្ចតាមរយៈការពង្រីកលទ្ធភាពដល់ប្រជាជនដែលខ្វះខាតធនធានហិរញ្ញវត្ថុក្នុងការទទួលបានសេវាហិរញ្ញវត្ថុ ដែលនឹងជួយពង្រឹងភាពធន់និងសមត្ថភាពទប់ទល់នឹងវិបត្តិ លើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាបន្ន។

៤- អាជីវកម្មទទួលបញ្ញើនិងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន បានដើរតួនាទីមួយចំណែកនៃធាតុផ្សំបរិយាបន្នហិរញ្ញវត្ថុក្នុងការជួយពង្រីកនិងផ្តល់សេវាប្រាក់កម្ចីខ្នាតតូចនិងមធ្យម ជូនដល់ប្រជាជនដែលត្រូវការសាច់ប្រាក់បន្ទាន់ និងបំពេញបន្ថែមសម្រាប់អាជីវកម្មខ្នាតតូចផងដែរ។

៥- ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនឹងជួយឲ្យការវិនិយោគកាន់តែមានទំហំធំនិងការបែងចែកដើមទុនកាន់តែមានផលិតភាព ដែលធ្វើឲ្យកំណើនប្រាក់ចំណូលខ្ពស់ជាងមុន[៤]។ ជាមួយគ្នានេះ ការផ្តល់សេវាសន្សំនិងសេវាទូទាត់ដែលល្អនិងមានតម្លៃទាបជាងមុន អាចឲ្យក្រុមហ៊ុននិងអ្នកប្រើប្រាស់ជៀសវាងការចំណាយក្នុងការទូទាត់ជាសាច់ប្រាក់ កាត់បន្ថយចំណាយផ្ទេរប្រាក់ និងផ្តល់ឱកាសក្នុងការសន្សំទ្រព្យធននិងរក្សាស្ថិរភាពចំណូល។

៦- រាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ តាមរយៈគោលនយោបាយពហុវិស័យ រួមទាំងការបង្កើតគោលនយោបាយបរិយាបន្នហិរញ្ញវត្ថុ។ ក្នុងន័យនេះ យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ នឹងបង្ហាញអំពីផែនការសកម្មភាពដែលគាំទ្រដល់ការពង្រីកលទ្ធភាពក្នុងការទទួលនិងការផ្តល់សេវាហិរញ្ញវត្ថុឱ្យកាន់តែប្រសើរឡើង សម្រាប់ប្រជាជននិងសហគ្រាសធុនតូចនិងមធ្យម ដោយផ្តោតលើការប្រើប្រាស់របស់ប្រជាជនពេញវ័យកម្ពុជាដែលមានអាយុចាប់ពី១៨ឆ្នាំ ចំពោះសេវាហិរញ្ញវត្ថុចំនួន៤ រួមមានសេវាសន្សំ សេវាទូទាត់ សេវាឥណទាន និងសេវាធានារ៉ាប់រង។

៧- យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ បង្ហាញអំពីអនុសាសន៍សម្រាប់សកម្មភាពអាទិភាពដើម្បីបំពេញតម្រូវការហិរញ្ញវត្ថុរបស់ទីផ្សារ។

៨- សកម្មភាពអាទិភាពដែលបានកំណត់នៅក្នុងឯកសារយុទ្ធសាស្ត្រនេះ គឺដើម្បីសម្រេចបាននូវគោលដៅជាក់លាក់នៃការអភិវឌ្ឍប្រកបដោយចីរភាព។ ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ពិតជាមានសារៈសំខាន់ក្នុងការសម្រេចបាននូវគោលដៅលុបបំបាត់ភាពក្រីក្រគ្រប់រូបភាពនិងគ្រប់ទីកន្លែង(គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ចំណុចទី១)។ ការជំរុញការសន្សំប្រាក់នៅគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ តាមរយៈការលើកទឹកចិត្តកៀរគរប្រមូលប្រាក់សន្សំនិងការលើកកម្ពស់ការទទួលបានសេវាសន្សំផ្សេងៗ អាចជួយកាត់បន្ថយភាពក្រីក្រ។ ការបង្កើនលទ្ធភាពរបស់ប្រជាជនគោលដៅ ក្នុងការទទួលបានកម្ចី និងសេវាធានារ៉ាប់រងខ្នាតតូចនឹងនាំទៅរកការសម្រេចបាននូវចំណុចទី១នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

៩- ការលើកកម្ពស់សិទ្ធិនិងបង្កើនកិច្ចការពារអតិថិជន ព្រមទាំងបង្កើនតម្លាភាពក្នុងវិស័យហិរញ្ញវត្ថុ គឺដើម្បីជួយជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាបន្ន ភាពមានការងារធ្វើនិងបទដ្ឋានការងារសមរម្យសម្រាប់គ្រប់គ្នា(គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ចំណុចទី៨) និងកាត់បន្ថយវិសមភាពនៅកម្ពុជា និងជាមួយប្រទេសនានា (គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ចំណុចទី១០)។ ទន្ទឹមនេះ វិធានការជាក់លាក់ ដូចជា ការបង្កើនចំណេះដឹងផ្នែកហិរញ្ញវត្ថុ នឹងជួយដល់ការប្រើប្រាស់ប្រាក់កម្ចីនិងការផ្តល់ប្រាក់កម្ចីប្រកបដោយការទទួលខុសត្រូវ ដែលនឹងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ ការធ្វើយុទ្ធនាការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុដោយផ្តោតលើប្រជាជនដែលទទួលបានសេវាហិរញ្ញវត្ថុតិចតួច អាចជួយកាត់បន្ថយវិសមភាពនៅកម្ពុជា។

១០- ការលើកកម្ពស់យុទ្ធសាស្ត្រយេនឌ័រ តាមរយៈការរៀបចំគោលនយោបាយដែលអាចធានានូវបរិស្ថានគាំទ្រយេនឌ័រ នឹងជួយឱ្យសម្រេចបានសមភាពយេនឌ័រ និងការផ្តល់សិទ្ធិដល់ស្ត្រីនិងកុមារី (គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ចំណុចទី៥) ទាក់ទងនឹងបរិយាបន្នហិរញ្ញវត្ថុ។ ការរៀបចំយុទ្ធសាស្ត្រច្បាស់លាស់ ដោយសហការជាមួយដៃគូដើម្បីបង្កើតសេវាសន្សំសម្រាប់ស្ត្រី និងកសាងសមត្ថភាពផ្នែកហិរញ្ញវត្ថុនិងជំនាញគ្រប់គ្រងដល់សហគ្រិនជាស្ត្រីដែលមានសក្តានុពល នឹងជួយកាត់បន្ថយគម្លាតយេនឌ័រទាក់ទងនឹងបរិយាបន្នហិរញ្ញវត្ថុ។

# ជំពូក២
# បរិបទវិស័យហិរញ្ញវត្ថុនៅកម្ពុជា

## I. បរិបទប្រទេសកម្ពុជា

**១១- សេដ្ឋកិច្ចកម្ពុជា :** សេដ្ឋកិច្ចមានការរីកលូតលាស់គួរឲ្យកត់សម្គាល់ ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ជាមួយអត្រាកំណើនជាមធ្យម ៧,៧%[7] ចាប់ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ២០១៥ កម្ពុជាត្រូវបានចាត់ថ្នាក់ជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនលឿននៅក្នុងពិភពលោក។ កំណើនសេដ្ឋកិច្ចដ៏រឹងមាំក្នុងរយៈពេលពីរទសវត្សរ៍នេះ បានប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៦[8]។ ជាមួយវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់បន្ថែមទៀតលើកំណែទម្រង់រចនាសម្ព័ន្ធសង្គមនិងសេដ្ឋកិច្ច និងបានបង្កើនឳកាសសម្រាប់ចំណាយមូលធន។ កម្ពុជាបាននិងកំពុងកាត់បន្ថយឱនភាពគណនីចរន្តមកត្រឹម៧,១%នៃផ.ស.ស.ក្នុងឆ្នាំ២០១៧ តាមរយៈលំហូរចូលយ៉ាងច្រើននៃវិនិយោគផ្ទាល់បរទេសដែលត្រូវបានប៉ាន់ស្មានថាមានទំហំរហូតដល់២,៨ប៊ីលានដុល្លារអាមេរិក(ឬ១៣%នៃផ.ស.ស.) ក្នុងឆ្នាំ២០១៧[9]។

**១២- ព័ត៌មានអំពីប្រជាជន : យោងតាមឯកសាររបស់វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០១៣ ប្រជាជនមានវ័យក្មេងជាស្ត្រីច្រើនជាងបុរស និងភាគច្រើនរស់នៅតំបន់ជនបទ[10]**

- ប្រជាជនសរុប : ១៤,៧លាននាក់
- ប្រជាជនពេញវ័យសរុប(១៨ឆ្នាំឡើងទៅ) : ប្រមាណ៩,៩លាននាក់
- ប្រជាជនវ័យក្មេង(អាយុក្រោម៤០ឆ្នាំ) : ៦៣%នៃចំនួនប្រជាជនសរុប
- ប្រជាជនភាគច្រើនរស់នៅតំបន់ជនបទ : ៧៥%នៃចំនួនប្រជាជនសរុប
- ភេទ : ៥២%ជាស្ត្រីនិង៤៨%ជាបុរស
- មេគ្រួសារជាបុរស : ៧៣%

**១៣- ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម : ការអភិវឌ្ឍមានស្ថិរភាព ទោះបីជាចំណាត់ថ្នាក់ជាសកលមានកម្រិតទាប**

- អាយុមធ្យមសង្ឃឹមរស់បានកើនឡើងដល់៧១ឆ្នាំសម្រាប់ស្ត្រី និង៦៧ឆ្នាំសម្រាប់បុរស
- ៤៣%នៃចំនួនប្រជាជនសរុបមានកម្រិតវប្បធម៌ត្រឹមថ្នាក់មូលដ្ឋាននិងអត្រាអក្ខរកម្មប្រជាជនពេញវ័យមាន៨០%ក្នុងឆ្នាំ២០១៣។ អត្រាចុះឈ្មោះចូលរៀនថ្នាក់វិទ្យាល័យមាន២៤% ហើយអត្រាបោះបង់ចោលការសិក្សានៅថ្នាក់បឋមមាន៨,១% ថ្នាក់អនុវិទ្យាល័យមាន១៥,៤% និងថ្នាក់វិទ្យាល័យមាន១៨,៣%[11]។

- សន្ទស្សន៍អភិវឌ្ឍធនធានមនុស្សមានចំណាត់ថ្នាក់ទី១៤៣ក្នុងចំណោមប្រទេសចំនួន១៨៨ នៅឆ្នាំ២០១៤ ប៉ុន្តែចំណាត់ថ្នាក់នេះស្ថិតនៅក្នុងកម្រិតមធ្យមនៃការអភិវឌ្ឍធនធានមនុស្ស[១២]។

## ១៤- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគឺជាគន្លឹះអាទិភាព

- ប្រវែងផ្លូវសរុបក្នុងប្រទេសកម្ពុជាមាន៤៧ ២៦៣គីឡូម៉ែត្រ ដែល៧៤%ជាផ្លូវនៅជនបទនិងខេត្ត ក្នុងនោះផ្លូវជាតិនិងផ្លូវខេត្តមានប្រវែង១៣ ៣៤០គីឡូម៉ែត្រ។ រាជរដ្ឋាភិបាលគ្រោងអភិវឌ្ឍផ្លូវជាតិ និងផ្លូវខេត្តឲ្យបានដល់១៦ ៤៨២គីឡូម៉ែត្រ ត្រឹមឆ្នាំ២០២៣[១៣]។
- រាជរដ្ឋាភិបាលកំពុងរៀបចំទស្សនវិស័យ ដើម្បីឲ្យប្រជាជនគ្រប់រូបមានអគ្គិសនីប្រើប្រាស់នៅក្នុងឆ្នាំ២០២០ តាមរយៈការវិនិយោគលើគម្រោងថាមពលវារីអគ្គិសនី គម្រោងថាមពលព្រះអាទិត្យ និងការពង្រីកបណ្ដាញអគ្គិសនី[១៤]។
- ប្រទេសកម្ពុជាមានដង់ស៊ីតេអ្នកប្រើប្រាស់បណ្ដាញទូរស័ព្ទសរុប១២១,៣៨%។ អត្រាប្រើប្រាស់ទូរស័ព្ទចល័តមាន១២០,៨៣% ដែលមានអ្នកជាវប្រើប្រាស់ចំនួន១៩,៤២លាននាក់ និងអត្រាប្រើប្រាស់អ៊ិនធឺណិតមាន៨៤,៧០% ស្មើនឹងអ្នកប្រើប្រាស់ចំនួន១៣,៤៦លាននាក់[១៥]។
- រាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់អភិវឌ្ឍបណ្ដាញហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិនិងតំបន់ និងសមត្ថភាពដឹកជញ្ជូនដើម្បីលើកកម្ពស់ការតភ្ជាប់បណ្ដាញគមនាគមន៍នៅកម្ពុជានិងក្នុងតំបន់[១៦]។

## ១៥- កំណើនសេដ្ឋកិច្ច : ការកើនឡើងយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចគាំទ្រដោយកំណើននៃការនាំចេញ

- កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានគាំទ្រដោយស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលត្រូវបានឆ្លុះបញ្ចាំងដោយកំណើនសេដ្ឋកិច្ចថេរនិងរឹងមាំ ក្នុងអត្រាខ្ពស់ជាង៧%ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយ ឱនភាពសារពើពន្ធមានកម្រិតទាប(១,៤%នៃផ.ស.ស.) និងគោលនយោបាយសេដ្ឋកិច្ចប្រកបដោយភាពប្រុងប្រយ័ត្នជាមួយបំណុលសាធារណៈកម្រិតទាប អតិរេកជញ្ជីងទូទាត់(៧,៤%នៃផ.ស.ស. ក្នុងឆ្នាំ២០១៧)អត្រាអតិផរណាទាប(២,២៣%នៅចុងឆ្នាំ២០១៧) និងការកើនឡើងគួរឲ្យកត់សម្គាល់នៃទុនបម្រុងអន្តរជាតិ(៨,៧ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១៧)។
- ផ.ស.ស.ក្នុងប្រជាជនម្នាក់ក្នុងមួយឆ្នាំបានកើនឡើងពី១ ០៤២ដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ ដល់ ១ ៤៣៥ដុល្លារអាមេរិកក្នុងឆ្នាំ២០១៧។
- សេដ្ឋកិច្ចកម្ពុជាដែលធ្លាប់ពឹងផ្អែកខ្លាំងលើវិស័យកសិកម្មបានបោះជំហានពីការពឹងផ្អែកលើការធ្វើកសិកម្មតាមយថាផលទៅជាតាមបែបទំនើបនិងវិស័យឧស្សាហកម្ម។
- ក្នុងឆ្នាំ២០១៧ វិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម បានចូលរួមចំណែក ១៩,២% ៣៤,១% និង ៣៩,៤% រៀងគ្នា នៃផ.ស.ស.។

- ក្នុងចំណោមប្រជាជនកម្ពុជាសរុប មានប្រជាជនប្រមាណ៣៣%ជាកសិករ។ ជាមួយគ្នានេះ ២៥%នៃក្រុមមានមុខរបរផ្លូវការ ២៧%នៃក្រុមមានមុខរបរក្រៅផ្លូវការ ២២%នៃក្រុមមានមុខរបរផ្ទាល់ខ្លួន និង ១៩%នៃក្រុមអ្នកនៅក្នុងបន្ទុក មានប្រភពចំណូលបន្ថែមពីការធ្វើកសិកម្ម។

**១៦- ការបែងចែកប្រាក់ចំណូល : ប្រាក់ចំណូលទាបប៉ុន្តែប្រកបដោយកម្រិតសមធម៌សមរម្យនិងកាត់បន្ថយភាពក្រីក្រ**

- ស្របពេលដែលផ.ស.ស.ក្នុងប្រជាជនម្នាក់ក្នុងមួយឆ្នាំមានការកើនឡើង ប្រទេសកម្ពុជាបានកាត់បន្ថយអត្រាភាពក្រីក្រគួរឲ្យកត់សម្គាល់ពី៥៣,៥%ក្នុងឆ្នាំ២០០៤ មកនៅត្រឹម១៣,៥%ក្នុងឆ្នាំ២០១៤ ដោយគិតជាភាគរយនៃចំនួនប្រជាជនរស់នៅក្រោមបន្ទាត់ប្រាក់ចំណូលជាតិ ហើយអត្រានេះបានធ្លាក់ចុះជាបន្តបន្ទាប់ថែមទៀតក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ(ប្រមាណ១០%ក្នុងឆ្នាំ២០១៨) ព្រមទាំងរួមចំណែកយ៉ាងសំខាន់ដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា។
- បច្ចុប្បន្ន កម្ពុជាបានវិវឌ្ឍពីប្រទេសដែលមានចំណូលកម្រិតទាបទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប[១៧]។
- ចំណូលជាមធ្យមប្រចាំខែរបស់ប្រជាជនម្នាក់ៗមានចំនួន៩៤២ ២៨៨រៀល(ប្រមាណ២៣១,៦៣ដុល្លារអាមេរិក)[១៨]។
- ប្រជាជនកម្ពុជាប្រមាណ៧៥%មានចំណូលតិចជាង១លានរៀល(ប្រមាណ២៤៦ដុល្លារអាមេរិក)ក្នុងមួយខែ[១៩]។
- ប្រជាជនចំនួនប្រមាណ១/៥នៃប្រជាជនសរុប មានចំណូលច្រើនជាងពាក់កណ្តាលនៃចំណូលរបស់ប្រទេសទាំងមូល ដែលស្មើនឹង១៨ដងនៃចំណូលរបស់ប្រជាជនដែលមានចំណូលទាបបំផុត ២០%[២០]។

**១៧- សេដ្ឋកិច្ចពហុរូបិយបណ្ណ : ចរាចរណ៍ខ្ពស់នៃប្រាក់ដុល្លារអាមេរិកជាមួយនឹងកិច្ចខិតខំបង្កើនការប្រើប្រាស់រូបិយវត្ថុ**

- ប្រាក់បញ្ញើជារូបិយបណ្ណមានប្រមាណ៨៣%នៃការផ្គត់ផ្គង់រូបិយវត្ថុទូទៅក្នុងឆ្នាំ២០១៧។ ដុល្លារូបនីយកម្មបានចូលរួមមួយចំណែកក្នុងការរក្សាស្ថិរភាពថ្លៃនិងស្ថិរភាពអត្រាប្តូរប្រាក់ ដែលនាំឲ្យមានអតិផរណាទាប និងបញ្ចៀសការធ្លាក់ថ្លៃនៃរូបិយវត្ថុ នៅពេលដែលមានលំហូរចេញខ្លាំងនៃដើមទុន។
- ទោះបីជាដុល្លារូបនីយកម្មបានដាក់កំហិតដល់ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុ និងតួនាទីរបស់ធនាគារកណ្តាល ក្នុងនាមជាអ្នកផ្តល់កម្ចីចុងក្រោយ ធនាគារជាតិនៃកម្ពុជាបានបន្ត

ខិតខំប្រឹងប្រែងអភិវឌ្ឍនិងដាក់ចេញនូវឧបករណ៍គោលនយោបាយរូបិយវត្ថុជាច្រើន ដូចជា មូលបត្រអាចជួញដូរបាន និងប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា ជាដើម ក្នុងគោលបំណងជំរុញការគ្រប់គ្រងសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អភិវឌ្ឍទីផ្សារអន្តរធនាគារ និងលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុ។

- ក្នុងឆ្នាំ២០១៧ រូបិយវត្ថុក្នុងចរាចរណ៍និងប្រាក់បញ្ញើជារូបិយវត្ថុ បានកើនឡើងរៀងគ្នា២៨%និង ១៧,៩%។ កម្ពុជាបានអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀល ដោយផ្អែកលើយន្តការទីផ្សារនិងការរីកចម្រើននៃវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នៅក្នុងវិស័យធនាគារ វិធានការទាំងនេះរួមមាន ការរក្សាតម្លៃប្រាក់រៀល ការផ្គត់ផ្គង់ប្រាក់រៀលតាមតម្រូវការនៅគ្រប់តំបន់ ការលើកកម្ពស់សោភណភាពនិងគុណភាពប្រាក់រៀល និងការកំណត់ឲ្យមានកម្រិតអប្បបរមានៃសមាមាត្រកម្ចីជាប្រាក់រៀលធៀបនឹងប្រាក់កម្ចីសរុបរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។
- វិស័យធានារ៉ាប់រងបានកកើតឡើង ស្របពេលដែលសេដ្ឋកិច្ចកម្ពុជាអនុវត្តការទូទាត់សេវាធានារ៉ាប់រងក្នុងរូបភាពពហុរូបិយបណ្ណ ដូចជា ប្រាក់ដុល្លារអាមេរិកនិងប្រាក់រៀលនៅលើសេវាកម្មដែលមានលក្ខណៈពាណិជ្ជកម្ម។

**ប្រអប់ទី១ : ចំណែកនៃការទទួលបានឬប្រើប្រាស់សេវាហិរញ្ញវត្ថុ** ( Financial Access Strand )

ចំណែកនៃការទទួលបានឬប្រើប្រាស់សេវាហិរញ្ញវត្ថុ[២១] ត្រូវបានប្រើប្រាស់ដើម្បីប្រៀបធៀបកម្រិតបរិយាបន្នហិរញ្ញវត្ថុពីប្រទេសមួយទៅប្រទេសមួយទៀតឬទៅតាមប្រភេទទីផ្សារផ្សេងៗ។ ផ្អែកលើរបាយការណ៍វិភាគស្ថានភាពបរិយាបន្នហិរញ្ញវត្ថុរបស់ MAP ឆ្នាំ២០១៧ ការគណនាចំណែកនៃការទទួលបានឬប្រើប្រាស់សេវាហិរញ្ញវត្ថុ បានបែងចែកដូចខាងក្រោមៈ

ក- ចំណែកនៃការទទួលបានឬប្រើប្រាស់សេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានធនាគារ សំដៅដល់ប្រជាជនពេញវ័យ(គិតជាភាគរយ)ដែលទទួលបានឬប្រើប្រាស់សេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានធនាគារដែលស្ថិតនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា។ ប្រជាជនពេញវ័យខាងលើមិនត្រឹមតែប្រើប្រាស់សេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានធនាគារប៉ុណ្ណោះទេ តែក៏អាចប្រើប្រាស់សេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀតឬអ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការផងដែរ។

ខ- ចំណែកនៃការទទួលបានឬប្រើប្រាស់សេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត សំដៅដល់ប្រជាជនពេញវ័យ(គិតជាភាគរយ)ដែលទទួលបានឬប្រើប្រាស់សេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗទៀតដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់អាជ្ញាធរត្រួតពិនិត្យ ដូចមានចែងក្នុងច្បាប់ រួមមាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(រួមទាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ) ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ សហគមន៍សន្សំនិងឥណទាន សហគមន៍ សង្គហសមាគម និងគ្រឹះស្ថានសន្សំតាមប្រៃសណីយ៍។ ទន្ទឹមនេះ សេវាធានារ៉ាប់រងដែលរួមមាន សេវាធានារ៉ាប់រងទូទៅ សេវាធានារ៉ាប់រងអាយុជីវិត និងសេវាធានារ៉ាប់រងខ្នាតតូច ត្រូវបានប្រើប្រាស់ដោយនីតិបុគ្គលនិងរូបវន្តបុគ្គល ដើម្បីធានាលើហានិភ័យទ្រព្យសម្បត្តិ ភារៈទទួលខុសត្រូវ អាយុជីវិត សុខភាព និងគ្រោះថ្នាក់បុគ្គលជាដើម។ តាមរយៈទិន្នន័យរបស់សេវាធានារ៉ាប់រងអាយុជីវិត អតិថិជនដែលប្រើប្រាស់សេវាប្រភេទនេះ ភាគច្រើនស្ថិតក្នុងស្រទាប់យុវជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។ សេវាទាំងនេះបាននិងកំពុងចែកចាយលក់ស្ថិតនៅក្នុងក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិស្តីពីការធានារ៉ាប់រង។ ប្រជាជនពេញវ័យខាងលើ ក៏អាចប្រើប្រាស់សេវាហិរញ្ញវត្ថុផ្តល់ដោយអ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការផងដែរ។

ប្រជាជនដែលទទួលបានឬប្រើប្រាស់សេវាហិរញ្ញវត្ថុផ្តល់ដោយ គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ត្រូវចាត់ទុកថាបានប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការឬបណ្តាញផ្លូវការ។

គ- ចំណែកនៃការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្តល់ដោយអ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ សំដៅដល់ប្រជាជនពេញវ័យ(គិតជាភាគរយ)ដែលមិនបានប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ប៉ុន្តែប្រើប្រាស់សេវាហិរញ្ញវត្ថុក្រៅផ្លូវការឬបណ្តាញក្រៅផ្លូវការ។ ការប្រើប្រាស់បែបនេះគឺជាការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្តល់ដោយអ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការតែប៉ុណ្ណោះ ដោយមិនរាប់បញ្ចូលប្រជាជនដែលបានប្រើប្រាស់សេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត។

ឃ- ចំណែកនៃការមិនបានប្រើប្រាស់សេវាហិរញ្ញវត្ថុ សំដៅដល់ប្រជាជនពេញវ័យ(គិតជាភាគរយ) ដែលមិនប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការឬក្រៅផ្លូវការសម្រាប់តម្រូវការជីវភាពរស់នៅ។

ចំណែកនៃការទទួលបានសេវាហិរញ្ញវត្ថុមិនរាប់បញ្ចូលភាពត្រួតគ្នារវាងការទទួលបានសេវាហិរញ្ញវត្ថុពីប្រភពផ្សេងៗគ្នានោះទេ។

## II. ស្ថានភាពបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា

១៨- **ការទទួលបានសេវាហិរញ្ញវត្ថុផ្លូវការស្ថិតក្នុងកម្រិតមធ្យម :** ការទទួលបានសេវាហិរញ្ញវត្ថុផ្លូវការមានកម្រិតមធ្យម៥៩% ក្នុងនោះ ប្រជាជនពេញវ័យ១៧%ប្រើប្រាស់សេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានធនាគារ និង៤២%ប្រើប្រាស់សេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត[២២] ភាគច្រើនផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ហើយប្រជាជនពេញវ័យ១២%ប្រើប្រាស់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ និង២៩%មិនបានប្រើប្រាស់សេវាហិរញ្ញវត្ថុ ដូចបានបង្ហាញក្នុងរូបទី១។ បើពិនិត្យមើលការប្រើប្រាស់សេវាហិរញ្ញវត្ថុត្រួតគ្នា បង្ហាញថា ការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀតមានកម្រិត៥២%(៦%, ៤%, ២៦% និង ១៦%) និងសេវាហិរញ្ញវត្ថុក្រៅផ្លូវការមានកម្រិត៣៤%(១២%, ១៦%, ៤% និង ២%) ដូចបានបង្ហាញក្នុងរូបទី២។

**រូបទី១ : កម្រិតបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា**




១៩- **ការទទួលបានសេវាហិរញ្ញវត្ថុត្រូវបាននាំមុខដោយសេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត :** បណ្តាញសេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត រួមមាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ជាកម្លាំងជំរុញបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើផ្តល់សេវាហិរញ្ញវត្ថុដូចគ្នានឹងគ្រឹះស្ថានធនាគារដែរ ហើយមានបណ្តាញធំទូលាយជាងគេ និងផ្តល់សេវាហិរញ្ញវត្ថុខ្នាតតូចជាមួយនឹងតម្លៃសមរម្យ ស្របតាមតម្រូវការរបស់ប្រជាជននៅទីជនបទ និងប្រជាជនដែលមានចំណូលទាប។ ដូចនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើជាកាតាលីករក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុផ្លូវការនៅកម្ពុជា។ ប្រសិនបើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាជនប្រមាណ១៧% [២៣] ត្រូវបានចាត់ទុកជាផ្នែកមួយនៃសេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានធនាគារ នោះការទទួលបានសេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានធនាគារនឹងកើនដល់អត្រា៣៤%។ ទន្ទឹមនេះ ការទទួលបានសេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀតមាន៤៧%ផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហើយ ៣៣%ផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ ជារួម ២៥%នៃប្រជាជនដែលទទួលបានសេវាហិរញ្ញវត្ថុគឺផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលក្នុងនោះ ៧៣%ត្រូវ

បានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ ភាពត្រួតស៊ីគ្នាមានកម្រិតគួរឲ្យកត់សម្គាល់រវាងការទទួលបានសេវាហិរញ្ញវត្ថុផ្លូវការនិងក្រៅផ្លូវការ(១៦%) និងសេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត(៦%) ដូចមានបង្ហាញក្នុងរូបទី២។ ការណ៍នេះសបញ្ជាក់ឲ្យឃើញពីការប្រើប្រាស់សេវាហិរញ្ញវត្ថុច្រើនប្រភេទ។ គ្រឹះស្ថានធនាគារទាក់ទាញការប្រើប្រាស់សេវាហិរញ្ញវត្ថុបានតិចជាងគេ ដោយក្នុងនោះមានតែ៥%នៃប្រជាជនពេញវ័យប៉ុណ្ណោះ ដែលប្រើប្រាស់តែសេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានធនាគារ។ គួរកត់សម្គាល់ផងដែរថា ចំនួនប្រជាជនប្រើប្រាស់បណ្តាញសេវាហិរញ្ញវត្ថុក្រៅផ្លូវការ (១២%) ខ្ពស់ជាងចំនួនប្រជាជនដែលប្រើប្រាស់តែសេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានធនាគារ។ បន្ថែមលើគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត អ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការក៏បានដើរតួនាទីសំខាន់ផងដែរសម្រាប់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។

**រូបទី២ : ទិន្នន័យត្រួតស៊ីគ្នារវាងការទទួលបានឬប្រើប្រាស់សេវាហិរញ្ញវត្ថុ**




**២០- ការទទួលបានសេវាហិរញ្ញវត្ថុមានកម្រិតប្រហាក់ប្រហែលគ្នារវាងក្រុមប្រជាសាស្ត្រនីមួយៗ :** សូចនាករប្រជាសាស្ត្រសំខាន់ៗមានបីគឺ យេនឌ័រ ទីតាំងភូមិសាស្ត្រ និងការអប់រំ ដែលអាចមានឥទ្ធិពលលើបរិយាបន្នហិរញ្ញវត្ថុ ដូចខាងក្រោម៖

ក- **បរិយាបន្នហិរញ្ញវត្ថុមិនមានភាពខុសគ្នាខ្លាំងទេរវាងយេនឌ័រ :** កម្រិតបរិយាបន្នហិរញ្ញវត្ថុមានភាពប្រហាក់ប្រហែលគ្នាសម្រាប់ភេទទាំងពីរ ដែលបរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រីមានកម្រិតខ្ពស់ជាងតែបន្តិចទេ។ ការរកឃើញនេះនៅតែបន្តរក្សាលទ្ធផលដដែលនៅពេលពិនិត្យលើការប្រើប្រាស់ទៅតាមទីផ្សារនៃសេវាហិរញ្ញវត្ថុ និងអ្នកផ្តល់សេវាហិរញ្ញវត្ថុ ដោយមិនបានបង្ហាញពីភាពខុសគ្នាខ្លាំងរវាងភេទទាំងពីរ។ ទោះយ៉ាងណា ការទទួលបានសេវាហិរញ្ញវត្ថុរបស់ស្ត្រី

នៅផ្នែកមួយចំនួនមានកម្រិតទាបជាងបុរស ដូចជា ការផ្ដល់ឥណទានទៅស្ត្រីវ័យក្មេងនិងស្ត្រីដែលមានការងារធ្វើ និងការសន្សំសម្រាប់ស្ត្រីវ័យចំណាស់។

ខ- **បរិយាបន្នហិរញ្ញវត្ថុមានកម្រិតខ្ពស់នៅទីប្រជុំជន៖** ការពិនិត្យពីភាពខុសគ្នានៃស្ថានភាពភូមិសាស្ត្រចំពោះបរិយាបន្នហិរញ្ញវត្ថុបង្ហាញថាបរិយាបន្នហិរញ្ញវត្ថុនៅទីប្រជុំជនមានកម្រិតខ្ពស់ជាងនៅជនបទតិចតួច(៧៨%នៃប្រជាជនពេញវ័យនៅទីប្រជុំជន និង៦៩%នៃប្រជាជនពេញវ័យនៅជនបទទទួលបានសេវាហិរញ្ញវត្ថុ)។ បណ្ដាខេត្តដែលមានកម្រិតបរិយាបន្នហិរញ្ញវត្ថុទាបរួមមាន ខេត្តក្រចេះ ខេត្តព្រះវិហារ និងខេត្តរតនគិរី។ ប៉ុន្តែ បើពិនិត្យលើចំនួនជាក់ស្ដែងឃើញថាចំនួនប្រជាជនពេញវ័យសរុបនៅជនបទទទួលបានសេវាហិរញ្ញវត្ថុ ច្រើនជាងប្រជាជនពេញវ័យនៅទីប្រជុំជន។ ជារួម ប្រជាជនពេញវ័យនៅជនបទមានចំនួន៥,២លាននាក់ ខណៈដែលប្រជាជនពេញវ័យនៅទីប្រជុំជនមានចំនួនតែ១,៩លាននាក់ ដែលទទួលបានសេវាហិរញ្ញវត្ថុ។ គួរកត់សម្គាល់ថា ៣០%នៃប្រជាជននៅទីប្រជុំជនទទួលបានសេវាហិរញ្ញវត្ថុផ្ដល់ដោយគ្រឹះស្ថានធនាគារ ខណៈដែលប្រជាជននៅជនបទមានតែ១២%ប៉ុណ្ណោះ។ ភាគច្រើននៃប្រជាជននៅទីជនបទទទួលបានសេវាហិរញ្ញវត្ថុផ្ដល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត(៤៣%)។

គ- **កម្រិតសិក្សាកាន់តែខ្ពស់នាំឲ្យទទួលបានសេវាហិរញ្ញវត្ថុកាន់តែច្រើន :** ប្រជាជនពេញវ័យដែលមានការសិក្សាអប់រំថ្នាក់ឧត្តមសិក្សា មានលទ្ធភាពខ្ពស់ក្នុងការទទួលបានសេវាហិរញ្ញវត្ថុ ក្នុងនោះ ៨៦%នៃប្រជាជនពេញវ័យដែលមានការអប់រំថ្នាក់ឧត្តមសិក្សា ទទួលបានសេវាហិរញ្ញវត្ថុ ខណៈដែលកម្រិតទទួលបានសេវាហិរញ្ញវត្ថុនេះ មានតែ៦៨%សម្រាប់ថ្នាក់មធ្យមសិក្សា ៧២%សម្រាប់ថ្នាក់បឋមសិក្សា និង៦៧%សម្រាប់ប្រជាជនមិនបានទទួលការសិក្សា។ ភាពខុសគ្នាចម្បងរវាងក្រុមប្រជាជននីមួយៗ គឺភាគរយនៃការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្ដល់ដោយគ្រឹះស្ថានធនាគារ។ ប្រជាជនពេញវ័យដែលមានការអប់រំថ្នាក់ឧត្តមសិក្សា ទទួលបានសេវាហិរញ្ញវត្ថុផ្ដល់ដោយគ្រឹះស្ថានធនាគារប្រមាណ៥១% ហើយក្រុមផ្សេងទៀតទទួលបានសេវាហិរញ្ញវត្ថុផ្ដល់ដោយគ្រឹះស្ថានធនាគារមាន ១៨%សម្រាប់ថ្នាក់មធ្យមសិក្សា ១៣%សម្រាប់ថ្នាក់បឋមសិក្សា និង ៨%សម្រាប់ប្រជាជនមិនបានទទួលការសិក្សា។ ការណ៍នេះបង្ហាញថា គ្រឹះស្ថានធនាគារអាចពង្រីកវិសាលភាពកាន់តែខ្លាំងដល់ប្រជាជនដែលមានការសិក្សាអប់រំថ្នាក់ឧត្តមសិក្សា។

២១- **សេវាផ្ទេរប្រាក់ សេវាសន្សំ និងសេវាឥណទាន ជាសេវាហិរញ្ញវត្ថុដែលត្រូវបានប្រើប្រាស់ភាគច្រើន :** សេវាផ្ទេរប្រាក់ជាសេវាហិរញ្ញវត្ថុដែលត្រូវបានប្រើប្រាស់ដោយប្រជាជនកម្ពុជាច្រើនជាងគេ ដោយមានប្រជាជនពេញវ័យ៤៩%ផ្ញើនិងទទួលប្រាក់។ ក្នុងចំណោមអ្នកប្រើប្រាស់សេវាផ្ទេរប្រាក់ មាន៣៥%នៃប្រជាជនពេញវ័យប្រើប្រាស់បណ្ដាញផ្លូវការផ្សេងទៀត ដែលភាគច្រើនជាសេវាផ្ទេរប្រាក់តាមទូរស័ព្ទ ហើយមានតែ៣%ប៉ុណ្ណោះ ដែលប្រើប្រាស់សេវាហិរញ្ញវត្ថុផ្ដល់ដោយគ្រឹះស្ថានធនាគារ។ ប្រជាជនពេញវ័យ៤៥% សន្សំជាមួយគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ និងអ្នកផ្ដល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ។ អ្នកផ្ដល់សេវាចម្បងសម្រាប់

ការសន្សំ គឺអ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ២៥%នៃប្រជាជនពេញវ័យ បន្ទាប់មក ការសន្សំនៅផ្ទះមាន២២% និងការសន្សំនៅក្នុងបណ្តាញផ្លូវការមានកម្រិតទាប ដែលក្នុងនោះ៧%នៅគ្រឹះស្ថានធនាគារ និង ៥%នៅក្នុងបណ្តាញផ្លូវការផ្សេងទៀត។ ប្រជាជនពេញវ័យ៤២%ទទួលបានសេវាឥណទាន។ គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត បានដើរតួនាទីយ៉ាងសំខាន់ក្នុងទីផ្សារឥណទាន ក្នុងនោះមានប្រជាជនពេញវ័យ២២% ទទួលបានសេវាឥណទាន ខណៈដែល៧%ទទួលបានពីអ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ ៧%ពីគ្រួសារ និងមិត្តភក្តិ និង៦%ពីគ្រឹះស្ថានធនាគារ(រូបទី៣)។ ប្រជាជនពេញវ័យដែលប្រើប្រាស់ប្រតិបត្តិការឌីជីថល មានតែ១១%ប៉ុណ្ណោះ។ កម្រិតទាបនៃការប្រើប្រាស់ប្រតិបត្តិការឌីជីថល បង្ហាញពីការប្រើប្រាស់សាច់ប្រាក់យ៉ាងច្រើននៅក្នុងសេដ្ឋកិច្ច។ ក្នុងឆ្នាំ២០១៧ ការផ្ទេរប្រាក់ចូលជាផ្លូវការមកប្រទេសកម្ពុជាមាន៦%នៃផ.ស.ស. ដែលស្មើនឹង១ ២៧៦លានដុល្លារអាមេរិក។ ប្រជាជនពេញវ័យ៩%ទទួលប្រាក់ផ្ទេរពីក្រៅប្រទេស ជាពិសេសតាមច្រកទូទាត់ពាណិជ្ជកម្មថៃ។ ក្នុងការផ្ទេរប្រាក់ពីក្រៅប្រទេសមកកម្ពុជា៧៩%ត្រូវបានផ្ទេរតាមរយៈបណ្តាញផ្លូវការ និង២១%តាមរយៈបណ្តាញក្រៅផ្លូវការ[២៤]។

**២២- សេវាធានារ៉ាប់រង :** ចាប់តាំងពីវិស័យធានារ៉ាប់រងបានកកើតជិតពីរទសវត្សរ៍ ឧស្សាហកម្មនេះបានធ្វើប្រតិបត្តិការយ៉ាងស្វាហាប់ជាមួយសេវាធានារ៉ាប់រងមួយចំនួននៅលើការធានារ៉ាប់រងទូទៅ ធានារ៉ាប់រងអាយុជីវិត និងធានារ៉ាប់រងខ្នាតតូច ក្នុងនោះការប្រើប្រាស់ផលិតផលធានារ៉ាប់រងដែលមានលក្ខណៈសន្សំ (ផលិតផលធានារ៉ាប់រងទាយជ្ជទាន) មានប្រមាណ៩១% បើប្រៀបធៀបនឹងផលិតផលធានារ៉ាប់រងអាយុជីវិតទាំងអស់។

**រូបទី៣ : កម្រិតប្រើប្រាស់សេវាហិរញ្ញវត្ថុក្នុងទីផ្សារសេវាហិរញ្ញវត្ថុ៤ប្រភេទ(សេវាសន្សំ សេវាទូទាត់ សេវាឥណទាន និងសេវាធានារ៉ាប់រង)**



**២៣- ភាពស៊ីជម្រៅនៃការប្រើប្រាស់សេវាហិរញ្ញវត្ថុនៅមានកម្រិត** ៖ ភាគច្រើននៃប្រជាជនពេញវ័យប្រើប្រាស់សេវាហិរញ្ញវត្ថុ១ទៅ២ប្រភេទប៉ុណ្ណោះ។ តាមការវិភាគ ក្នុងចំណោមប្រជាជនដែលទទួលសេវាហិរញ្ញវត្ថុ ៥៩%ប្រើប្រាស់សេវាហិរញ្ញវត្ថុ១ប្រភេទ ៣៦%ប្រើប្រាស់សេវាហិរញ្ញវត្ថុ ២ប្រភេទ ១៣%ប្រើប្រាស់សេវាហិរញ្ញវត្ថុ៣ប្រភេទ និងមានតែ១%ប៉ុណ្ណោះ ប្រើប្រាស់សេវាហិរញ្ញវត្ថុទាំង៤ប្រភេទ។ ការណ៍នេះបង្ហាញថា មានតែប្រជាជនពេញវ័យមួយចំនួនតូចប៉ុណ្ណោះបានប្រើប្រាស់សេវាហិរញ្ញវត្ថុពេញលេញដើម្បីធ្វើឲ្យជីវភាពហិរញ្ញវត្ថុកាន់តែប្រសើរឡើង។ ក្រៅពីបណ្តាញផ្លូវការនិងក្រៅផ្លូវការ តម្រូវការសេវាហិរញ្ញវត្ថុត្រូវបានបំពេញបន្ថែម ដែលភាគច្រើនធ្វើឡើងជាសាច់ប្រាក់ ដូចជា ការសន្សំនិងឥណទានពីក្រុមគ្រួសារនិងមិត្តភក្តិ ដែលការណ៍នេះធ្វើឲ្យប៉ះពាល់ដល់ភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ។

**២៤- វិធានការទប់ស្កាត់បំណុលលើសលប់និងការពារក្រុមងាយរងគ្រោះ** ៖ តាមការសិក្សាលើស្ថានភាពបំណុលបង្ហាញថា អតិថិជនអាចមានលទ្ធភាពទទួលបានឥណទានពីច្រើនប្រភព មានន័យថា ប្រជាជនខ្លះអាចលាក់បាំងការជំពាក់បំណុលលើសលប់ ក្រោមរូបភាពជាការខ្ចីឥណទានមួយដើម្បីទូទាត់ឥណទានមួយផ្សេងទៀត។ ការទំនាក់ទំនងខ្ចីប្រាក់ពីអ្នកផ្តល់សេវាហិរញ្ញវត្ថុច្រើនជាង៣ ហើយមានការកើនឡើងនូវសំពៀតឥណទានដែលមានហានិភ័យ ជាសញ្ញាបង្ហាញពីបំណុលលើសលប់។ បុនហិរញ្ញប្បទានអាចដាក់បន្ទុកបន្ថែមផ្នែកហិរញ្ញវត្ថុទៅលើអ្នកខ្ចីដែលនឹងត្រូវសងបំណុលចាស់ និងខ្ចីឡើងវិញជាមួយនឹងការបង់ថ្លៃសេវាបន្ថែម។ ទោះបីពុំមានការរកឃើញណាមួយបញ្ជាក់អំពីការកេងចំណេញលើអ្នកខ្ចីក៏ដោយក៏មានសញ្ញាបង្ហាញពីបំណុលលើសលប់និងឥណទានមិនដំណើរការ។ ការណ៍នេះទាមទារឲ្យមានវិធានការប្រុងប្រយ័ត្នក្នុងការពង្រឹងប្រព័ន្ធរាយការណ៍ឥណទាន និងយន្តការវាយតម្លៃលទ្ធភាពទទួលបានកម្ចី ព្រមទាំងការរៀបចំយុទ្ធនាការផ្សព្វផ្សាយការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងយន្តការការពារអ្នកខ្ចីប្រាក់ឲ្យបានគ្រប់ជ្រុងជ្រោយ។

**២៥- ការទទួលបានសេវាហិរញ្ញវត្ថុ** ៖ ការទទួលបានសេវាហិរញ្ញវត្ថុដែលសមស្របតាមតម្រូវការ មានសារៈសំខាន់ណាស់ ដើម្បីធានាថាបុគ្គលនិងក្រុមគ្រួសារអាចគ្រប់គ្រងជីវភាពហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព។ ទោះបីជាមានភាពស្មុគស្មាញក៏ដោយ ការវាស់វែងពីកម្រិតនៃការប្រើប្រាស់សេវាហិរញ្ញវត្ថុដោយរួមបញ្ចូលទាំងសេវាក្រៅផ្លូវការពិតជាមានសារៈសំខាន់។ ការផ្តោតលើភាពស៊ីជម្រៅនៃការប្រើប្រាស់សេវាហិរញ្ញវត្ថុ នឹងជួយលើកកម្ពស់ការយល់ដឹងអំពីបរិយាបន្នហិរញ្ញវត្ថុ ដែលនឹងផ្តល់លទ្ធភាពឲ្យអ្នករៀបចំគោលនយោបាយ ក្នុងការកំណត់គោលដៅដែលត្រូវអនុវត្ត ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុបន្ថែមទៀត។

**២៦- ទីផ្សារគោលដៅចម្រុះនៃបរិយាបន្នហិរញ្ញវត្ថុ** ៖ ក្រុមកសិករ(៣៣%) និងក្រុមមានមុខរបរផ្ទាល់ខ្លួន(២០%) គឺជាទីផ្សារគោលដៅធំបំផុតនៅកម្ពុជា។ ទោះយ៉ាងណា ក្រុមមានមុខរបរផ្លូវការ(១១%នៃប្រជាជនពេញវ័យ) ដែលជាទីផ្សារគោលដៅតូច តែមានកម្រិតបរិយាបន្នខ្ពស់បំផុត(៨៨%) ហើយបន្ទាប់មកគឺក្រុមមានមុខរបរផ្ទាល់ខ្លួន(៨២%)។ ការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត មាន

ភាពប្រហាក់ប្រហែលគ្នានៅគ្រប់ទីផ្សារគោលដៅ លើកលែងតែក្រុមមានមុខរបរផ្លូវការប៉ុណ្ណោះ ដែលប្រើប្រាស់សេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត(៣២%) ទាបជាងទីផ្សារគោលដៅដទៃទៀត។ ក្រុមអ្នកនៅក្នុងបន្ទុក(១២%) និងក្រុមមានមុខរបរក្រៅផ្លូវការ(១០%)ប្រើប្រាស់សេវាហិរញ្ញវត្ថុពីគ្រួសារនិងមិត្តភក្តិច្រើនជាងគេ ក្នុងការគ្រប់គ្រងជីវភាពហិរញ្ញវត្ថុ(រូបទី៤)។

**រូបទី៤ : ចំណែកនៃការទទួលបានសេវាហិរញ្ញវត្ថុតាមទីផ្សារគោលដៅ**




ក្រុមកសិករគឺជាទីផ្សារគោលដៅដែលប្រើប្រាស់ឥណទានច្រើនជាងគេ មានកម្រិត៥១% តាមរយៈបណ្តាញផ្លូវការឬក្រៅផ្លូវការ។ ចំពោះការសន្សំ ក្រុមមានមុខរបរផ្លូវការមានកម្រិតបរិយាបន្នហិរញ្ញវត្ថុខ្ពស់ជាងគេ ដែលការសន្សំក្នុងបណ្តាញផ្លូវការឬក្រៅផ្លូវការ មានកម្រិត៥៩%។ ដូចគ្នាផងដែរ ក្រុមមានមុខរបរផ្លូវការគឺជាទីផ្សារគោលដៅដ៏សំខាន់ដែលប្រើប្រាស់បណ្តាញទូទាត់ឌីជីថល ក្នុងនោះ ៣៩%បានធ្វើប្រតិបត្តិការតាមរយៈបណ្តាញផ្លូវការ។ គួរកត់សម្គាល់ថា ចំណែកទីផ្សារនៃក្រុមអ្នកនៅក្នុងបន្ទុក មានកម្រិតបរិយាបន្នខ្ពស់(៥១%)ក្នុងការទទួលបានការផ្ទេរប្រាក់ចូលតាមរយៈបណ្តាញផ្លូវការនិងក្រៅផ្លូវការ ហើយចំពោះការផ្ទេរប្រាក់ចេញ ឃើញថាទីផ្សារគោលដៅនៃក្រុមមានមុខរបរផ្លូវការ(៣០%) ប្រើប្រាស់បណ្តាញផ្លូវការនិងក្រៅផ្លូវការច្រើនជាងគេ។

**ប្រអប់ទី២ : ចរិតលក្ខណៈទីផ្សារគោលដៅ**

ផ្អែកលើទស្សនវិស័យបរិយាបន្នហិរញ្ញវត្ថុ ការចាត់ថ្នាក់ប្រជាជនជាក្រុមទៅតាមទីផ្សារគោលដៅមានសារៈសំខាន់ក្នុងការជួយរាជរដ្ឋាភិបាល និងគ្រឹះស្ថានហិរញ្ញវត្ថុផ្តោតលើកិច្ចខិតខំប្រឹងប្រែង ការបែងចែកធនធានបានសមស្រប និងបង្កើនការយល់ដឹងឲ្យកាន់តែស៊ីជម្រៅ អំពីតម្រូវការហិរញ្ញវត្ថុរបស់ទីផ្សារគោលដៅនីមួយៗ។ ការកំណត់ទីផ្សារគោលដៅនិងចំណែកទីផ្សារ ត្រូវបានធ្វើឡើងដោយផ្អែកលើរបាយការណ៍ប្រភពចំណូលចម្បងរបស់ក្រុមប្រជាជន។ នេះជាជំហានកាលដ៏សំខាន់ក្នុងការស្វែងយល់អំពីតម្រូវការហិរញ្ញវត្ថុនិងភាពជាក់ស្តែងរបស់ក្រុមប្រជាជនដែលត្រូវបានបែងចែកជា៥ក្រុម រួមមានក្រុមមានមុខរបរផ្លូវការ ក្រុមមានមុខរបរក្រៅផ្លូវការ ក្រុមមានមុខរបរផ្ទាល់ខ្លួន ក្រុមកសិករ និងក្រុមអ្នកនៅក្នុងបន្ទុក។ តម្រូវការហិរញ្ញវត្ថុតាមទីផ្សារគោលដៅនីមួយៗ[៦] មានបង្ហាញ ដូចខាងក្រោម៖

| ប្រភេទទីផ្សារគោលដៅ | ចំនួនប៉ាន់ស្មាន | ចរិតលក្ខណៈ |
|---|---|---|
| ក្រុមមានមុខរបរផ្លូវការ | ១,១១ លាននាក់ | • ប្រភពចំណូលចម្បងគឺប្រាក់បៀវត្សរ៍ពីក្រុមហ៊ុនឯកជនឬស្ថាប័នរដ្ឋ<br>• មានប្រាក់ចំណូលជាមធ្យមខ្ពស់លំដាប់ទី១<br>• ភាគច្រើនរស់នៅតាមបណ្តាខេត្តនិងជនបទ<br>• ទទួលបានការសិក្សាខ្ពស់ជាងគេ<br>• ទទួលបានសេវាហិរញ្ញវត្ថុផ្លូវការច្រើនជាងគេ<br>• ភាគច្រើន(៧៤%) ប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ<br>• ប្រើប្រាស់សេវាផ្ទេរប្រាក់ចេញដ៏ចម្បង |
| ក្រុមមានមុខរបរក្រៅផ្លូវការ | ១,៥០ លាននាក់ | • ប្រភពចំណូលចម្បងគឺប្រាក់បៀវត្សរ៍និងប្រាក់ឈ្នួលពីក្រុមហ៊ុនក្រៅផ្លូវការនិងការងារមៅការ<br>• មិនបានប្រើប្រាស់សេវាហិរញ្ញវត្ថុច្រើនជាងគេ<br>• ភាគច្រើនប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ (៥១%)<br>• ការសិក្សាមានកម្រិតទាប<br>• ភាគច្រើនរស់នៅតាមជនបទ (៧៥%)<br>• បុរសមានចំនួនច្រើនជាងស្ត្រីបន្តិច |
| ក្រុមមានមុខរបរផ្ទាល់ខ្លួន | ២,០៣ លាននាក់ | • ប្រភពចំណូលចម្បងទទួលបានពីអាជីវកម្មផ្ទាល់ខ្លួន (សហគ្រាសធុនតូចនិងមធ្យម)<br>• មានប្រាក់ចំណូលជាមធ្យមខ្ពស់លំដាប់ទី២<br>• ប្រើទូរស័ព្ទដៃច្រើនជាងគេ<br>• ប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការច្រើនបង្គួរ (៦៣%) |
| ក្រុមកសិករ | ៣,២៨ លាននាក់ | • ប្រភពចំណូលចម្បងបានមកពីសកម្មភាពកសិកម្ម<br>• មានប្រាក់ចំណូលទាប |

| | | |
|---|---|---|
| | | • ភាគច្រើនរស់នៅតាមជនបទនិងមានកម្រិតសិក្សាទាប<br>• ៥៥% ប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ<br>• ៣៣% ពឹងផ្អែកលើការទទួលប្រាក់ផ្ញើ<br>• ភាគច្រើនសន្សំប្រាក់នៅក្នុងបណ្តាញក្រៅផ្លូវការ |
| ក្រុមអ្នកនៅក្នុងបន្ទុក | ១,០៤ លាននាក់ | • ប្រភពចំណូលចម្បងគឺការទទួលប្រាក់ផ្ញើ<br>• ទីផ្សារគោលដៅតូចជាងគេ<br>• ភាគច្រើនរស់នៅតាមជនបទ<br>• មានចំណូលទាបបំផុត<br>• ៦១% ប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ |

## III. ឧបសគ្គចំពោះបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា

### ឧបសគ្គក្នុងការទទួលបានសេវាហិរញ្ញវត្ថុ

២៧- **កង្វះមធ្យោបាយរូបវន្តជាឧបសគ្គចម្បងក្នុងការទទួលបានសេវាហិរញ្ញវត្ថុ** : ទោះបីជាចំនួនសាខាធនាគារបានបន្តកើនឡើងក្នុងឆ្នាំកន្លងទៅក្តី ប្រជាជនជាង៥២%ត្រូវចំណាយរយៈពេលច្រើនជាង៣០នាទីដើម្បីធ្វើដំណើរទៅកាន់គ្រឹះស្ថានផ្តល់សេវាហិរញ្ញវត្ថុផ្លូវការដែលនៅជិតបំផុត។ ទោះបីជាប្រជាជនប្រមូលផ្តុំនៅតំបន់ជនបទក៏ដោយ គ្រឹះស្ថានផ្តល់សេវាហិរញ្ញវត្ថុផ្លូវការភាគច្រើនបានដាក់ទីតាំងបណ្តាញចែកចាយតែនៅក្បែរផ្សារធំៗ នៅតាមទីក្រុងប៉ុណ្ណោះ និងកំពុងផ្តល់សេវាហិរញ្ញវត្ថុតាមរយៈសាខា ម៉ាស៊ីន ATM ម៉ាស៊ីន POS និងសេវាធនាគារអេឡិចត្រូនិកជាដើម។ ទោះជាយ៉ាងនេះក្តី ជាទូទៅក្រុមអតិថិជនដែលមានចំណូលទាបមិនមានលទ្ធភាពរ៉ាប់រងលើការចំណាយ និងមិនមានពេលវេលាក្នុងការធ្វើដំណើរផ្លូវឆ្ងាយដើម្បីទទួលបានសេវាហិរញ្ញវត្ថុទាំងនោះទេ។

២៨- **ប្រាក់ចំណូលកម្រិតទាបជាឧបសគ្គក្នុងការទទួលបានសេវាហិរញ្ញវត្ថុ** : ប្រជាជនពេញវ័យប្រមាណ៧៥% រកប្រាក់ចំណូលបានតិចជាង១លានរៀល (ប្រមាណ២៤៦ដុល្លារអាមេរិក) ក្នុងមួយខែ។ ប្រជាជនភាគច្រើនមានប្រាក់ចំណូលអាចប្រើប្រាស់បានទាប ដែលក្នុងនោះ ប្រមាណ២៩%ពុំមានប្រាក់ចំណូលទាល់តែសោះ។ ក្នុងចំណោម៤៤%នៃប្រជាជនពេញវ័យដែលសន្សំប្រាក់ មាន៦០%អាចរក្សាទុកប្រាក់សន្សំយូរបំផុតត្រឹមរយៈពេលមួយខែ ដែលបង្ហាញថា ប្រាក់សន្សំដែលបានរក្សាទុកមានបរិមាណតិចតួច។ ដូច្នេះ ប្រជាជនទាំងនេះមិនមានលទ្ធភាពប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការឡើយ ដោយសារសេវាហិរញ្ញវត្ថុភាគច្រើន ផ្តល់អត្ថប្រយោជន៍ច្រើនសម្រាប់តែប្រាក់បញ្ញើរយៈពេលវែងប៉ុណ្ណោះ។ ប្រជាជនពេញវ័យ១២% មិនអាចរក្សាសមតុល្យអប្បបរមានៅក្នុងគណនី ហើយ៨%យល់ថាគ្រឹះស្ថានធនាគារគិតកម្រៃសេវាហិរញ្ញវត្ថុថ្លៃពេក។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបានផ្តល់ការប្រាក់ខ្ពស់ ចំពោះសេវាប្រាក់បញ្ញើ

មានកាលកំណត់រយៈពេលវែង ក៏ប៉ុន្តែការប្រមូលប្រាក់សន្សំតូចៗសម្រាប់រយៈពេលវែង និងការផ្តល់ការប្រាក់ខ្ពស់លើប្រាក់សន្សំទាំងនេះនៅតែជាបញ្ហាប្រឈមរបស់គ្រឹះស្ថាន[៣៧]។

**២៩- កង្វះលទ្ធភាពបំពេញតាមលក្ខខណ្ឌជាឧបសគ្គក្នុងការទទួលបានសេវាហិរញ្ញវត្ថុ :** ក្រុមមានមុខរបរក្រៅផ្លូវការនិងប្រជាជនគ្មានការងារធ្វើ ជាទូទៅ មិនអាចបញ្ជាក់ពីលទ្ធភាពសងប្រាក់ ឬផ្តល់ឯកសារភស្តុតាងអំពីប្រាក់ចំណូល ដើម្បីស្នើសុំឥណទានពីគ្រឹះស្ថានផ្តល់សេវាហិរញ្ញវត្ថុផ្លូវការឡើយ។ ម្យ៉ាងទៀត គ្រឹះស្ថានផ្តល់សេវាហិរញ្ញវត្ថុផ្លូវការក៏ទាមទារឲ្យមានការដាក់ទ្រព្យធានានៅពេលស្នើសុំឥណទាន ហើយគ្រឹះស្ថាននឹងបដិសេធផ្តល់ឥណទាន នៅពេលដែលអ្នកស្នើសុំឥណទានមិនមានលទ្ធភាពផ្តល់ទ្រព្យធានា ឬការធានាគ្រប់គ្រាន់។

**៣០- លទ្ធភាពទទួលបានផលិតផលធានារ៉ាប់រងនិងបណ្តាញចែកចាយផលិតផល :** ក្រុមហ៊ុនធានារ៉ាប់រងមានប្រតិបត្តិការអាជីវកម្មធានារ៉ាប់រងតែនៅភ្នំពេញនិងបានពង្រីកនៅតាមសាខាមួយចំនួនដែលជាតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ចប៉ុណ្ណោះ ហើយការបើកសាខានេះ មានត្រឹមតែការធានារ៉ាប់រងទូទៅ និងអាយុជីវិត។ រីឯការចែកចាយផលិតផលធានារ៉ាប់រងតាមរយៈអន្តរការីយធានារ៉ាប់រង នៅមានកម្រិតផងដែរ ព្រោះថា ការកម្រិតកិច្ចប្រតិបត្តិការរបស់ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រឹមតែជាភ្នាក់ងារណែនាំអតិថិជន ធ្វើឲ្យក្រុមហ៊ុនធានារ៉ាប់រងនីមួយៗត្រូវចំណាយខ្ពស់ក្នុងការដាក់បុគ្គលិកផ្នែកលក់របស់ក្រុមហ៊ុន នៅតាមទីតាំងសាខារបស់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ យន្តការនេះមិនបានផ្តល់កាលានុវត្តភាពដល់ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចសម្រាប់អនុវត្តឡើយ។ រីឯការចែកចាយផលិតផលធានារ៉ាប់រងតាមប្រព័ន្ធអេឡិចត្រូនិក គឺស្ថិតនៅក្នុងទម្រង់សាកល្បងដែរនិងដាក់ឲ្យស្ថិតនៅក្នុងការអនុវត្តជាភ្នាក់ងារធានារ៉ាប់រង។ ដោយឡែកចំពោះការលក់សេវាធានារ៉ាប់រងតាមប្រព័ន្ធអេឡិចត្រូនិកមិនទាន់មានក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងនៅឡើយ។

**ឧបសគ្គក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុ**

**៣១- សេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការមិនបានឆ្លើយតបពេញលេញ តាមតម្រូវការរបស់អតិថិជន :** គុណប្រយោជន៍នៃសេវាហិរញ្ញវត្ថុផ្លូវការមិនស្របតាមតម្រូវការរបស់ប្រជាជនពេញវ័យទាំងស្រុងទេ ហើយបច្ចុប្បន្នប្រជាជនដែលមិនបានទទួលសេវាហិរញ្ញវត្ថុពីគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការមួយចំនួន កំពុងប្រើប្រាស់បណ្តាញក្រៅផ្លូវការ ឬមិនប្រើប្រាស់សេវាហិរញ្ញវត្ថុតែម្តង។ ចំពោះការសន្សំ ការលំបាកក្នុងការធ្វើដំណើរជាពិសេស នៅទីជនបទ ធ្វើឲ្យប្រជាជនមួយភាគធំ(៧៦%)ចូលចិត្តសន្សំប្រាក់នៅផ្ទះ ឬជាមួយអ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ។ នៅប្រទេសកម្ពុជា អត្រាគណនីមិនដំណើរការ (គ្មានសកម្មភាពប្រតិបត្តិការក្នុងរយៈពេលពេញមួយឆ្នាំ) មានរហូតដល់២០%ក្នុងឆ្នាំ២០១៤ កើនឡើងគួរឲ្យកត់សម្គាល់ពី៨%ក្នុងឆ្នាំ២០១១។ ទន្ទឹមនេះ ចំនួនគណនីដែលមានប្រតិបត្តិការ(លើសពី៣ដងក្នុងមួយខែ) បានថយចុះពី២១%ក្នុងឆ្នាំ២០១១ មក ១៨%ក្នុងឆ្នាំ២០១៤។ គណនីប្រមាណ៦២%ត្រូវបានប្រើប្រាស់ដូចប្រអប់សំបុត្រ ដែលមានប្រតិបត្តិការ

ជាមធ្យមពី១ដងទៅ២ដងក្នុងមួយខែ ដូច្នេះគណនីធនាគារភាគច្រើនត្រូវបានប្រើប្រាស់ដើម្បីទទួលប្រាក់ និងដកប្រាក់វិញភ្លាមៗស្ទើរតែទាំងអស់។ មិនតែប៉ុណ្ណោះ របបពន្ធលើបុព្វលាភធានារ៉ាប់រងមិនលើកទឹកចិត្តដល់អ្នកប្រើប្រាស់ និងអ្នកផ្តល់សេវាធានារ៉ាប់រង លើកលែងតែចំពោះរបបពន្ធលើការធានារ៉ាប់រងអាយុជីវិតដែលបានកែសម្រួលនៅក្នុងឆ្នាំ២០១៨។ ក្នុងចំណោមផលិតផលធានារ៉ាប់រងជាច្រើនដែលមាននៅលើទីផ្សារនេះ នៅមិនទាន់បានឆ្លើយតបទាំងស្រុងតាមតម្រូវការជាក់ស្តែងរបស់អតិថិជននៅឡើយទេ ដូចជា ផលិតផលធានារ៉ាប់រងលើដំណាំកសិកម្ម ធានារ៉ាប់រងលើចម្ការកៅស៊ូ ធានារ៉ាប់រងលើអាកាសធាតុ និងធានារ៉ាប់រងលើការចិញ្ចឹមសត្វ។ រីឯការធានារ៉ាប់រងជាកាតព្វកិច្ចយានយន្តឯកជន និងការចូលរួមលើការជំរុញឲ្យអនុវត្តលើការធានារ៉ាប់រងជាកាតព្វកិច្ចផ្សេងៗទៀត នៅមិនទាន់បានដាក់ឲ្យអនុវត្ត។

៣២- **ការយល់ដឹងនិងចំណេះដឹងផ្នែកហិរញ្ញវត្ថុនៅមានកម្រិតជាឧបសគ្គចម្បង** : លទ្ធភាពទទួលបានព័ត៌មានអំពីសេវាហិរញ្ញវត្ថុជាកត្តាសំខាន់សម្រាប់ការប្រើប្រាស់សេវាហិរញ្ញវត្ថុឲ្យមានប្រសិទ្ធភាព។ នៅកម្ពុជាការយល់ដឹងផ្នែកហិរញ្ញវត្ថុមានអត្រា១៨% ស្ថិតក្នុងចំណាត់ថ្នាក់ទី១៣៥ក្នុងចំណោម១៤៤ប្រទេស ដែលបង្ហាញថាប្រជាជនមួយភាគធំមានលទ្ធភាពតិចតួចក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុ[២៨]។

៣៣- **ការបារម្ភចំពោះការជំពាក់បំណុល** : ប្រជាជនពេញវ័យដែលមិនបានប្រើប្រាស់សេវាឥណទានមាន ៥៨% ក្នុងនោះ ៦២%ភ័យខ្លាចការជំពាក់បំណុល ៨%ចៀសវាងការខ្ចីប្រាក់ដោយមិនចង់ឲ្យគេដឹងនៅពេលខកខានសង និង៧%យល់ថាការខ្ចីប្រាក់គឺជារឿងគួរឲ្យអាម៉ាស់។ ការខ្មាសអៀនចំពោះការខ្ចីប្រាក់នៅក្នុងសង្គម បានក្លាយជាឧបសគ្គចំពោះប្រជាជនដែលមានតម្រូវការប្រើប្រាស់ឥណទាន ដើម្បីចាត់ចែងជីវភាពហិរញ្ញវត្ថុ។

## IV. កត្តាជំរុញទីផ្សារ

### កត្តាជំរុញទីផ្សារដែលមានឥទ្ធិពលលើបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា

៣៤- **គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀតគ្របដណ្តប់ទីផ្សារ** : ទោះបីជាគ្រឹះស្ថានធនាគារមានចំនួនច្រើន និងមានទំហំធំក៏ដោយ ក៏គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀតគ្របដណ្តប់ទីផ្សារសេវាហិរញ្ញវត្ថុរាយ។ ប្រជាជនពេញវ័យ ៥២% ប្រើប្រាស់សេវាហិរញ្ញវត្ថុ តាមរយៈបណ្តាញផ្លូវការផ្សេងទៀត ដែលធ្វើឲ្យបណ្តាញនេះមានការប្រើប្រាស់ច្រើនបំផុត[២៩]។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានគ្របដណ្តប់ទីផ្សារនិងបានពង្រីកបណ្តាញបម្រើសេវាហិរញ្ញវត្ថុក្នុងអត្រាកំណើនសាខាប្រមាណ០,៤%ក្នុងឆ្នាំ២០១៨។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកំពុងក្លាយជាអ្នកផ្តល់ប្រភពទុនដ៏សំខាន់ និងជាជម្រើសមួយ ជំនួសឲ្យអ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការដែលគិតការប្រាក់ខ្ពស់។ ចំពោះសេវាទូទាត់សងប្រាក់ បណ្តាញផ្លូវការផ្សេងទៀតដែលមានទម្រង់ជាការទូទាត់ចល័ត កំពុងស្រូបយកចំណែកទីផ្សារកាន់តែច្រើន ដោយសារការកើនឡើងនូវចំនួនប្រជាជនប្រើប្រាស់ការទូទាត់ចល័តសម្រាប់ធ្វើប្រតិបត្តិការនិងផ្ទេរប្រាក់។ ជាក់ស្តែង ទំហំនៃការទូទាត់

តាមរយៈអ្នកផ្តល់សេវាទូទាត់ក្នុងស្រុកបានកើនឡើងប្រមាណ៣០,២៣%ពី៤,៨ប៊ីលានដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ ដល់៦,៨៨ប៊ីលានដុល្លារអាមេរិកក្នុងឆ្នាំ២០១៨ ដែលក្នុងរយៈពេលដូចគ្នានេះ ប្រតិបត្តិការតាមរយៈគ្រឹះស្ថានធនាគារបានកើនឡើង២២,៦៣% ពី១២,១ប៊ីលានដុល្លារអាមេរិកដល់១៥,៦៤ប៊ីលានដុល្លារអាមេរិក។ ក្រៅពីនេះ អាជីវកម្មទទួលបញ្ញើនិងប្រាតិភោគដោយអនុប្បទាន ក៏បានគ្របដណ្តប់នៅតាមបណ្តាខេត្តនានា ជាពិសេស ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានធ្វើប្រតិភូកម្ម ជូនដល់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានីខេត្ត ដែលជាសេនាធិការ ដើម្បីគ្រប់គ្រង តាមដាន ត្រួតពិនិត្យ ក្នុងទិសដៅពង្រឹងនិងពង្រីកវិសាលភាពនៃការផ្តល់សេវាហិរញ្ញវត្ថុជូនដល់ប្រជាជន និងអ្នកដាក់ទ្រព្យបញ្ចាំឬអ្នកដាក់ប្រាតិភោគដោយអនុប្បទាន។

៣៥- **អ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ** : ក្រុមអ្នកសន្សំនិងផ្តល់ឥណទានជាច្រើន ដូចជា សមាគមសន្សំនិងកម្ចីតាមភូមិ តុងទីន និងអ្នកឲ្យខ្ចីចងការក្នុងស្រុក សុទ្ធសឹងជាអ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការនៅកម្ពុជា។ ប្រជាជនពេញវ័យប្រមាណ១២%ប្រើប្រាស់បណ្តាញក្រៅផ្លូវការក្នុងការគ្រប់គ្រងជីវភាពហិរញ្ញវត្ថុ។ បើពិនិត្យលើភាពត្រួតគ្នា ប្រជាជនពេញវ័យដល់ទៅ៣៤%ប្រើប្រាស់បណ្តាញក្រៅផ្លូវការ។ ការខ្ចីតាមបណ្តាញក្រៅផ្លូវការមានភាពទូលំទូលាយនៅកម្ពុជានិងជាជម្រើសមួយផ្សេងទៀតដ៏សំខាន់ក្នុងការទទួលបានសេវាហិរញ្ញវត្ថុ។ ក្រុមកសិករជាច្រើនពឹងផ្អែកលើកម្ចីក្រៅផ្លូវការនិងអ្នកឲ្យខ្ចីចងការឯកជននៅតាមភូមិ។ ទន្ទឹមនឹងនេះ ការសន្សំតាមរយៈតុងទីនជាវិធីពេញនិយម ដែលការសន្សំត្រូវបានប្រមូលជាកញ្ចប់ ហើយសមាជិកក្រុមអាចដេញថ្លៃការប្រាក់ដើម្បីទទួលបានកម្ចីម្តងម្នាក់[៣០]។

៣៦- **គ្រឹះស្ថានហិរញ្ញវត្ថុជាច្រើនកាន់កាប់ដោយភាគទុនិកបរទេស** : គិតត្រឹមឆ្នាំ២០១៨ ប្រទេសកម្ពុជាមានគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការជាច្រើន រួមមាន ធនាគារពាណិជ្ជចំនួន៤៣ ធនាគារឯកទេសចំនួន១៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៨១ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន១៥ និងអាជីវកម្មទទួលបញ្ញើនិងប្រាតិភោគដោយអនុប្បទានចំនួន១១២។ ដើមទុនចុះបញ្ជីសរុបរបស់គ្រឹះស្ថានធនាគារកាន់កាប់ដោយភាគទុនិកបរទេសមាន៧៤,៣%និងភាគទុនិកក្នុងស្រុក២៥,៧%។ ការកាន់កាប់ភាគហ៊ុននៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏មានលក្ខណៈស្រដៀងគ្នា ដែល៧៥,៦% ជាដើមទុនវិនិយោគពីបរទេស។

៣៧- **ស្ថិរភាពវិស័យធនាគារជំរុញកំណើនសេដ្ឋកិច្ច** : វិស័យធនាគារនៅកម្ពុជាកំពុងមានកំណើនខ្ពស់ដោយសារទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារបន្តកើនឡើងគួរឲ្យកត់សម្គាល់ ហើយបរិយាបន្នហិរញ្ញវត្ថុកាន់តែមានវិសាលភាព។ សម្រាប់រយៈពេល១២ខែ គិតត្រឹមខែធ្នូ ឆ្នាំ២០១៨ ទ្រព្យសកម្មសរុបរបស់គ្រឹះស្ថានធនាគារកើនឡើងចំនួន២១,៤% ដើមទុនភាគទុនិកកើនឡើងចំនួន២៣,១% កម្ចីពីប្រភពផ្សេងៗថយចុះចំនួន១៤,៤% និងប្រាក់បញ្ញើកើនឡើងចំនួន២៧,៩%។ ស្របជាមួយគ្នានេះ អតិថិជនដាក់ប្រាក់បញ្ញើមានចំនួន៤,២លាននាក់ កើនឡើងចំនួន២០,៩%និងអតិថិជនខ្ចីប្រាក់មានចំនួន០,៨លាននាក់កើនឡើងចំនួន៧,៥%។ សាខារបស់គ្រឹះស្ថានធនាគារ(គិតទាំងធនាគារឯកទេស)បានកើនដល់ចំនួន៩០៦ និងម៉ាស៊ីន ATM បានកើនដល់ចំនួន១ ៨១៨។ ទិដ្ឋភាពរួមរបស់វិស័យធនាគារមានស្ថិរភាព ដែល

ផ្លុះបញ្ចាំងដោយដើមទុនអប្បបរមាខ្ពស់និងសូចនាករសំខាន់ៗ ដូចជា អនុបាតសទ្ធនីយភាពខ្ពស់ក្នុងប្រព័ន្ធធនាគារ (គ្រឹះស្ថានធនាគារ១៥៨,៨% និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ២១៣,៦%) អនុបាតសាធនភាពខ្ពស់ (គ្រឹះស្ថានធនាគារ២៤,២% និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ១៩,៨%) និងអនុបាតទ្រព្យសកម្មមិនដំណើរការមានកម្រិតទាប (គ្រឹះស្ថានធនាគារ២,២% និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ១,៣%)។

**៣៨- ការបង្កើនដើមទុនចុះបញ្ជីអប្បបរមាជួយគាំទ្រដល់ការពង្រីកដែនសេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានធនាគារ** : ការបង្កើនដើមទុនចុះបញ្ជីអប្បបរមាអាចជួយជំរុញដល់ការច្របាច់បញ្ចូលគ្នារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនិងបង្កើនការប្រកួតប្រជែង។ ការកើនឡើងនូវការប្រកួតប្រជែងនិងការថយចុះប្រាក់ចំណេញនឹងជំរុញឲ្យគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការស្វែងរកទីផ្សារថ្មីនិងពង្រីកដែនសេវាហិរញ្ញវត្ថុរបស់ខ្លួនទៅតំបន់នៅក្រៅទីក្រុង។ ការច្របាច់បញ្ចូលគ្នានឹងធ្វើឲ្យគ្រឹះស្ថានធនាគារមានទំហំធំជាងមុន ដោយផ្តោតការផ្តល់សេវាហិរញ្ញវត្ថុជាចម្បងទៅលើក្រុមហ៊ុន និងអតិថិជនមានទ្រព្យធនច្រើន ហើយអតិថិជនតូចៗអាចនឹងលែងជាអាទិភាព។

**៣៩- គ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការបានពង្រីកដែនសេវាយ៉ាងឆាប់រហ័ស** : គ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការនៅកម្ពុជា កំពុងពង្រីកបណ្តាញផ្តល់សេវាហិរញ្ញវត្ថុដោយបានបើកសាខានិងការិយាល័យតំណាងថ្មីៗជាបន្តបន្ទាប់ ទាំងក្នុងរាជធានីនិងតាមបណ្តាខេត្ត។ នៅឆ្នាំ២០១៨ ធនាគារពាណិជ្ជមានសាខាសរុបចំនួន ៨៧៦ ហើយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានសាខាសរុបចំនួន១ ៩២៣។ ខណៈដែលធនាគារពាណិជ្ជផ្តោតលើការបើកសាខានៅរាជធានីភ្នំពេញនិងតាមទីប្រជុំជនធំៗ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានពង្រីកដែនសេវានៅតំបន់ដាច់ស្រយាល។ បន្ថែមលើការបើកសាខារបស់គ្រឹះស្ថានធនាគារជាប្រពៃណី គ្រឹះស្ថានធនាគារបានដាក់ឲ្យប្រើប្រាស់ម៉ាស៊ីន ATM ចំនួន១ ៨១៨ ម៉ាស៊ីន POS ចំនួន១៥ ៩៧៦ សេវាធនាគារតាមអ៊ិនធឺណិតនិងសេវាធនាគារចល័ត ដើម្បីពង្រីកសេវាហិរញ្ញវត្ថុក្នុងប្រទេស។ ភ្នាក់ងារផ្តល់សេវាតាមទូរស័ព្ទចល័តសរុបក្នុងឆ្នាំ២០១៨ មានចំនួន៣៤ ៩៤៩ ដែលជាមធ្យម ភ្នាក់ងារមួយអាចផ្តល់សេវាឲ្យប្រជាជនពេញវ័យចំនួន៣៥៦នាក់។ ទន្ទឹមនេះ បណ្តាញផ្តល់សេវាហិរញ្ញវត្ថុដែលប្រើបច្ចេកវិទ្យាហិរញ្ញវត្ថុកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍដំបូងនៅឡើយ។

**៤០- ច្បាប់និងបទប្បញ្ញត្តិក្នុងវិស័យធនាគារ** : វិស័យធនាគារនៅកម្ពុជា ត្រូវបានគ្រប់គ្រងយ៉ាងទូលំទូលាយដោយច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា(ឆ្នាំ១៩៩៦) ច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់(ឆ្នាំ១៩៩៧) ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ(ឆ្នាំ១៩៩៩) ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់(ឆ្នាំ២០០៥) និងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម(ឆ្នាំ២០០៧)។ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាអនុញ្ញាតឲ្យអ្នកប្រើប្រាស់អាចធ្វើប្រតិបត្តិការដែលមានកិច្ចធានា តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងពាណិជ្ជកម្ម។ ប៉ុន្តែការប្រើប្រាស់ពុំទាន់បានទូលំទូលាយនៅឡើយ ដោយការចូលរួមអនុវត្តពីសំណាក់វិស័យឯកជន និងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត។ ច្បាប់មួយចំនួន រួមទាំងច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានចែងអំពីកិច្ចការពារ

អតិថិជន។ ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ច្បាប់ស្តីពីបរធនបាលកិច្ច និងច្បាប់ស្តីពីការប្រកួតប្រជែង គឺជាគន្លឹះដ៏សំខាន់ក្នុងការបង្កើតយន្តការសម្រាប់ការពារអតិថិជន។ ទោះយ៉ាងណាការរៀបចំសេចក្តីព្រាងបទប្បញ្ញត្តិមួយចំនួនទៀត គឺជាតម្រូវការចាំបាច់ដើម្បីគ្រប់គ្រងវិស័យធនាគារ។ ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចែងថា ប្រតិបត្តិការធនាគាររួមបញ្ចូលផងដែរនូវប្រព្រឹត្តិកម្ម និងការដាក់ឲ្យអតិថិជនប្រើប្រាស់នូវមធ្យោបាយទូទាត់ជារូបិយវត្ថុ ឬជារូបិយបណ្ណ។ បច្ចុប្បន្ន ប្រកាសគ្រប់គ្រងគ្រឹះស្ថាននិងប្រតិបត្តិករទូរស័ព្ទចល័តដែលផ្តល់សេវាទូទាត់ មានប្រកាសស្តីពីអ្នកដំណើរការតតិយភាគី និងប្រកាសស្តីពីការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។ ការរៀបចំបទប្បញ្ញត្តិសម្រាប់ប្រតិបត្តិករទូរស័ព្ទចល័តដែលផ្តល់សេវាទូទាត់សងប្រាក់គួរត្រូវបានពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីចៀសវាងបញ្ហាខ្វាស់គ្នានៃបទប្បញ្ញត្តិ។

**៩១- ការប្រើប្រាស់ប្រភេទសេវាហិរញ្ញវត្ថុផ្លូវការមានកម្រិតមធ្យម :** ប្រជាជនពេញវ័យ៣៦%ប្រើប្រាស់សេវាហិរញ្ញវត្ថុតែមួយប្រភេទប៉ុណ្ណោះ ក្នុងនោះ ១៨%ប្រើប្រាស់តែឧបករណ៍ទូទាត់សងប្រាក់ដែលធ្វើឲ្យឧបករណ៍នេះក្លាយជាផលិតផលប្រើប្រាស់ដ៏ពេញនិយមបំផុត។ ប្រជាជនពេញវ័យ១០%ប្រើប្រាស់សេវាសន្សំនិងសេវាទូទាត់ ប៉ុន្តែមានតែ១%ដែលប្រើប្រាស់គ្រប់សេវាហិរញ្ញវត្ថុទាំង៤ប្រភេទ។

**៩២- ការអភិវឌ្ឍសេវាធានារ៉ាប់រង :** ផលិតផលធានារ៉ាប់រងដែលមាននៅក្នុងទីផ្សារបច្ចុប្បន្ន រួមមានផលិតផលធានារ៉ាប់រងទូទៅដែលផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងទូទៅ មានដូចជា ការធានារ៉ាប់រងអគ្គិភ័យ ការធានារ៉ាប់រងសុខភាព ការធានារ៉ាប់រងលើអគារនិងសំណង់ ការធានារ៉ាប់រងជាកាតព្វកិច្ច និងការធានារ៉ាប់រងផ្សេងៗទៀត។ ផលិតផលធានារ៉ាប់រងអាយុជីវិតដែលផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត មានដូចជា ការធានារ៉ាប់រងទាយជ្ជទាន ការធានារ៉ាប់រងជីវិតមានកាលកំណត់ ការធានារ៉ាប់រងមួយជីវិតកាល និងការធានារ៉ាប់រងធនលាភ។ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច សម្រាប់កិច្ចសន្យាធានារ៉ាប់រងដែលមានទំហំតូចៗ ដូចជា ការធានារ៉ាប់រងសុខភាពខ្នាតតូច គ្រោះថ្នាក់បុគ្គលខ្នាតតូច ការធានារ៉ាប់រងអាយុជីវិតមានកាលកំណត់ខ្នាតតូច និងការធានារ៉ាប់រងឥណទានខ្នាតតូច។

**៩៣- ការលើកកម្ពស់ការយល់ដឹងនិងការចែកចាយផលិតផលធានារ៉ាប់រង :** ក្រុមហ៊ុនធានារ៉ាប់រងបានផ្សព្វផ្សាយផលិតផលធានារ៉ាប់រង តាមរយៈការផ្សព្វផ្សាយពាណិជ្ជកម្ម តាមប្រព័ន្ធផ្សព្វផ្សាយ កម្មវិធីសង្គម និងតាមរយៈសិក្ខាសាលាផ្សេងៗ។ ក្នុងនោះដែរ នាយកដ្ឋានធានារ៉ាប់រងបានសហការជាមួយសមាគមធានារ៉ាប់រង ដោយបានរៀបចំកម្មវិធីសិក្ខាសាលានៅតាមបណ្តាខេត្តមួយចំនួន ដើម្បីជាការបញ្ជ្រាបចំណេះដឹងស្តីពីការធានារ៉ាប់រងដល់អាជ្ញាធរមូលដ្ឋាន និងភាគីពាក់ព័ន្ធផ្សេងៗទៀត។ ក្រុមហ៊ុនធានារ៉ាប់រងបានប្រើប្រាស់បណ្តាញចែកចាយផលិតផលធានារ៉ាប់រងរបស់ខ្លួន តាមរយៈមធ្យោបាយមួយចំនួន ដូចជា បុគ្គលិកផ្នែកលក់របស់ក្រុមហ៊ុន ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងតាមរយៈភ្នាក់ងារធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនានា ការលក់តាមប្រព័ន្ធអេឡិចត្រូនិក ជាដើម។

**៩៥- វិស័យទទួលបញ្ចាំនិងទទួលប្រាតិភោគដោយអនុប្បទាន** : ការគ្រប់គ្រងលើវិស័យទទួលបញ្ចាំនិងទទួលប្រាតិភោគដោយអនុប្បទានត្រូវបានចាប់ផ្តើមតាំងពីឆ្នាំ២០១០ តាមរយៈប្រកាសលេខ០២៨ សហវ.ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១០ និងត្រូវបានកែសម្រួលទៅជាប្រកាសលេខ០៣០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំនិងទទួលប្រាតិភោគដោយអនុប្បទាន ក្នុងទិសដៅកំណត់យន្តការ វិធាន និងនីតិវិធីនៃការគ្រប់គ្រង ត្រួតពិនិត្យលើប្រតិបត្តិការអាជីវកម្មទទួលបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន។ ជាមួយគ្នានេះ កត្តាជំរុញទីផ្សារឲ្យបានម៉ឺងម៉ាត់ និយ័តករមានយន្តការផ្សេងទៀត ដូចខាងក្រោម៖

- រៀបចំច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ
- រៀបចំផែនការត្រួតពិនិត្យទាំងលើឯកសារនិងដល់ទីកន្លែងចំពោះក្រុមហ៊ុន សហគ្រាស អាជីវកម្មទទួលបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន សំដៅធានាឲ្យបាននូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព
- បង្កើនការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំនិងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូច តាមរយៈការធ្វើប្រតិភូកម្មជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្តជាអ្នកគ្រប់គ្រងជំនួស និង
- បន្តកិច្ចសហការជាមួយក្រសួងមហាផ្ទៃនិងអាជ្ញាធរពាក់ព័ន្ធដើម្បីកៀរគរនិងចាត់វិធានការទប់ស្កាត់សកម្មភាពអាជីវកម្មខុសច្បាប់។

# ជំពូក៣
# ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា

## I. ទីផ្សារគោលដៅ

**៩៥- ប្រភេទទីផ្សារគោលដៅ :** ការកំណត់អំពីតម្រូវការសម្រាប់ប្រភេទទីផ្សារគោលដៅទាំង៥មានបង្ហាញក្នុងតារាងទី១។ ការកំណត់អំពីតម្រូវការសម្រាប់គោលដៅនីមួយៗមានលក្ខណៈពិសេសជាក់លាក់និងផ្អែកលើការវាយតម្លៃអំពីការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនិងការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ។

**តារាងទី១ : តម្រូវការសេវាហិរញ្ញវត្ថុតាមប្រភេទទីផ្សារគោលដៅ**

| ប្រភេទទីផ្សារគោលដៅ | ការកំណត់អំពីតម្រូវការ |
|---|---|
| ក្រុមមានមុខរបរផ្លូវការ | • គណនីសម្រាប់ប្រតិបត្តិការទទួលប្រាក់បៀវត្សរ៍ដែលមានតម្លៃទាបសមរម្យនិងអាចធ្វើប្រតិបត្តិការឌីជីថល(ប្រតិបត្តិការធនាគារតាមប្រព័ន្ធអ៊ិនធឺណិតនិងទូរស័ព្ទចល័ត)។ គណនីទាំងនោះជាធម្មតាមិនមានកម្រៃសេវាប្រចាំឆ្នាំ និងមានសមតុល្យអប្បបរមាស្មើសូន្យ។ គណនីទាំងនេះផ្តល់លទ្ធភាពឲ្យអតិថិជនអាចធ្វើប្រតិបត្តិការឌីជីថល ដូចជាការបញ្ចូលទឹកប្រាក់ទូរស័ព្ទ ការផ្ទេរប្រាក់ ការទូទាត់វិក្កយបត្រទឹក/ភ្លើង និងការទូទាត់រាយជាមួយពាណិជ្ជករ។<br>• ប្រព័ន្ធការពារប្រាក់បញ្ញើ ដើម្បីជំរុញការកៀរគរប្រាក់សន្សំ។<br>• ភាពងាយស្រួលនៃការប្រើប្រាស់ និងការយល់ដឹងអំពីគណនីប្រាក់សន្សំទៀងទាត់ដែលជាផែនការសន្សំរយៈពេលវែងនឹងលើកទឹកចិត្តការសន្សំប្រកបដោយវិន័យ។<br>• សេវាហិរញ្ញវត្ថុជាកញ្ចប់ដែលអនុញ្ញាតឲ្យអតិថិជនសន្សំ (ដោយមានការប្រាក់ខ្ពស់ជាងធម្មតាបន្តិច ឬការប្រាក់ត្រូវគិតលើសមតុល្យអប្បបរមាប្រចាំថ្ងៃ) ធ្វើប្រតិបត្តិការទូទាត់ (តាមប្រព័ន្ធអនឡាញនិងតាមទូរស័ព្ទចល័ត) និងទទួលបានឥណទាន (ដោយផ្អែកលើសមតុល្យជាមធ្យមក្នុងគណនីនិងប្រវត្តិប្រាក់ចំណូល) ។<br>• សេវាធានារ៉ាប់រងសុខភាពនិងអាយុជីវិត ដែលមានតម្លៃសមរម្យ។ |
| ក្រុមមានមុខរបរក្រៅផ្លូវការ | • ភាពងាយស្រួលនៃការប្រើប្រាស់និងការយល់ដឹងអំពីសេវាសន្សំតូចៗដែលមានភាពបត់បែន ដើម្បីសម្រួលការសន្សំរបស់អ្នកមានចំណូលមិនទៀងទាត់និងតាមចំណាយនាពេលអនាគត។ |

| | |
|---|---|
| | • សេវាផ្ទេរប្រាក់ដែលងាយស្រួលប្រើប្រាស់និងមានតម្លៃទាបសមរម្យ ជំរុញការសន្សំ និងផ្តល់លទ្ធភាពដល់ការខ្ចីប្រាក់ដែលផ្អែកលើការសន្សំ[៣១]។<br>• សេវាហិរញ្ញវត្ថុសម្រាប់ជួយសម្រួលការពង្រឹងសមត្ថភាពជំនាញ ដើម្បីបង្កើនផលិតភាព និងជីវភាពរបស់អតិថិជន។ |
| ក្រុមមានមុខរបរផ្ទាល់ខ្លួន | • ដើមទុនសម្រាប់វិនិយោគក្នុងអាជីវកម្ម។<br>• ភាពងាយស្រួលនិងអំណោយផលក្នុងការប្រើប្រាស់សេវាសន្សំ។<br>• ប្រព័ន្ធទូទាត់ឌីជីថលដែលមានតម្លៃទាបសមរម្យនិងងាយស្រួលប្រើប្រាស់។<br>• ផលិតផលធានារ៉ាប់រងដែលមានតម្លៃទាប ដើម្បីជួយកាត់បន្ថយហានិភ័យក្នុងក្រុមគ្រួសារ និងអាជីវកម្ម ជាពិសេស ផលិតផលដែលកាត់បន្ថយហានិភ័យចំពោះមេគ្រួសារ។<br>• សេវាហិរញ្ញវត្ថុសម្រាប់ជួយសម្រួលការពង្រឹងសមត្ថភាពជំនាញ ដើម្បីបង្កើនផលិតភាព និងជីវភាពរបស់អតិថិជន។ |
| ក្រុមកសិករ | • ឥណទានកសិកម្មដែលមានជម្រើសក្នុងការទូទាត់សង សមស្របទៅនឹងចំណូលតាមរដូវកាល រួមទាំងដំណាំតាមកិច្ចសន្យា។<br>• ការសន្សំមានភាពបត់បែននិងចំណាយទាបដែលអាចសម្រួលដល់ការចាយវាយត្រឹមត្រូវដើម្បីកាត់បន្ថយហានិភ័យលំហូរសាច់ប្រាក់មិនទៀងទាត់។<br>• ផលិតផលធានារ៉ាប់រងដែលមានតម្លៃទាបដើម្បីជួយកាត់បន្ថយហានិភ័យ (ពាក់ព័ន្ធនឹងគ្រោះធម្មជាតិ កសិកម្ម និងមេគ្រួសារ)។ |
| ក្រុមអ្នកនៅក្នុងបន្ទុក | • មធ្យោបាយទូទាត់ដែលអាចទុកចិត្តបាននិងមានតម្លៃទាបសម្រាប់ទទួលប្រាក់ផ្ញើ។<br>• សេវាហិរញ្ញវត្ថុដែលអាចធ្វើប្រតិបត្តិការផ្ទេរប្រាក់និងសន្សំ ដើម្បីសម្រួលដល់ការចាយវាយត្រឹមត្រូវ។<br>• សេវាហិរញ្ញវត្ថុសម្រាប់ជួយសម្រួលការពង្រឹងសមត្ថភាពជំនាញ ដើម្បីបង្កើនផលិតភាព។ |

**៤៦- សកម្មភាពអាទិភាព** : ការកំណត់សកម្មភាពអាទិភាពត្រូវផ្អែកទៅលើផលប៉ះពាល់ដល់ចំនួនប្រជាជនដោយពិចារណាផងដែរ ទៅលើគោលដៅកំណើនសេដ្ឋកិច្ចជាតិ។ សកម្មភាពអាទិភាពទាំងនេះមានទិសដៅបង្កើនការទទួលបាននិងការប្រើប្រាស់សេវាហិរញ្ញវត្ថុ ដើម្បីផ្តល់លទ្ធភាពដល់ប្រជាជនក្នុងការគ្រប់គ្រងជីវភាពហិរញ្ញវត្ថុឲ្យប្រសើរឡើង។ ផ្អែកតាមការវិភាគ សកម្មភាពអាទិភាពមានបង្ហាញក្នុងតារាងទី២។

**តារាងទី២ : សកម្មភាពអាទិភាព**[៣២]

| សកម្មភាពអាទិភាព | ការរកឃើញសំខាន់ៗ |
|---|---|
| ១- លើកទឹកចិត្តឲ្យមានការសន្សំនៅតាមគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ | ប្រជាជនពេញវ័យសន្សំប្រាក់ក្នុងគ្រឹះស្ថានធនាគារមានតែ៦% និងសន្សំជាសាច់ប្រាក់និងជាទ្រព្យសកម្មផ្សេងៗមាន៥៩%។ ទោះបីជាមានលទ្ធភាពទទួលបានសេវាសន្សំក៏ដោយ ក៏ការប្រើប្រាស់សេវាសន្សំមានកម្រិតទាបនៅឡើយ។ |
| ២- ជំរុញនវានុវត្តន៍សេវាឥណទានសម្រាប់សហគ្រាសធុនតូចនិងមធ្យម | ក្រុមមានមុខរបរផ្ទាល់ខ្លួនប្រើប្រាស់សេវាឥណទានផ្លូវការមាន ២៨% ប្រើប្រាស់សេវាឥណទានក្រៅផ្លូវការមាន១០%និងមិនបានប្រើប្រាស់សេវាឥណទានមាន៦២%។ |
| ៣- ពង្រឹកសមត្ថភាពប្រព័ន្ធទូទាត់ | ប្រជាជនពេញវ័យដែលប្រើប្រាស់សាច់ប្រាក់សម្រាប់ធ្វើប្រតិបត្តិការផ្សេងៗមាន៨៩%និងប្រើប្រាស់បណ្ដាញផ្លូវការផ្សេងទៀតសម្រាប់ទូទាត់មាន៣២%។ |
| ៤- ពង្រីកការផ្ដល់សេវាធានារ៉ាប់រងឲ្យបានទូលំទូលាយ | ប្រជាជនពេញវ័យមិនប្រើសេវាធានារ៉ាប់រងមាន៩៥%។ |
| ៥- ពង្រឹងសមត្ថភាពនិយ័តករវិស័យហិរញ្ញវត្ថុ | យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ បានផ្ដល់អាទិភាពទៅលើការកសាងសមត្ថភាពស្ថាប័ននិងធនធានមនុស្ស នៅក្នុងវិស័យហិរញ្ញវត្ថុ។ |
| ៦- លើកកម្ពស់សិទ្ធិនិងបង្កើនកិច្ចការពារអតិថិជន ព្រមទាំងបង្កើនតម្លាភាពក្នុងវិស័យហិរញ្ញវត្ថុ | ប្រទេសកម្ពុជាមានអត្រាយល់ដឹងផ្នែកហិរញ្ញវត្ថុ១៨%ស្ថិតក្នុងចំណាត់ថ្នាក់ទី១៣៥ក្នុងចំណោម១៤៨ប្រទេស[៣៣]។ |

## II. ការកំណត់គោលដៅសម្រាប់បរិយាបន្នហិរញ្ញវត្ថុ

**៤៧- គោលដៅក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ :** យុទ្ធសាស្ត្រជាតិស្ដីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ លើកឡើងនូវគោលនយោបាយដែលចង្អុលបង្ហាញពីគោលដៅក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុដូចខាងក្រោម៖

**បង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការដែលមានគុណភាព កាត់បន្ថយអត្រាស្ត្រីដែលមិនទាន់ទទួលបានសេវាហិរញ្ញវត្ថុឲ្យបានពាក់កណ្ដាលពី២៧%មក១៣% និងពង្រីកការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការពី៥៩%ទៅ៧០% ត្រឹមឆ្នាំ២០២៥ ព្រមទាំងធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាពគ្រួសារ និងគាំទ្រកំណើនសេដ្ឋកិច្ច តាមរយៈសកម្មភាពអាទិភាព ដូចខាងក្រោម៖**

១- លើកទឹកចិត្តឲ្យមានការសន្សំនៅតាមគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ
២- ជំរុញនវានុវត្តន៍សេវាឥណទាន សម្រាប់សហគ្រាសធុនតូចនិងមធ្យម
៣- ពង្រីកសមត្ថភាពប្រព័ន្ធទូទាត់
៤- ពង្រីកការផ្តល់សេវាធានារ៉ាប់រងឲ្យបានទូលំទូលាយ
៥- ពង្រឹងសមត្ថភាពនិយ័តករវិស័យហិរញ្ញវត្ថុ និង
៦- លើកកម្ពស់សិទ្ធិនិងបង្កើនកិច្ចការពារអតិថិជន ព្រមទាំងបង្កើនតម្លាភាពក្នុងវិស័យហិរញ្ញវត្ថុ។

**៤៨- បុរេលក្ខខណ្ឌ** : សកម្មភាពអាទិភាពទាំង៦នេះ ត្រូវបានដាក់ចេញដើម្បីសម្រេចបាននូវគោលដៅដែលបានកំណត់ខាងលើ។ ទន្ទឹមនឹងនេះ ដើម្បីឲ្យការអនុវត្តសកម្មភាពអាទិភាពទទួលបានជោគជ័យ ចាំបាច់ត្រូវមានបុរេលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- ឆន្ទៈនយោបាយនិងកិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធ
- ស្ថិរភាពនយោបាយនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច
- ភាពប្រសើរឡើងនៃហេដ្ឋារចនាសម្ព័ន្ធអប់រំនិងកម្រិតអក្ខរកម្ម និង
- ភាពប្រសើរឡើងនៃហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ។

# ជំពូក៤

# សកម្មភាពអាទិភាព

៤៩- សកម្មភាពអាទិភាពចំនួន៦ដែលបានកំណត់ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ រួមមាន :

១- លើកទឹកចិត្តឲ្យមានការសន្សំនៅតាមគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ

២- ជំរុញនវានុវត្តន៍សេវាឥណទាន សម្រាប់សហគ្រាសធុនតូចនិងមធ្យម

៣- ពង្រីកសមត្ថភាពប្រព័ន្ធទូទាត់

៤- ពង្រីកការផ្តល់សេវាធានារ៉ាប់រងឲ្យបានទូលំទូលាយ

៥- ពង្រឹងសមត្ថភាពនិយ័តករវិស័យហិរញ្ញវត្ថុ និង

៦- លើកកម្ពស់សិទ្ធិនិងបង្កើនកិច្ចការពារអតិថិជន ព្រមទាំងបង្កើនតម្លាភាពក្នុងវិស័យហិរញ្ញវត្ថុ។

ការអនុវត្តសកម្មភាពអាទិភាពទាំងនេះនឹងអាចបំពេញតម្រូវការសេវាហិរញ្ញវត្ថុរបស់ប្រជាជនពេញវ័យជាច្រើន។ សកម្មភាពអាទិភាពទាំងនេះ ត្រូវបានបែងចែកជា៖

- វិស័យធនាគារ រួមមាន ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គ្រឹះស្ថានឥណទានជនបទ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ អ្នកដំណើរការតតីយភាគី គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ប្រតិបត្តិការបង់រំលស់ និងទីផ្សារប្តូរប្រាក់និងអន្តរធនាគារ
- វិស័យមិនមែនធនាគារ រួមមាន ធានារ៉ាប់រង សោធននិវត្តន៍ ទីផ្សារមូលបត្រ និងអាជីវកម្មទទួលបញ្ចាំនិងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ រួមមាន អភិបាលកិច្ចនិងក្របខ័ណ្ឌគតិយុត្តិនិងបទប្បញ្ញត្តិក្រមប្រតិបត្តិទីផ្សារនិងកិច្ចការពារអ្នកប្រើប្រាស់ ការិយាល័យឥណទាន ការធានាឥណទាន និងកិច្ចការពារអ្នកដាក់ប្រាក់បញ្ញើ និង
- ការកសាងសមត្ថភាព។

## I. វិស័យធនាគារ

### ការលើកទឹកចិត្តការសន្សំនៅក្នុងវិស័យធនាគារ

**៥០- ការលើកទឹកចិត្តប្រជាជនពេញវ័យឲ្យមានទម្លាប់សន្សំនិងបំប្លែងការសន្សំនេះជាទុនវិនិយោគ :** ការសន្សំរបស់ប្រជាជនពេញវ័យនៅកម្ពុជាមានកម្រិតទាប ដោយសារតែកត្តាជាច្រើន ក្នុងនោះចំណូលទាបនិងមិនទៀងទាត់ជាកត្តាចម្បង(៥៨%នៃប្រជាជនពេញវ័យ)ដែលធ្វើឲ្យលទ្ធភាពសន្សំនៅមានកម្រិត។ ការណ៍នេះជារបាំងក្នុងការបង្កើតមូលធននៅក្នុងសេដ្ឋកិច្ចនិងការកៀរគរមូលនិធិតាមរយៈវិស័យធនាគារ។ ម៉្យាងវិញទៀត ប្រជាជនភាគច្រើនសន្សំនៅផ្ទះឬសន្សំក្រៅផ្លូវការ ដែលបង្ហាញថា ប្រជាជនមានតម្រូវការសន្សំខ្ពស់ តែប្រភេទសេវាសន្សំផ្សេងៗមិនទាន់អាចបំពេញតាមតម្រូវការនេះ។ ក្រុមអ្នកសន្សំនិង

សហគមន៍ សង្គហសមាគមបានផ្តល់សេវាសន្សំដែលមានចំណាយទាបឬដោយមិនមានរបាំងចំពោះការប្រើប្រាស់ ហេតុដូច្នេះ ការកៀរគរប្រាក់សន្សំទទួលបានជោគជ័យ ក្នុងទម្រង់ជាការសន្សំទៀងទាត់និងកាតព្វកិច្ច។ ទន្ទឹមនឹងនេះ ប្រជាជនសន្សំប្រាក់នៅផ្ទះគឺដោយសារមានសន្ទនីយភាពខ្ពស់ និងងាយស្រួលដោះស្រាយស្ថានភាពបន្ទាន់។ ករណីទាំងនេះបង្ហាញថា ប្រជាជនមានលទ្ធភាពសន្សំក្នុងទំហំទឹកប្រាក់តូចៗ ហើយការកៀរគរប្រាក់សន្សំអាចធ្វើទៅបាន។

ការប្រើប្រាស់ឥណទានមានកម្រិតខ្ពស់សម្រាប់ចំណាយជីវភាពទូទៅ(១៥%)និងដោះស្រាយស្ថានភាពបន្ទាន់(៧%)។ ការណ៍នេះបង្ហាញថាប្រជាជនទទួលបានមូលនិធិតាមរយៈសេវាឥណទាន ហើយប្រើប្រាស់ប្រាក់ចំណូលដែលមានកម្រិត សម្រាប់ទូទាត់សងឥណទានជាជាងសន្សំ។ ការលើកទឹកចិត្តឲ្យប្រជាជនពេញវ័យសន្សំប្រាក់ពិតជាមានសារៈសំខាន់ ដើម្បីបំពេញតម្រូវការចាំបាច់និងស្ថានភាពបន្ទាន់ និងជួយដល់ការកៀរគរប្រាក់សន្សំ ហើយការបង្កើនការបណ្តុះបណ្តាលវប្បធម៌សន្សំជាជាងការខ្ចីឥណទាននឹងធ្វើឲ្យការគ្រប់គ្រងហិរញ្ញវត្ថុកាន់តែមានភាពប្រសើរឡើង។

ស្ត្រី(៤៦%)មានការសន្សំច្រើនជាងបុរស(៣៩%)ដែលមានគម្លាត៧%។ យន្តការសន្សំដែលពេញនិយមជាងគេ គឺការសន្សំតាមរយៈអ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ សម្រាប់ស្ត្រី(៣៧%)និងបុរស(២៨%)ដែលស្ត្រីខ្ពស់ជាងបុរស៩%[៣៤]។ ទោះយ៉ាងណា ការស្រាវជ្រាវរបស់មូលនិធិអភិវឌ្ឍន៍មូលធនអង្គការសហប្រជាជាតិលើមជ្ឈមណ្ឌលទិន្នន័យធំ អំពីការប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់អតិថិជន(ដោយផ្អែកលើទិន្នន័យទទួលបានពីអ្នកផ្តល់សេវាហិរញ្ញវត្ថុចំនួន៤ក្នុងប្រទេសកម្ពុជា ដែលគ្របដណ្តប់ប្រមាណ២០%នៃទីផ្សារឥណទាននិងសន្សំ) បានបង្ហាញថា ទំហំប្រាក់សន្សំជាមធ្យមរបស់ស្ត្រីមានកម្រិតទាបជាងខ្លាំងបើធៀបនឹងបុរស ហើយគណនីទាំងនោះស្ទើរតែគ្មានសកម្មភាព។ ការអភិវឌ្ឍសមត្ថភាពក្នុងការប្រមូលនិងប្រើប្រាស់មជ្ឈមណ្ឌលទិន្នន័យធំដែលបែងចែកអតិថិជនតាមយេនឌ័រជាតម្រូវការចាំបាច់ ដើម្បីបង្កើតអាជីវកម្មសម្រាប់ស្ត្រី ហើយផ្តល់ព័ត៌មានអំពីទីផ្សារ និងយុទ្ធសាស្ត្របែងចែកអតិថិជន។

**៥១- វប្បធម៌សន្សំជាទ្រព្យសកម្មបង្កើតចំណូលដល់អតិថិជន ប៉ុន្តែបាត់បង់ឱកាសក្នុងការប្រើប្រាស់មូលធនសម្រាប់អន្តរការីយកម្ម** : វប្បធម៌សន្សំជាសាច់ប្រាក់និងជាទ្រព្យសកម្មនៅប្រទេសកម្ពុជាមានតាំងពីយូរណាស់មកហើយ។ ចំណូលពីការសន្សំជាសាច់ប្រាក់មានកម្រិត ខណៈដែលការសន្សំជាទ្រព្យសកម្មផ្តល់ចំណូលតាមតម្លៃទីផ្សារ។ ការសន្សំជាសាច់ប្រាក់មានភាពងាយស្រួល មិនមានចំណាយប្រតិបត្តិការ និងមានសន្ទនីយភាពខ្ពស់ ខណៈបច្ច័យនៃការសន្សំជាទ្រព្យសកម្មរូបវន្ត ធ្វើឲ្យបាត់បង់ឱកាសក្នុងការប្រើប្រាស់ដើមទុនសម្រាប់អន្តរការីយកម្ម។ ដូច្នេះ កត្តាសំខាន់គឺត្រូវរកមធ្យោបាយដែលធ្វើឲ្យអតិថិជនប្តូរមកប្រើប្រាស់សេវាសន្សំជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលផ្តល់ចំណូលប្រកួតប្រជែង។ សេវាសន្សំទាំងនោះ រួមមានសេវាដែលបង្កើតចំណូលពីទ្រព្យសកម្មរូបវន្ត ដូចជា ការជួញដូរទ្រព្យសកម្មទាំងនោះក្នុងទីផ្សារខ្ចីឌីជី។ ជាងនេះទៅទៀត ការធ្វើឲ្យសេវាសន្សំមានតម្លៃសមរម្យនិងងាយទទួលបាន ជាកម្លាំងចលករដ៏សំខាន់ក្នុងការជំរុញកំណើនប្រើប្រាស់និងទទួលយកសេវាសន្សំ។

**៥២- កាលានុវត្តភាពសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការប្រើប្រាស់កត្តាជំនឿទុកចិត្ត ដើម្បីពង្រីកទីផ្សារ :** ជំនឿទុកចិត្តរបស់ប្រជាជនពេញវ័យក្នុងប្រទេសកម្ពុជាទៅលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានកម្រិតខ្ពស់ ប៉ុន្តែមិនទាន់មានលទ្ធភាពប្រើប្រាស់ជំនឿទុកចិត្តនេះ ដើម្បីបង្កើនមូលដ្ឋានអតិថិជននៅឡើយ ខណៈដែលជំនឿទុកចិត្តលើអ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការមានកម្រិតទាប។ ប៉ុន្តែ ការប្រើប្រាស់សេវាសន្សំឆ្លុះបញ្ចាំងរូបភាពផ្ទុយគ្នាទៅវិញ។ ជាក់ស្តែង ក្រុមអ្នកសន្សំជាមួយអ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការមានចំនួនសមាជិកច្រើនលើសលប់ ដោយសារអត្ថប្រយោជន៍ដែលទទួលបាន។ ដូច្នេះ កាលានុវត្តភាពសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការទាញយកផលប្រយោជន៍ពីជំនឿទុកចិត្តនេះ គឺការដោះស្រាយបញ្ហាផ្សេងៗដែលរារាំងអតិថិជនមិនឲ្យទទួលបានសេវាហិរញ្ញវត្ថុរបស់គ្រឹះស្ថាន។ ការសន្សំនៅក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានចាត់ទុកថាមានចំណាយខ្ពស់ ដោយសារមានកម្រៃសេវាប្រចាំឆ្នាំ ថ្លៃថែទាំគណនីនិងតម្រូវឲ្យមានសមតុល្យអប្បបរមា ព្រមទាំងមានចំណូលការប្រាក់ទាប។ ការបង្កើតសេវាសន្សំជាកញ្ចប់ដែលមានទឹកប្រាក់តូចៗ ការប្រាក់ខ្ពស់ និងអត្ថប្រយោជន៍ប្រសើរជាងមុនដល់អ្នកដាក់ប្រាក់បញ្ញើ នឹងផ្តល់កាលានុវត្តភាពក្នុងការកេណ្ឌប្រមូលប្រាក់សន្សំ។

**៥៣- យុទ្ធសាស្ត្រសម្រាប់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដើម្បីលើកទឹកចិត្តការសន្សំ :**

- ជំរុញនិងគាំទ្រការបង្កើតសេវាសន្សំដែលភ្ជាប់នឹងការផ្ទេរប្រាក់(ជាពិសេស ការផ្ទេរប្រាក់ឆ្លងដែន)
- លើកទឹកចិត្តអតិថិជនក្នុងការបង្កើនការប្រើប្រាស់សេវាហិរញ្ញវត្ថុឲ្យកាន់តែស៊ីជម្រៅ(សេវាសន្សំ សេវាឥណទាន សេវាទូទាត់ និងសេវាធានារ៉ាប់រង) និង
- ធ្វើយុទ្ធនាការផ្សព្វផ្សាយប្រព័ន្ធការពារប្រាក់បញ្ញើសម្រាប់ប្រជាជនមានប្រាក់ចំណូលទាប និងរស់នៅជនបទ។

## ការជំរុញឲ្យមានសេវាឥណទានប្រកបដោយនវានុវត្តន៍សម្រាប់អតិថិជននិងសហគ្រាសធុនតូចនិងមធ្យម

**៥៤- កាលានុវត្តភាពក្នុងការពង្រីកឥណទានផ្តល់ដោយគ្រឹះស្ថានធនាគារ :** គ្រឹះស្ថានធនាគារជាអ្នកផ្តល់ឥណទានធំបំផុត ទាំងទឹកប្រាក់ និងចំនួនអតិថិជនតូចៗ។ អតិថិជនគោលដៅរបស់គ្រឹះស្ថានធនាគារទាំងនោះ ភាគច្រើនជាក្រុមហ៊ុន និងជារូបវន្តបុគ្គលដែលមានមូលនិធិផ្ទាល់សុទ្ធច្រើន។ គ្រឹះស្ថានធនាគារមិនបានបង្កើតសេវាហិរញ្ញវត្ថុសម្រាប់បម្រើដល់ទីផ្សារលក់រាយក្នុងបរិមាណច្រើនទេ ដូច្នេះគ្រឹះស្ថានធនាគារនឹងមិនងាកមករកទីផ្សារនេះឡើយ។ ទោះយ៉ាងណា គ្រឹះស្ថានធនាគារអាចជំរុញការផ្តល់ឥណទានដោយផ្អែកលើលំហូរសាច់ប្រាក់ដល់សហគ្រាសធុនតូចនិងមធ្យម ជាពិសេស សហគ្រាសធុនតូចនិងមធ្យមដែលមានសក្តានុពល ប៉ុន្តែខ្វះហិរញ្ញប្បទាន។ គ្រឹះស្ថានធនាគារអាចបង្កើតសេវាហិរញ្ញវត្ថុនានាដោយប្រើប្រាស់ប្រាតិភោគជាចលនវត្ថុនិងគណនីត្រូវទទួល។ ការបង្កើតឲ្យមានធនាគារសហគ្រាសធុនតូចនិងមធ្យម ដោយរាជរដ្ឋាភិបាល នឹងចូលរួមដោះស្រាយបញ្ហាប្រឈមផ្នែកឥណទានរបស់សហគ្រាសធុនតូចនិងមធ្យម។

**៥៥- សេវាឥណទានសម្រាប់សហគ្រាសធុនតូចនិងមធ្យម :** គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនមានបែបបទស្មុគស្មាញសម្រាប់ស្នើសុំឥណទាន អនុម័តឥណទាន និងទាមទារទ្រព្យធានាដែលមានគុណភាពខ្ពស់។ ទោះជាទីផ្សារមានលក្ខណៈចង្អៀតក៏ដោយ គ្រឹះស្ថាននៅតែអាចមានមធ្យោបាយក្នុងការពង្រីកឥណទានដែលមិនតម្រូវឲ្យមានទ្រព្យធានាជាអចលនវត្ថុ ចំពោះសហគ្រាសធុនតូចនិងមធ្យម និងហិរញ្ញប្បទានខ្សែចង្វាក់តម្លៃជាដើម។ ដោយសារបណ្ដាញប្រតិបត្តិការច្រើននិងភាពងាយស្រួលក្នុងការប្រាស្រ័យទាក់ទងអតិថិជន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាស្ថាប័នមួយប្រសើរបំផុតសម្រាប់បំពេញតម្រូវការហិរញ្ញប្បទានរបស់អតិថិជនជាសហគ្រាសធុនតូចនិងមធ្យម។ ការបង្កើតឲ្យមានគម្រោងធានាឥណទាននឹងជួយឲ្យសហគ្រាសធុនតូចនិងមធ្យម អាចមានលទ្ធភាពទទួលបានហិរញ្ញប្បទានពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ កាន់តែប្រសើរជាងមុន។

**៥៦- ការពង្រឹងទីផ្សារភតិសន្យាហិរញ្ញវត្ថុ :** ទោះបីជាប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុទើបបានបង្កើតឡើងនៅឆ្នាំ២០១២ វិស័យនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្ដល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូចនិងមធ្យម លើឧបករណ៍កសិកម្មនិងគ្រឿងចក្រធុនតូចជាដើម។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញបទប្បញ្ញត្តិកំណត់យន្តការពន្ធដារសម្រាប់ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ដើម្បីចៀសវាងការគិតពន្ធបន្ថែមត្រួតគ្នាលើកិច្ចសន្យាភតិសន្យាហិរញ្ញវត្ថុ។ ជាមួយគ្នានេះដែរ ដើម្បីដោះស្រាយបញ្ហាប្រឈមនៅក្នុងការអនុវត្តភតិសន្យាហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌បានចេញលិខិតណែនាំដល់តុលាការឲ្យចូលរួមសហការពន្លឿននីតិវិធី និងចេញដីកាសម្រេចរក្សាការពារការរឹបអូសទ្រព្យសម្បត្តិដោយម្ចាស់បំណុល នៅក្នុងប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ។

**៥៧- យុទ្ធសាស្ត្រពង្រឹងមុខងារឥណទាន :**

- បង្កើតសេវាហិរញ្ញវត្ថុនិងជំរុញការផ្ដល់ហិរញ្ញប្បទានដោយប្រើប្រាស់សន្និធិ គណនីត្រូវទទួលហ្វាកទើរីង និងហិរញ្ញប្បទានខ្សែចង្វាក់តម្លៃ សម្រាប់សហគ្រាសធុនតូចនិងមធ្យម
- ពិនិត្យលើទីផ្សារនិងចំណែកឥណទានដែលអាចទទួលបានការធានា ពីគម្រោងធានាឥណទាន (កសិកម្ម ថាមពលកកើតឡើងវិញ និងសហគ្រាសធុនតូចនិងមធ្យមដែលជាកម្មសិទ្ធិរបស់ស្ត្រីជាដើម)
- យកចិត្តទុកដាក់ជាពិសេសលើការបង្កើតសេវាហិរញ្ញវត្ថុសម្រាប់ស្ត្រី(ឥណទានសម្រាប់ស្ត្រីវ័យក្មេង និងស្ត្រីដែលមានការងារធ្វើ និងការសន្សំសម្រាប់ស្ត្រីវ័យចំណាស់)
- ជំរុញការប្រើប្រាស់ប្រព័ន្ធផ្ដល់ហិរញ្ញប្បទានដោយផ្អែកលើទំនិញក្នុងឃ្លាំង ជាមួយក្រុមហ៊ុនគ្រប់គ្រងប្រាតិភោគតតីយភាគី សម្រាប់ថ្នាក់តំបន់ និងជាមួយប្រតិបត្តិករខ្សែចង្វាក់តម្លៃដែលមានទំនាក់ទំនងជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សម្រាប់ថ្នាក់មូលដ្ឋាន និង
- ស្វែងមតិអំពីតម្រូវការសេវាហិរញ្ញវត្ថុ តាមវិស័យនិងតាមផលិតផលមួយចំនួន(កសិកម្ម ថាមពលកកើតឡើងវិញ។ល។)ដែលអាចពង្រីកប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ។

## II. វិស័យមិនមែនធនាគារ

### ពង្រីកការផ្ដល់សេវាធានារ៉ាប់រងឲ្យបានទូលំទូលាយ

**៥៨- ទិដ្ឋភាពទូទៅនៃសេវាធានារ៉ាប់រង** : គិតត្រឹមចុងឆ្នាំ២០១៨ ទីផ្សារធានារ៉ាប់រងនៅកម្ពុជា មានក្រុមហ៊ុនធានារ៉ាប់រងសរុបចំនួន៣២ ក្នុងនោះមានក្រុមហ៊ុនធានារ៉ាប់រងទូទៅចំនួន១៣ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតចំនួន១០ ក្រុមហ៊ុនធានារ៉ាប់រងបន្តចំនួន១ និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចចំនួន៨ ដែលទទួលបានអាជ្ញាបណ្ណសម្រាប់ផ្ដល់សេវាធានារ៉ាប់រង ព្រមទាំងជើងសាធានារ៉ាប់រងចំនួន១៦ និងភ្នាក់ងារធានារ៉ាប់រងចំនួន២២ ដើម្បីចែកចាយផលិតផលដល់អតិថិជន និងក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងចំនួន៣។ បុព្វលាភធានារ៉ាប់រងដុលដែលទទួលបានពីផលិតផលធានារ៉ាប់រងទាំងអស់បានកើនឡើងពី២៥លានដុល្លារអាមេរិកក្នុងឆ្នាំ២០១០ទៅដល់ជាង១៩៥លានដុល្លារអាមេរិកនៅចុងឆ្នាំ២០១៨។ សម្រាប់រយៈពេល១២ខែ គិតត្រឹមខែធ្នូ ឆ្នាំ២០១៨ បុព្វលាភធានារ៉ាប់រងដុលទូទៅមានចំនួន៨៦លានដុល្លារអាមេរិកកើនឡើងប្រមាណ១៤% បុព្វលាភធានារ៉ាប់រងដុលអាយុជីវិតមានចំនួន១០០លានដុល្លារអាមេរិក កើនឡើងប្រមាណ៤៩% និងបុព្វលាភធានារ៉ាប់រងដុលខ្នាតតូចមានចំនួន៩លានដុល្លារអាមេរិក បានថយចុះ៧% បើប្រៀបធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០១៧។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ(ឆ្នាំ២០១៤-២០១៨) អត្រាកំណើនជាមធ្យមសម្រាប់បុព្វលាភធានារ៉ាប់រងដុលគឺមានចំនួន៣៥%។ រីឯ អត្រានៃចំណូលពីសេវាធានារ៉ាប់រងធៀបនឹងផ.ស.ស. កើនឡើងពី០,២១%នៅក្នុងឆ្នាំ២០១០ទៅចំនួន០,៨៣%នៅឆ្នាំ២០១៨ និងមានដង់ស៊ីតេធានារ៉ាប់រងកើនឡើងប្រមាណពី១,៧៣ដុល្លារអាមេរិកក្នុងប្រជាជនម្នាក់នៅឆ្នាំ២០១០ ទៅ ១២,០៤ ដុល្លារអាមេរិកក្នុងប្រជាជនម្នាក់ក្នុងឆ្នាំ២០១៨។

**៥៩- ការជំរុញការធានារ៉ាប់រងខ្នាតតូចដល់ប្រជាជនក្រីក្រនៅតំបន់ជនបទ** : ការធានារ៉ាប់រងខ្នាតតូចជាប្រភេទធានារ៉ាប់រងសម្រាប់ប្រជាជនពេញវ័យមានប្រាក់ចំណូលទាប ដែលភាគច្រើនមិនទាន់ទទួលបានការធានារ៉ាប់រងនៅឡើយ។ បច្ចុប្បន្ន កម្ពុជាមានក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចចំនួន៨កំពុងផ្ដល់សេវាធានារ៉ាប់រងសុខភាព ធានារ៉ាប់រងជីវិតមានកាលកំណត់ និងធានារ៉ាប់រងលើការទូទាត់ឥណទាន ដែលអតិថិជនអាចជ្រើសរើសសំណងធានារ៉ាប់រងជាសាច់ប្រាក់ឬមិនមែនជាសាច់ប្រាក់ សម្រាប់ធានារ៉ាប់រងសុខភាពខ្នាតតូច។ករណីនេះជាមូលដ្ឋានគ្រឹះដ៏ល្អមួយដើម្បីបង្កើតឲ្យមានការផ្ដល់សេវាធានារ៉ាប់រងជីវិតបន្ថែមទៀត និងការស្វែងរកសក្ដានុពលសម្រាប់សេវាធានារ៉ាប់រងទូទៅ។ ការធានារ៉ាប់រងខ្នាតតូចត្រូវបានកំណត់និយមន័យក្នុងច្បាប់ និងបទប្បញ្ញត្តិស្ដីពីការធានារ៉ាប់រង។ បទប្បញ្ញត្តិស្ដីពីការធានារ៉ាប់រងខ្នាតតូចកំពុងត្រូវបានរៀបចំដើម្បីធានាឲ្យមានបទប្បញ្ញត្តិសំខាន់ៗសម្រាប់គ្រប់គ្រងវិស័យធានារ៉ាប់រងខ្នាតតូច ដែលអាចជំរុញដល់កំណើននៃវិស័យនេះ។ ដើម្បីបង្កើតបរិយាកាសអំណោយផលក្នុងការពង្រីកវិស័យធានារ៉ាប់រងខ្នាតតូច ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវដាក់ចេញបទប្បញ្ញត្តិរួម សម្រាប់លើកកម្ពស់បណ្ដាញចែកចាយផលិតផលធានារ៉ាប់រង និងត្រួតពិនិត្យប្រតិបត្តិករដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់និយ័តករនីមួយៗ។

**៦០- កាលានុវត្តភាពរបស់ក្រុមហ៊ុនធានារ៉ាប់រងក្នុងការពង្រីកសេវាតាមរយៈផលិតផលធានារ៉ាប់រងដែលមានតម្លៃសមរម្យ :** ទីផ្សារធានារ៉ាប់រងស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយ ដែលក្រុមហ៊ុនធានារ៉ាប់រងភាគច្រើនផ្តល់សេវាធានារ៉ាប់រងអាយុជីវិត និងសេវាធានារ៉ាប់រងទូទៅខ្នាតតូច។ ក្រុមហ៊ុនធានារ៉ាប់រងមានកាលានុវត្តភាពខ្ពស់ក្នុងការបន្ថែមសេវានិងផលិតផលធានារ៉ាប់រងដែលមានតម្លៃសមរម្យ ទៅក្នុងកញ្ចប់ផលិតផលដែលកំពុងមានតម្រូវការ ដោយសារប្រជាជនពេញវ័យនៅកម្ពុជាភាគច្រើនប្រើប្រាស់ប្រាក់សន្សំ និងឥណទានដើម្បីគ្រប់គ្រងហានិភ័យ និងដោះស្រាយស្ថានភាពធ្ងន់ធ្ងរបន្ទាន់ ដូចនេះសេវាធានារ៉ាប់រងនឹងជួយពង្រឹងស្ថានភាពហិរញ្ញវត្ថុរបស់ប្រជាជន។ ដោយសារការប្រើប្រាស់សេវាធានារ៉ាប់រងនៅកម្ពុជាមានបរិមាណតិចតួចត្រឹមតែ០,៧៤% ដូច្នេះទីផ្សារធានារ៉ាប់រងនៅមានសក្តានុពលខ្លាំង។ ទោះយ៉ាងណា ឆន្ទៈរបស់ក្រុមហ៊ុនធានារ៉ាប់រងគឺជាធាតុដ៏សំខាន់ក្នុងការជំរុញ និងចូលរួមចំណែកយ៉ាងសកម្មដល់ការអភិវឌ្ឍទីផ្សារធានារ៉ាប់រងខ្នាតតូចនេះ តាមរយៈការលើកទឹកចិត្តដែលគាំទ្រដោយបទប្បញ្ញត្តិ។ ផលិតផលធានារ៉ាប់រងអាចត្រូវបានលក់តាមរយៈគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្នុងរូបភាពជាភ្នាក់ងារណែនាំអតិថិជនធានារ៉ាប់រងដែលបានផ្តល់ផលិតផលធានារ៉ាប់រងទូទៅ របស់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ឬក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច។

**៦១- ការសិក្សាលើបណ្តាញចែកចាយដែលមានតម្លៃសមរម្យ :** បញ្ហាប្រឈមចម្បងក្នុងការពង្រីកនិងការប្រើប្រាស់សេវាធានារ៉ាប់រង គឺការខ្វះខាតបណ្តាញចែកចាយទូលំទូលាយ និងមានតម្លៃសមរម្យ ដែលមានសារៈសំខាន់ ក្នុងការធ្វើឲ្យបុព្វលាភធានារ៉ាប់រងមានតម្លៃសមរម្យ។ បណ្តាញចែកចាយទំនើបជាតម្រូវការចាំបាច់ក្នុងការផ្តល់សេវាធានារ៉ាប់រងទៅដល់អតិថិជននៅតាមតំបន់ដាច់ស្រយាល។ ការប្រើប្រាស់បណ្តាញដែលមានស្រាប់របស់គ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀតឲ្យកាន់តែទូលំទូលាយនឹងជួយជំរុញការប្រើប្រាស់សេវាធានារ៉ាប់រងនៅកម្ពុជា។ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចមួយចំនួនបានប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងការសម្រួលដល់ការប្រមូលបុព្វលាភ និងពន្លឿនការទូទាត់សំណងធានារ៉ាប់រង។ ករណីនេះបានបង្ហាញអំពីកាលានុវត្តភាពក្នុងការអភិវឌ្ឍនិងការពង្រីកផលិតផលធានារ៉ាប់រងឲ្យមានតម្លៃសមរម្យ(ផលិតផលដែលមានគុណប្រយោជន៍ខ្ពស់ប៉ុន្តែតម្លៃសមរម្យ) និងវិធីសាស្ត្រចែកចាយដើម្បីបង្កើនវិសាលភាព និងពង្រីកការផ្តល់ផលិតផលធានារ៉ាប់រងដល់ប្រជាជនមួយចំនួនធំដែលមិនទាន់បានប្រើប្រាស់។

**៦២- យុទ្ធសាស្ត្រពង្រឹងមុខងារទីផ្សារធានារ៉ាប់រង :**

- គាំទ្រដល់ការធ្វើពិពិធកម្មផលិតផលធានារ៉ាប់រងខ្នាតតូចនិងមានបុព្វលាភសមរម្យ រួមមានការធានារ៉ាប់រងសុខភាព និងការសម្រាកព្យាបាលនៅមន្ទីរពេទ្យ
- សិក្សាលើការអភិវឌ្ឍសន្ទស្សន៍ធានារ៉ាប់រងអាកាសធាតុ ដំណាំ និងសត្វ ដើម្បីគាំទ្រដល់ការអភិវឌ្ឍផលិតផលធានារ៉ាប់រងវិស័យកសិកម្ម

- គាំទ្រដល់ការបង្កើតផលិតផលធានារ៉ាប់រងដែលមានបុព្វលាភសមរម្យ សម្រាប់ស្ត្រីដែលមានប្រាក់ចំណូលទាប និងជំរុញឲ្យមានបណ្តាញចែកចាយផលិតផលធានារ៉ាប់រងដល់អ្នកប្រើប្រាស់ និង
- ដាក់ឲ្យប្រើប្រាស់នូវក្រមប្រតិបត្តិ សម្រាប់ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច។

**៦៣- បង្កើនការតាមដាននិងត្រួតពិនិត្យការអនុវត្តអាជីវកម្មទទួលបញ្ចាំនិងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន** : គិតត្រឹមឆ្នាំ២០១៨ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានផ្តល់អាជ្ញាបណ្ណជូនក្រុមហ៊ុន សហគ្រាសអាជីវកម្មទទួលបញ្ចាំនិងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានបានចំនួន ៥២៧ ក្រុមហ៊ុន សហគ្រាសដែលមានដើមទុនអាជីវកម្មសរុបប្រមាណ៣០លានដុល្លារអាមេរិក និងបានចូលរួមចំណែកក្នុងការផ្តល់ប្រាក់កម្ចីក្នុងប្រព័ន្ធហិរញ្ញវត្ថុផ្លូវការប្រមាណ១៥៧លានដុល្លារអាមេរិក ដោយគិតចាប់ពីឆ្នាំ២០១៤។ ក្នុងន័យនេះបង្ហាញឲ្យឃើញថា អាជីវកម្មទទួលបញ្ចាំនិងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយតម្រូវការទុនបន្ទាន់ ជូនដល់ប្រជាជនដែលមានចំណូលទាបនិងមធ្យមបានយ៉ាងច្រើន។ ដូច្នេះការរៀបចំបទប្បញ្ញត្តិនានា គឺជាការងារអាទិភាពសម្រាប់គ្រប់គ្រងនិងត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ដើម្បីធានាតម្លាភាព ជៀសវាងការកេងចំណេញផ្នែកបទប្បញ្ញត្តិ និងលុបបំបាត់អាជីវកម្មខុសច្បាប់។

**៦៤- យុទ្ធសាស្ត្រពង្រឹងអាជីវកម្មទទួលបញ្ចាំនិងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន :**

- រៀបចំច្បាប់និងបទប្បញ្ញត្តិបន្ថែមសម្រាប់ពង្រីកដល់ការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំនិងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន និង
- បង្កើនការតាមដាននិងការត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំនិងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ដើម្បីធានាប្រសិទ្ធភាពនិងសក្តិសិទ្ធភាពនៃការអនុវត្តប្រកបដោយចីរភាព។

**តួនាទីទីផ្សារមូលបត្រក្នុងបរិយាបន្នហិរញ្ញវត្ថុ**

**៦៥- គាំទ្រគំនិតផ្តួចផ្តើមរបស់គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក)** : ដោយសារទីផ្សារមូលបត្រជាទីផ្សារថ្មីនៅកម្ពុជានិងមានទំហំតូច បើប្រៀបធៀបទៅនឹងទីផ្សារនៅក្នុងតំបន់ ទីផ្សារនេះនៅខ្វះសន្ទនីយភាពនិងភាពស៊ីជម្រៅ។ គ.ម.ក បាននិងកំពុងជំរុញនូវការកសាងសមត្ថភាពនិងបង្កើតស្តង់ដានៃការអនុវត្តអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុន ដើម្បីជួយសម្រួលដល់ការចុះបញ្ជីក្រុមហ៊ុនក្នុងទីផ្សារមូលបត្រ។ គ.ម.ក កំពុងអភិវឌ្ឍផ្តល់ការលើកទឹកចិត្ត និងគាំទ្រផ្នែកបច្ចេកទេស ដើម្បីជំរុញឲ្យមានក្រុមហ៊ុនកាន់តែច្រើនចូលរួមក្នុងទីផ្សារមូលបត្រ។ ទន្ទឹមនេះ គ.ម.ក ក៏កំពុងរៀបចំបទប្បញ្ញត្តិសម្រាប់ការចុះបញ្ជីទាំងមូលបត្ររដ្ឋនិងមូលបត្រឯកជន។ គ.ម.ក កំពុងខិតខំលើកទឹកចិត្តឲ្យមានការចូលរួមពីវិនិយោគិនស្ថាប័ន ដូចជា ក្រុមហ៊ុនធានារ៉ាប់រងដែលអាចធ្វើឲ្យទីផ្សារកាន់តែមានភាពស៊ីជម្រៅ និងប្រកបដោយគុណភាព។

**៦៦- ការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ** : ដើម្បីរួមចំណែកក្នុងកិច្ចការពារវិនិយោគិន នាពេលថ្មីៗនេះ គ.ម.ក បានអនុម័តប្រកាសស្តីពីការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ ដែលផ្តល់ឲ្យវិនិយោគិនក៏ដូចជាអ្នកចូលរួម

ក្នុងទីផ្សារ នូវមធ្យោបាយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការវិនិយោគក្នុងទីផ្សារមូលបត្រ។ ទន្ទឹមនឹងនេះ កម្មវិធីជំរុញការអនុវត្តច្បាប់និងបទប្បញ្ញត្តិមូលបត្រ ក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាសណ្តាប់ធ្នាប់ និងភាពត្រឹមត្រូវនៅក្នុងទីផ្សារ។ ក្នុងន័យនេះ គ.ម.ក បានរៀបចំសិក្ខាសាលាជាច្រើន ពាក់ព័ន្ធនឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិមូលបត្រនៅទូទាំងប្រទេស។ គ.ម.ក ក៏បានអនុម័តប្រកាសស្តីពីការស៊ើបអង្កេតក្នុងវិស័យមូលបត្រ ដើម្បីផ្តល់នូវក្របខ័ណ្ឌជាក់លាក់ និងច្បាស់លាស់សម្រាប់និយ័តករ និងអ្នកចូលរួមក្នុងទីផ្សារឲ្យយល់ដឹងពីតួនាទីនិងកាតព្វកិច្ចរបស់ខ្លួន ក្នុងករណីមានការស៊ើបអង្កេត។

**៦៧- សកម្មភាពបន្តរបស់គ.ម.ក :** គ.ម.ក បាននិងកំពុងអនុវត្តសកម្មភាពមួយចំនួនដើម្បីលើកកម្ពស់ទីផ្សារ ដូចជា ១)- កម្មវិធីអប់រំវិនិយោគិនដើម្បីបង្កើនចំណេះដឹងអំពីនីតិវិធីជួញដូរថ្មីៗ នៅក្នុងទីផ្សារមូលបត្រ ២)- កម្មវិធីសម្រាប់ក្រុមហ៊ុនចុះបញ្ជីសក្តានុពលដើម្បីបង្កើនការយល់ដឹងក្នុងការទទួលបានហិរញ្ញប្បទានផ្សេងទៀតសម្រាប់សហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា និង ៣)- កម្មវិធីឧត្តមភាពដើម្បីជំរុញការរៀបចំក្រុមហ៊ុនប្រកបដោយស្តង់ដា។

## III. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ

### ការលើកទឹកចិត្តការសន្សំនៅគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ

**៦៨- ភាពចាំបាច់ក្នុងការលើកកម្ពស់វប្បធម៌សន្សំប្រាក់ :** លទ្ធផលនៃរបាយការណ៍វិភាគស្ថានភាពបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៧ បានបង្ហាញថាវប្បធម៌សន្សំប្រាក់ (ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ) មានកម្រិតទាប។ ការណ៍នេះអាចធ្វើឲ្យប្រសើរឡើង តាមរយៈការលើកកម្ពស់ការយល់ដឹងអំពីការសន្សំប្រាក់ជំនួសឲ្យការប្រើប្រាស់ឥណទាន។ រាជរដ្ឋាភិបាលអាចដាក់ចេញគំនិតផ្តួចផ្តើមលើកទឹកចិត្តប្រជាជនឲ្យសន្សំប្រាក់តាមរយៈយុទ្ធនាការអប់រំនិងជំរុញការសន្សំជាមួយបណ្តាញសេវាហិរញ្ញវត្ថុផ្លូវការ ដោយផ្តល់ផលប្រយោជន៍ដូចជា ការការពារប្រាក់បញ្ញើ ការផ្តល់ឥណទាន ការអនុគ្រោះពន្ធ ជាដើម។

**៦៩- យុទ្ធសាស្ត្រសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ ដើម្បីលើកកម្ពស់ការសន្សំ :**

- បង្កើតផែនការរំកិលថ្នាក់ជាតិស្តីពីការសន្សំប្រាក់ដោយមានការអនុគ្រោះពន្ធដល់អតិថិជនមានចំណូលទាប
- រៀបចំបទប្បញ្ញត្តិដែលអនុញ្ញាតឲ្យភ្នាក់ងាររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អាចប្រមូលប្រាក់សន្សំតូចៗ និង
- គាំទ្រការអភិវឌ្ឍនិងអនុម័តបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិធីសាស្ត្រថ្លៃដើមទាប ដើម្បីកៀរគរប្រាក់សន្សំនៅក្រៅបណ្តាញសាខារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើនៅជនបទ។

**៧០- ការសិក្សាពីវិធីសាស្ត្រសម្រាប់ពង្រីកការផ្តល់ឥណទានដោយគ្មានទ្រព្យធានា ដល់សហគ្រាសធុនតូចនិងមធ្យម :** នៅកម្ពុជា ឥណទានត្រូវបានផ្តល់ដោយមានអចលនវត្ថុជាទ្រព្យធានានិងពឹងផ្អែកលើប្រាក់ចំណូលទៀងទាត់ មានន័យថា ឥណទានត្រូវបានរឹតត្បិតចំពោះប្រជាជនដែលគ្មានទ្រព្យធានានិងចលនវត្ថុ។ ការណ៍នេះធ្វើឲ្យកើនឡើងនូវការប្រើប្រាស់សេវាឥណទានផ្តល់ដោយអ្នកផ្តល់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ ដែលមានការប្រាក់ខ្ពស់។ នេះជាកាលានុវត្តភាពក្នុងការបង្កើតសេវាឥណទានដែលមិនមានការធានានិងប្រើប្រាស់ចលនវត្ថុជាទ្រព្យធានា ដែលនឹងបង្កើនប្រភពសម្រាប់ការវិនិយោគ និងកំណើនសេដ្ឋកិច្ច ព្រមទាំងកាត់បន្ថយថ្លៃដើមឥណទាន។ ទន្ទឹមនឹងនេះ ការតម្កល់លិខិតជូនដំណឹងស្តីពីប្រតិបត្តិការដែលមានកិច្ចធានា តាមរយៈប្រព័ន្ធប្រតិបត្តិការដែលមានកិច្ចធានា បាននិងកំពុងជួយសម្រួលផ្តល់ឥណទានដែលមានទ្រព្យធានាជាចលនវត្ថុ(ដូចជា សន្និធិ គណនីត្រូវទទួល ផលដំណាំ ឧបករណ៍ផ្សេងៗ ជាដើម) ព្រមទាំងបង្កើនលទ្ធភាពទទួលបានឥណទាន តាមរយៈការធានាជាក្រុម និងវិធីសាស្ត្រដទៃទៀត។ ការណ៍នេះគាំទ្រដល់ការបង្កើនប្រភេទទ្រព្យធានាផ្សេងៗ ដែលនឹងពង្រីកការទទួលបានឥណទានពីគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ។

**៧១- ការលើកកម្ពស់របាយការណ៍ឥណទាននិងការវាយតម្លៃហានិភ័យឥណទាន :** ដោយសារសកម្មភាពឥណទានកើនឡើងយ៉ាងឆាប់រហ័ស ប្រសិទ្ធភាពនៃការតាមដាន និងការត្រួតពិនិត្យទីផ្សារឥណទានមានសារៈសំខាន់ក្នុងការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុនៅកម្ពុជា។ បទប្បញ្ញត្តិត្រួតពិនិត្យដែលមានប្រសិទ្ធភាពចាំបាច់ត្រូវពង្រឹង ដើម្បីបញ្ចៀសការខ្ចីប្រាក់ពីច្រើនគ្រឹះស្ថាន និងបំណុលលើសលប់។ ជាក់ស្តែងនៅកម្ពុជា ទិន្នន័យឆ្នាំ២០១៨ បង្ហាញថាអតិថិជនដែលមានទំនាក់ទំនងជាមួយគ្រឹះស្ថានលើសពី៣មានកម្រិតហានិភ័យ ១,១០% (សំពៀតឥណទានហួសកាលកំណត់សងរយៈពេល៣០ថ្ងៃ)។ ការិយាល័យឥណទានកម្ពុជាមានកាតព្វកិច្ចផ្តល់ទិន្នន័យឥណទានទាន់ពេលវេលា ដើម្បីជួយគ្រប់គ្រងហានិភ័យឥណទាន តាមរយៈការវាយតម្លៃហានិភ័យឥណទានឲ្យបានសមរម្យ។ កង្វះទិន្នន័យទាន់ពេលវេលា អំពីអ្នកខ្ចីប្រាក់ ឬបញ្ហាដែលកើតឡើងពីការប្រើប្រាស់អត្តសញ្ញាណបណ្ណច្រើនប្រភេទរបស់អ្នកខ្ចីប្រាក់ ធ្វើឲ្យព័ត៌មានផ្តល់ដោយការិយាល័យឥណទានកម្ពុជាមានភាពខ្វះចន្លោះ។ ដោយសារសហគមន៍ សង្គហសមាគម កំពុងក្លាយជាអ្នកផ្តល់ឥណទានដ៏សំខាន់ ការតាមដាននិងការអនុវត្តកាតព្វកិច្ចរាយការណ៍របស់សហគមន៍ សង្គហសមាគម ទៅការិយាល័យឥណទានកម្ពុជាជាការចាំបាច់។ ដើម្បីពង្រឹងការគ្រប់គ្រងឥណទានឲ្យកាន់តែមានប្រសិទ្ធភាព ការងារអាទិភាពគឺការពង្រឹងការិយាល័យឥណទានកម្ពុជានិងកាតព្វកិច្ចរាយការណ៍ ដើម្បីវាយតម្លៃលទ្ធភាពសងរបស់អ្នកខ្ចីប្រាក់សក្តានុពល។

**៧២- យុទ្ធសាស្ត្រពង្រឹងមុខងារឥណទាន :**

- ពង្រឹងនិងពង្រីកដំណើរការនិងផ្សព្វផ្សាយ ការតម្កល់លិខិតជូនដំណឹងដែលមានកិច្ចធានាដល់វិស័យឯកជននិងស្ថាប័នពាក់ព័ន្ធ ដើម្បីលើកកម្ពស់ការផ្តល់ឥណទានដោយមានទ្រព្យធានាជាចលនវត្ថុ

- ពង្រឹងនិងពង្រីកមុខងារការិយាល័យឥណទានលើការប្រមូលព័ត៌មានលម្អិតរបស់អតិថិជន របាយការណ៍ឥណទាន និងយន្តការវាយតម្លៃហានិភ័យឥណទាន
- សិក្សាតាមគ្រា អំពីបំណុល និងបំណុលលើសលប់
- កំណត់និយមន័យឲ្យបានច្បាស់លាស់ក្នុងបទប្បញ្ញត្តិអំពី បំណុលលើសលប់ ការផ្តល់ឥណទានធូររលុង និងការផ្តល់ឥណទានដែលមានលក្ខខណ្ឌសមស្រប
- ពិនិត្យលទ្ធភាពនៃការកំណត់អាជ្ញាយុកាលនៃបំណុល និង
- ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធកំណត់អត្តសញ្ញាណបណ្ណជាតិដើម្បីបញ្ចូលការចុះឈ្មោះជាមជ្ឈការ និងស្វែងរកជម្រើសផ្សេងទៀតសម្រាប់អត្តសញ្ញាណបណ្ណមួយច្បាស់លាស់ ដូចជា អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរឌីជីថលបាយអូមេទ្រិក ជាដើម។

**ការពង្រីកសមត្ថភាពប្រព័ន្ធទូទាត់ឌីជីថល**

**៧៣- ផែនការសម្រាប់ផ្លាស់ប្តូរទៅប្រតិបត្តិការឌីជីថល :** បណ្តាញទូទាត់ឌីជីថល មានភាពឆាប់រហ័ស សុវត្ថិភាព និងចំណាយតិចក្នុងប្រតិបត្តិការទូទាត់ ជាពិសេស កន្លែងឆ្ងាយៗ។ សេដ្ឋកិច្ចកម្ពុជាដែលពឹងផ្អែកខ្លាំងលើការប្រើប្រាស់សាច់ប្រាក់ នឹងទទួលបានអត្ថប្រយោជន៍កាន់តែច្រើនពីការផ្លាស់ប្តូរទៅប្រើប្រាស់ប្រតិបត្តិការឌីជីថល។ កត្តាជំរុញដ៏សំខាន់ក្នុងការប្រើប្រាស់បណ្តាញឌីជីថល គឺចាប់ផ្តើមពីការប្រើប្រាស់គណនីប្រាក់បញ្ញើ គណនីប្រតិបត្តិការជាមួយគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគណនីទូទាត់តាមរយៈគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។ គណនីទាំងនេះជាកន្លែងប្រមូលផ្តុំធនធានសម្រាប់ធ្វើប្រតិបត្តិការឌីជីថល និងទទួលប្រាក់ចំណូល។ មធ្យោបាយដើម្បីធានាការប្រើប្រាស់គណនីទាំងនេះ គឺការជំរុញឲ្យការទូទាត់របស់រាជរដ្ឋាភិបាល និងនិយោជក(ការទូទាត់របបសន្តិសុខសង្គម ការទូទាត់តាមលក្ខខណ្ឌនៃកិច្ចសន្យា និងការទូទាត់ប្រាក់បៀវត្សរ៍) ធ្វើឡើងជាឌីជីថលភ្ជាប់ជាមួយគណនីទាំងនេះ។ ការធានាឲ្យមានប្រតិបត្តិការឌីជីថលនិងទីតាំងសម្រាប់ដកប្រាក់គ្រប់គ្រាន់ មានសារៈសំខាន់ណាស់ក្នុងការជួយឲ្យនិយោជិតអាចទទួលបានសាច់ប្រាក់ដោយងាយស្រួល។ លើសពីនេះទៀត ដើម្បីគាំទ្រដល់ប្រតិបត្តិការឌីជីថល ចាំបាច់ត្រូវមានទីតាំងសម្រាប់ដកប្រាក់ និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ចរាចរសាច់ប្រាក់ ដើម្បីឲ្យអតិថិជនមានជម្រើសធ្វើប្រតិបត្តិការជាសាច់ប្រាក់ រហូតទាល់តែការទូទាត់តាមប្រព័ន្ធឌីជីថលមានលក្ខណៈទូលំទូលាយអាចជំនួសការប្រើប្រាស់សាច់ប្រាក់។ ទីតាំងសម្រាប់ដកប្រាក់និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ចរាចរសាច់ប្រាក់ គឺជាស្ពានដ៏ចាំបាច់រវាងសេដ្ឋកិច្ចរូបវន្តនិងប្រព័ន្ធហិរញ្ញវត្ថុឌីជីថល និងជាជំហានដ៏សំខាន់មួយឆ្ពោះទៅរកការបង្កើន ការទទួលយក និងការប្រើប្រាស់បណ្តាញឌីជីថលក្នុងរយៈពេលវែង។ មូលប្បទានបត្រជាឧបករណ៍ទូទាត់ដែលភ្ជាប់ប្រតិបត្តិការឌីជីថលនិងសាច់ប្រាក់។ ការប្រើប្រាស់មូលប្បទានបត្រ មិនគួរត្រូវបានលើកទឹកចិត្តទេ ដោយសារមុខងាររបស់មូលប្បទានបត្រត្រូវបានបញ្ចូលទៅក្នុងការផ្ទេរមូលនិធិជាអេឡិចត្រូនិក ហើយការប្រើប្រាស់ឧបករណ៍នេះមានហានិភ័យ និងចំណាយច្រើនចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ខណៈដែលការធ្វើប្រតិបត្តិការជាឌីជីថលមានភាពប្រសើរជាង។

បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជា បានខិតខំប្រឹងប្រែងលើកកម្ពស់ការប្រើប្រាស់ការទូទាត់ជាអេឡិចត្រូនិក ដោយបានអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងដាក់ចេញនូវបទប្បញ្ញត្តិនានា។ ទោះយ៉ាងណា ចំណេះដឹងផ្នែកហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ថា មានកម្រិតនៅឡើយ ដូច្នេះការផ្តួចផ្តើមផ្សព្វផ្សាយការយល់ដឹងជាសាធារណៈអំពីឧបករណ៍ និងបណ្តាញទូទាត់ឌីជីថល គប្បីត្រូវបានយកចិត្តទុកដាក់ ជាពិសេសចំពោះប្រជាជននៅជនបទ មន្ត្រីរាជការ និងនិវត្តជន។

**៧៤- ការជំរុញអភិវឌ្ឍបណ្តាញផ្ទេរប្រាក់** ៖ ប្រជាជនភាគច្រើនផ្ទេរប្រាក់និងទទួលប្រាក់ទាំងក្នុងស្រុកនិងអន្តរជាតិ។ សេវាផ្ទេរប្រាក់ គឺជាសេវាហិរញ្ញវត្ថុដែលត្រូវបានប្រើច្រើនជាងគេ ដោយប្រជាជនពេញវ័យ៥៤% ជាអ្នកផ្ញើឬទទួលប្រាក់។ ចំពោះការផ្ទេរប្រាក់ក្នុងស្រុក ការទូទាត់ចល័ត គឺជាបណ្តាញមួយដែលពេញនិយមសម្រាប់ទាំងការទទួលនិងផ្ញើប្រាក់[៣៥]។ ការជួយដល់អ្នកប្រើប្រាស់សេវាទូទាត់រំលងបញ្ជរ គឺជាកត្តាជំរុញឲ្យមានការប្រើប្រាស់ការទូទាត់ចល័តកាន់តែច្រើន។ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ គឺជាតួអង្គសំខាន់ក្នុងការគាំទ្រដល់ការពង្រីកការទទួលបានសេវាហិរញ្ញវត្ថុ តាមរយៈការពង្រីកបណ្តាញភ្នាក់ងារនិងប្រតិបត្តិការនៅជនបទនិងទីប្រជុំជន និងការផ្តល់សេវាទូទាត់ចល័តដែលមានតម្លៃទាប។ ការតម្រូវឯកសារងាយៗសម្រាប់ផ្ទេរប្រាក់ចល័ត គឺជាធាតុសំខាន់មួយក្នុងការប្តូរពីការផ្ទេរប្រាក់ក្រៅផ្លូវការ ទៅក្នុងបណ្តាញផ្លូវការ ដោយសារមានពលករធ្វើការនៅក្រៅប្រទេស។ លើសពីនេះ ការផ្ទេរប្រាក់ក៏អាចធ្វើទៅបានតាមរយៈម៉ាស៊ីន ATM ភ្នាក់ងារផ្ទេរប្រាក់ចល័ត និងតាមម៉ាស៊ីន Kiosks។ ចំពោះការផ្ទេរប្រាក់ជាអន្តរជាតិ អ្នកទទួលប្រាក់នៅកម្ពុជាភាគច្រើនបានទទួលប្រាក់ពីបណ្តាញផ្លូវការ ជាពិសេស ពីប្រតិបត្តិករផ្ទេរប្រាក់ដូចជា Western Union, MoneyGram និង IME។ ដោយឡែក ប្រជាជនកម្ពុជាដែលទទួលបានការផ្ទេរប្រាក់ក្នុងស្រុកមានអត្រាខ្ពស់។ ដូចនេះ កត្តាសំខាន់គឺការរៀបចំឲ្យមានបរិស្ថានអំណោយផលសម្រាប់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ក្នុងការផ្តល់សេវាផ្ទេរប្រាក់ឆ្លងដែន។ ដោយយល់ឃើញពីសារៈសំខាន់ទាំងនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឲ្យអនុវត្តប្រកាសស្តីពីការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលអាចឲ្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ បើកបណ្តាញដើម្បីសម្រួលការទូទាត់ពាណិជ្ជកម្ម និងការផ្ទេរប្រាក់ឆ្លងដែន។ លើសពីនេះ ការធ្វើប្រតិបត្តិការផ្ទេរប្រាក់តាមបណ្តាញផ្លូវការ នឹងផ្តល់កាលានុវត្តភាពសម្រាប់ការផ្តល់សេវាសន្សំនិងឥណទានដល់អ្នកផ្ញើនិងអ្នកទទួលប្រាក់។

**៧៥- ការលើកទឹកចិត្តដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូទាត់** ៖ ប្រព័ន្ធទូទាត់គឺជាឆ្អឹងខ្នងនៃសេវាហិរញ្ញវត្ថុផ្លូវការ។ ដូច្នេះ ការអភិវឌ្ឍប្រព័ន្ធទូទាត់មានឥទ្ធិពលដោយផ្ទាល់ទៅលើលទ្ធភាពផ្តល់សេវាហិរញ្ញវត្ថុឲ្យកាន់តែច្រើននិងប្រសើរឡើង។ នៅក្នុងបរិបទនេះ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូទាត់ ដើម្បីគាំទ្រដល់ការជាត់ទាត់ និងទូទាត់អន្តរធនាគារពិតជាមានសារៈសំខាន់ណាស់។ ប្រព័ន្ធសម្រាប់ការទូទាត់រាយរួមមាន៖

**ក- ប្រព័ន្ធជាត់ទាត់ជាតិ** ត្រូវបានដាក់ឲ្យដំណើរការនៅខែធ្នូ ឆ្នាំ២០១២ ដើម្បីសម្រួលការជាត់ទាត់មជ្ឈការសម្រាប់មូលប្បទានបត្រនិងបញ្ជាទូទាត់ជាអេឡិចត្រូនិក

**ខ- ប្រព័ន្ធសេវាទូទាត់រហ័ស** ត្រូវបានដាក់ឲ្យដំណើរការនៅខែកក្កដា ឆ្នាំ២០១៦ ដើម្បីផ្ទេរមូលនិធិភ្លាមៗ ជារូបិយវត្ថុជាតិរវាងគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលមានបណ្តាញសេវាទូទាំងប្រទេស ហើយបច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាបានជំរុញឲ្យគ្រឹះស្ថានជាសមាជិកពង្រីកបណ្តាញផ្តល់សេវាទូទាត់រហ័ស តាមរយៈប្រព័ន្ធអ៊ិនធឺណិតនិងទូរស័ព្ទចល័ត ដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជន និង

**គ- ប្រព័ន្ធខេមបូឌានស៊ែស្វិច** ត្រូវបានចាប់ផ្តើមដំណើរការបឋមនៅខែតុលា ឆ្នាំ២០១៧ ដើម្បីឲ្យអតិថិជនធ្វើប្រតិបត្តិការឆ្លងគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ តាមរយៈម៉ាស៊ីន ATM និង POS ដោយប្រើបណ្ណឥណពន្ធ។ ដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធខេមបូឌានស៊ែស្វិច ការដាក់បន្ថែមម៉ាស៊ីន ATM និង POS គប្បីត្រូវយកចិត្តទុកដាក់ ជាពិសេសនៅតំបន់ជនបទ។

ការជំរុញមធ្យោបាយប្រើប្រាស់បណ្តាញសេវាទូទាត់រហ័សនិងម៉ាស៊ីន ATM និង POS ជាកាតាលីករក្នុងការពង្រឹងអន្តរប្រតិបត្តិការ និងបង្កើនការប្រើប្រាស់ការទូទាត់ឌីជីថល។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានអនុញ្ញាតឲ្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ធនាគារឯកទេស និងប្រតិបត្តិករស្វិច ចូលជាសមាជិករបស់ប្រព័ន្ធទាំងនេះ ដើម្បីពង្រីកបណ្តាញផ្តល់សេវាឲ្យកាន់តែទូលំទូលាយដល់ជនបទ។

ចំពោះការទូទាត់តម្លៃធំ ធនាគារជាតិនៃកម្ពុជាកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ដុលភ្លាមៗ (RTGS) ដែលជាប្រព័ន្ធទូទាត់តម្លៃធំ (LVPS) ដើម្បីផាត់ទាត់និងទូទាត់ប្រតិបត្តិការដែលមានចំនួនប្រាក់ធំៗ។ ការដាក់ឲ្យប្រើប្រាស់ប្រព័ន្ធទូទាត់ដុលភ្លាមៗ នឹងកាត់បន្ថយហានិភ័យនៃការទូទាត់សងប្រាក់តម្លៃធំ។

**៧៦- ការពិនិត្យនិងសិក្សាលទ្ធភាពតភ្ជាប់ប្រព័ន្ធទូទាត់ជាមួយសមាគមអាស៊ាន** : ការតភ្ជាប់ប្រព័ន្ធទូទាត់ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធទូទាត់ក្នុងតំបន់ មានអត្ថប្រយោជន៍សម្រួលដល់ការទូទាត់ឆ្លងដែនឲ្យកាន់តែមានប្រសិទ្ធភាព។ ដើម្បីធ្វើសមាហរណកម្មប្រព័ន្ធទូទាត់ក្នុងស្រុកជាមួយប្រព័ន្ធទូទាត់ក្នុងតំបន់ ធនាគារជាតិនៃកម្ពុជាបានពិនិត្យលើការចូលរួមជាមួយបណ្តាញទូទាត់តំបន់អាស៊ីនិងការតភ្ជាប់ប្រព័ន្ធទូទាត់តម្លៃធំជាមួយនឹងប្រព័ន្ធទូទាត់ដុលភ្លាមៗ របស់សមាជិកអាស៊ាន។ បណ្តាញទូទាត់តំបន់អាស៊ី ផ្តោតលើការទូទាត់រាយជាពិសេស បណ្ណទូទាត់តាមម៉ាស៊ីន ATM និង POS។ ការតភ្ជាប់ជាមួយបណ្តាញទូទាត់តំបន់អាស៊ី ប្រាកដជាមានលទ្ធភាពកាត់បន្ថយច្រើនក្នុងការចំណាយសម្រាប់ការផ្ទេរប្រាក់អន្តរជាតិ តាមច្រកទូទាត់ក្នុងតំបន់។

**៧៧- បទប្បញ្ញត្តិផ្អែកលើទស្សនៈអនាគតសម្រាប់ជំរុញកំណើនទីផ្សារ** : កត្តាសំខាន់ដើម្បីធានាដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូទាត់រាយនៅកម្ពុជា គឺកិច្ចសហការរវាងនិយ័តករនិងវិស័យឯកជនក្នុងការដោះស្រាយបញ្ហាប្រឈមផ្នែកបទប្បញ្ញត្តិ។ បទប្បញ្ញត្តិផ្អែកលើទស្សនៈអនាគត ត្រូវយកចិត្តទុកដាក់លើអន្តរប្រតិបត្តិការរវាងបណ្តាញ ឧបករណ៍ និងប្រព័ន្ធទូទាត់ ជាមួយគ្នានេះក៏ត្រូវលើកកម្ពស់ការប្រកួតប្រជែងរវាងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដល់អតិថិជន។ បន្ថែមលើនេះ ដោយសារការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃវិស័យ បច្ចេកវិទ្យាសម្រាប់ការទូទាត់សងប្រាក់ បទប្បញ្ញត្តិត្រូវជំរុញការជ្រើសយកម៉ូដែលអាជីវកម្មថ្មីៗ និងនវានុវត្តន៍ឧបករណ៍ទូទាត់សងប្រាក់ដែលមានស្តង់ដាអន្តរជាតិនិងឧត្តមានុវត្ត។ ដោយសារមានការកើនឡើងនូវម៉ូដែលអាជីវកម្មថ្មីៗ

ចាំបាច់ត្រូវប្រែក្លាយតួនាទីភ្នាក់ងារធនាគារឲ្យមានលក្ខណៈផ្លូវការ ដែលនេះជាគំនិតផ្តួចផ្តើមក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។

**៧៨- យុទ្ធសាស្ត្របង្កើនការប្រើប្រាស់ប្រព័ន្ធទូទាត់ឌីជីថល :**

- ដាក់ឲ្យប្រើប្រាស់ប្រព័ន្ធទូទាត់ដុលភ្លាមៗ ដើម្បីកាត់បន្ថយហានិភ័យទូទាត់នៅក្នុងប្រព័ន្ធទូទាត់តម្លៃធំ
- លើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធសេវាទូទាត់រហ័សតាមបណ្តាញទូទាត់ផ្សេងៗ
- ដាក់ឲ្យប្រើប្រាស់ប្រព័ន្ធខេមបូខានស៊េរីស្វីច និងលើកទឹកចិត្តដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឲ្យពង្រីកហេដ្ឋារចនាសម្ព័ន្ធម៉ាស៊ីន ATM និង POS ដល់តំបន់ជនបទនិងដាច់ស្រយាល
- លើកកម្ពស់ការប្រើប្រាស់ឧបករណ៍ទូទាត់ និងបណ្តាញទូទាត់ដែលប្រកបដោយនវានុវត្តន៍
- ប្រែក្លាយតួនាទីភ្នាក់ងារធនាគារឲ្យមានលក្ខណៈផ្លូវការ
- លើកកម្ពស់ការទូទាត់ជាឌីជីថលរបស់រាជរដ្ឋាភិបាល
- ពិនិត្យនិងសិក្សាលទ្ធភាពតភ្ជាប់ប្រព័ន្ធទូទាត់ជាមួយសមាគមអាស៊ាន និង
- លើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងកិច្ចការពារអតិថិជនក្នុងវិស័យទូទាត់សងប្រាក់។

**ពង្រីកការផ្តល់សេវាធានារ៉ាប់រងឲ្យបានទូលំទូលាយ**

**៧៩- ការពង្រីកការធានារ៉ាប់រងជាកាតព្វកិច្ចនឹងជំរុញការប្រើប្រាស់សេវាធានារ៉ាប់រង :** ប្រទេសកម្ពុជាមានគម្រោងធានារ៉ាប់រងសង្គម ដូចជា ប្រាក់សោធននិវត្តន៍ ប្រាក់អត្ថប្រយោជន៍បន្ថែម ប្រាក់ឧបត្ថម្ភសុខភាព ប្រាក់ឧបត្ថម្ភគ្រោះថ្នាក់ការងារនិងជំងឺ និងនិកម្មភាព។ រាជរដ្ឋាភិបាលរួមចំណែករ៉ាប់រងចំណាយសម្រាប់និវត្តជន អតីតយុទ្ធជន ជនពិការ និងប្រជាជនក្រីក្រ។ បច្ចុប្បន្ន ការធានារ៉ាប់រងជាកាតព្វកិច្ចនៅកម្ពុជាត្រូវបានអនុវត្តចំពោះតែការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬធានារ៉ាប់រងតតិយជន(អនុវត្តសម្រាប់យានយន្តធ្វើអាជីវកម្មប៉ុណ្ណោះ) ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន និងការធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ (ច្បាប់ស្តីពីការធានារ៉ាប់រង ឆ្នាំ២០១៤)។ គម្រោងថែទាំសុខភាពកំពុងត្រូវបានពិនិត្យឡើងវិញ ដើម្បីតម្រូវឲ្យប្រជាជនគ្រប់រូបមានការធានារ៉ាប់រងសុខភាព។ ជាមួយគ្នានេះ គម្រោងថែទាំសុខភាពជាកាតព្វកិច្ចបានដាក់ឲ្យអនុវត្ត ដោយតម្រូវឲ្យនិយោជកទទួលយកកម្មវិធីធានារ៉ាប់រងថែទាំសុខភាពដែលគាំទ្រដោយរាជរដ្ឋាភិបាល សម្រាប់និយោជិតនិងក្រុមគ្រួសារផ្ទាល់(ប្តី ប្រពន្ធ និងកូន)។ ខណៈដែលការធានារ៉ាប់រងជាកាតព្វកិច្ចត្រូវបានអនុវត្តដោយប្រុងប្រយ័ត្ន ការធានារ៉ាប់រងនេះផ្តល់កាលានុវត្តភាពដើម្បីបញ្ចៀសឧបសគ្គក្នុងពេលដែលមានហានិភ័យសំខាន់ៗ និងត្រូវសិក្សាពីកាលានុវត្តភាពផ្សេងទៀត។ ការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តឬធានារ៉ាប់រងតតិយជនសម្រាប់យានយន្តឯកជន នឹងត្រូវដាក់ឲ្យអនុវត្តនិងកំពុងសិក្សាអំពីគំរូនៃការអនុវត្តនៅតាមបណ្តាប្រទេសនានាក្នុងតំបន់។

**៨០- ការលក់ផលិតផលធានារ៉ាប់រងជាកញ្ចប់ជួយទាក់ទាញអ្នកប្រើប្រាស់ :** ផលិតផលធានារ៉ាប់រងដែលផ្តល់ភ្ជាប់ជាមួយសេវាឬអត្ថប្រយោជន៍បន្ថែមផ្សេងៗ បង្កើនការលើកទឹកចិត្តក្នុងការប្រើប្រាស់សេវា

ធានារ៉ាប់រង។ ផលិតផលធានារ៉ាប់រងនៅកម្ពុជា ក្រៅពីផលិតផលធានារ៉ាប់រងជីវិតឥណទាន មិនត្រូវបានផ្តល់ជាកញ្ចប់ភ្ជាប់ជាមួយសេវាផ្សេងទៀតទេ។ ផលិតផលធានារ៉ាប់រងជាកញ្ចប់ផ្តល់កាលានុវត្តភាពក្នុងការពង្រីកផលិតផលសម្រាប់បំពេញតម្រូវការអតិថិជនលើសពីការធានារ៉ាប់រង ដែលបង្កើនការលើកទឹកចិត្តដល់ការប្រើប្រាស់សេវាធានារ៉ាប់រង ជាពិសេស នៅពេលដែលការសន្សំត្រូវបានដាក់បញ្ចូលក្នុងកញ្ចប់សេវា ដែលបង្កើតបានយ៉ាងមានប្រសិទ្ធភាពនូវផលិតផលធានារ៉ាប់រងទាយជ្ជទាន។ ជម្រើសក្នុងការបង្កើនការលើកទឹកចិត្តដល់ការប្រើប្រាស់សេវាធានារ៉ាប់រងត្រូវមានការសិក្សាបន្ថែម ជាពិសេស ក្នុងបរិការដែលអតិថិជនមានការយល់ដឹងតិចតួចអំពីការធានារ៉ាប់រង។ ការលើកទឹកចិត្តនេះត្រូវដាក់បញ្ចូលក្នុងយុទ្ធនាការដ៏មានប្រសិទ្ធភាពក្នុងការលើកកម្ពស់ការយល់ដឹង ដើម្បីធានាថាអតិថិជនបានយល់ពីអត្ថប្រយោជន៍នៃសេវាធានារ៉ាប់រង។

៨១- **ការកែសម្រួលវិធានពន្ធដារលើបុព្វលាភធានារ៉ាប់រង** : បច្ចុប្បន្ន មិនមានការលើកទឹកចិត្តផ្នែកពន្ធដារដល់ប្រជាជនមានប្រាក់ចំណូលដែលប្រើប្រាស់ធានារ៉ាប់រង លើកលែងតែក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត។ សេវាធានារ៉ាប់រងត្រូវបានចាត់ទុកជាអត្ថប្រយោជន៍បន្ថែមនិងត្រូវគិតពន្ធ២០%ពីអ្នកប្រើប្រាស់សេវា។ ដោយឡែកអ្នកផ្តល់សេវាដែលជាក្រុមហ៊ុនធានារ៉ាប់រងត្រូវបង់ពន្ធ៥%លើបុព្វលាភដុល។ ការធ្វើកំណែទម្រង់បទប្បញ្ញត្តិផ្នែកពន្ធ ដោយបែងចែកដើមទុន និងសេវាផ្តល់តម្លៃបន្ថែម ដែលជាចំណែកនៃបុព្វលាភធានារ៉ាប់រង និងសោហ៊ុយផ្សេងៗ គឺជាការចាំបាច់ដើម្បីឲ្យការគណនាពន្ធកាន់តែមានលក្ខណៈសមស្រប។ ការកំណត់ពន្ធមិនសមស្រប ជាពិសេស ពន្ធលើដើមទុននិងបុព្វលាភ អាចរារាំងដល់ការអភិវឌ្ឍវិស័យធានារ៉ាប់រង ហើយជាលទ្ធផល នឹងរាំងស្ទះដល់ការគរពូនដើមទុនរយៈពេលវែងរបស់ក្រុមហ៊ុនធានារ៉ាប់រង ដែលនៅប្រទេសជឿនលឿន ការគរពូនដើមទុននេះជាធាតុដ៏សំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។ ដោយសារការធានារ៉ាប់រងគឺជាការទិញដោយមិនស្ម័គ្រចិត្ត ដូច្នេះចាំបាច់ត្រូវបង្កើតយន្តការលើកទឹកចិត្ត ដើម្បីបង្កើនការប្រើប្រាស់សេវាធានារ៉ាប់រងដោយស្ម័គ្រចិត្ត។

៨២- **ពង្រឹងកិច្ចសហការរវាងអាជ្ញាធរពាក់ព័ន្ធ** : បច្ចុប្បន្ន វិស័យធានារ៉ាប់រងស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានធានារ៉ាប់រង និងសោធននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ លើសពីនេះ គ្រឹះស្ថានធនាគារដែលមានបំណងផ្តល់សេវាធានារ៉ាប់រង ចាំបាច់ត្រូវសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់រាល់ការសហការជាដៃគូ ឬការលក់ផ្ទួបជាមួយសេវាហិរញ្ញវត្ថុផ្តល់ដោយគ្រឹះស្ថានធនាគារ។ ដូចគ្នានេះ ដើងសានិងភ្នាក់ងារធានារ៉ាប់រងដែលមានទំនាក់ទំនងអាជីវកម្មជាមួយក្រុមហ៊ុនធានារ៉ាប់រង ស្ថិតនៅក្រោមច្បាប់ស្តីពីធានារ៉ាប់រង និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ។ ការពង្រឹងកិច្ចសហការរវាងអាជ្ញាធរពាក់ព័ន្ធ និងការបង្កើតមជ្ឈមណ្ឌលឧត្តមភាព ក្នុងការរៀបចំបទប្បញ្ញត្តិរួមគ្នានឹងបង្កើនសុក្រឹតភាពនៃបទប្បញ្ញត្តិដែលពាក់ព័ន្ធ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥ បានលើកឡើងពីតម្រូវការសម្រាប់ការពិនិត្យ និងធ្វើបច្ចុប្បន្នកម្មប្រកាសដែលពាក់ព័ន្ធនឹងការអនុវត្តជាក់ស្តែងក្នុងទីផ្សារ។ សមត្ថភាពរបស់អង្គភាពត្រួតពិនិត្យវិស័យធានារ៉ាប់រង ត្រូវចាត់ទុកជាផ្នែកមួយនៃដំណើរការនេះ

ជាពិសេស ដោយគិតអំពីតម្រូវការនៃវិស័យធានារ៉ាប់រងដែលកំពុងរីកចម្រើននិងបង្កើនចំនួនប្រតិបត្តិករ។ ការដាក់ចេញបទប្បញ្ញត្តិច្បាស់លាស់និងទាន់ពេលវេលា ពិតជាមានសារៈសំខាន់ក្នុងការគាំទ្រដល់ការពង្រីកទីផ្សារធានារ៉ាប់រង។

**៨៣- យុទ្ធសាស្ត្រពង្រីកការផ្តល់សេវាធានារ៉ាប់រង :**

- រៀបចំសេចក្តីព្រាងបទប្បញ្ញត្តិសំខាន់ៗសម្រាប់វិស័យធានារ៉ាប់រងខ្នាតតូច
- ពិនិត្យលទ្ធភាពកែសម្រួលរបបពន្ធពាក់ព័ន្ធនឹងវិស័យធានារ៉ាប់រង
- បង្កើតយន្តការការពារអ្នកប្រើប្រាស់ដើម្បីធានាសុវត្ថិភាពនិងដោះស្រាយបណ្តឹងអតិថិជន និង
- ពង្រឹងកិច្ចការពារអ្នកប្រើប្រាស់ តាមរយៈការផ្តល់អាទិភាពចំពោះការផ្តល់កម្ចី ការផ្សព្វផ្សាយផលិតផល បណ្តឹងតវ៉ា កម្រៃសេវា អត្រាការប្រាក់ និងបែបបទនៃការប្រមូល។

**ការលើកកម្ពស់សិទ្ធិនិងបង្កើនកិច្ចការពារអតិថិជន ព្រមទាំងបង្កើនតម្លាភាពក្នុងវិស័យហិរញ្ញវត្ថុ**

**៨៤- ការជំរុញយុទ្ធនាការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ :** ដោយសារប្រទេសកម្ពុជាមានអត្រាចំណេះដឹងផ្នែកហិរញ្ញវត្ថុ១៨% យុទ្ធនាការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុគឺមានសារៈសំខាន់យ៉ាងខ្លាំង។ ធនាគារជាតិនៃកម្ពុជាបានធ្វើយុទ្ធនាការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ដោយយកចិត្តទុកដាក់លើសិទ្ធិនិងកិច្ចការពារអតិថិជន ព្រមទាំងបង្កើនតម្លាភាពក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងជួយដល់ក្រុមអតិថិជនដែលងាយរងគ្រោះ។ ជាក់ស្តែង យុទ្ធនាការ "តោះ!និយាយពីលុយ" ដែលបានចាប់ផ្តើមនៅឆ្នាំ២០១៦ ត្រូវបានរៀបចំឡើងដើម្បីជួយអតិថិជនឲ្យយល់ដឹងពីសិទ្ធិក្នុងការប្រើប្រាស់ ជ្រើសរើស ចរចា និងប្រាស្រ័យទាក់ទង សំដៅសម្រេចចិត្តផ្នែកហិរញ្ញវត្ថុឲ្យបានប្រសើរ។ កត្តាទាំងនេះគឺជាជំហានឆ្ពោះទៅរកទិសដៅដ៏ត្រឹមត្រូវ។ ការខិតខំប្រឹងប្រែងទាំងនេះកាន់តែទទួលបានលទ្ធផលល្អប្រសើរតាមរយៈ ១)- ការដាក់ចេញបទប្បញ្ញត្តិនានា ដូចជា រយៈពេលដែលអ្នកស្នើសុំខ្ចីអាចបដិសេធឥណទានដោយមិនទទួលរងពិន័យ អត្រាការប្រាក់អប្បបរមា និងអនុបាតនៃការឲ្យខ្ចី និង ២)- វិធានការដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលនិងរៀបចំបំណុលឡើងវិញ ដូចជា ច្បាប់ក្ស័យធនដែលអនុញ្ញាតឲ្យមានជម្រើសប្រមូលបំណុលក្រៅប្រព័ន្ធតុលាការ។ លើសពីនេះ ការជំរុញឥណទានសម្រាប់ការវិនិយោគ ជាជាងសម្រាប់ការប្រើប្រាស់ គួរត្រូវបានពន្លឿន។ ទោះយ៉ាងណា ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុនៅកម្ពុជាមិនអាចធ្វើទៅបានដោយនិយ័តករតែឯងទេ ត្រូវមានការចូលរួមពីគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការដែលនឹងទទួលបានអត្ថប្រយោជន៍ពីចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងរក្សាបាននូវអតិថិជនរបស់គ្រឹះស្ថាន។ គំនិតផ្តួចផ្តើមយុទ្ធនាការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ គួរផ្តោតលើអតិថិជនដែលមានលទ្ធភាពស្រូបយកចំណេះដឹង និងធ្វើឡើងតាមរយៈគ្រឹះស្ថាន ដើម្បីធានានូវការយល់ដឹង ការរក្សា និងការប្រើប្រាស់ព័ត៌មានដែលបានផ្សព្វផ្សាយ។ ការពង្រឹងប្រព័ន្ធទំនាក់ទំនងរបស់គ្រឹះស្ថាន គឺមានសារៈសំខាន់សម្រាប់ផ្សារភ្ជាប់ជាមួយអតិថិជនឲ្យកាន់តែប្រសើរ។ ការប្រាស្រ័យទាក់ទងជាមួយអតិថិជន ដែលមានលក្ខណៈសាមញ្ញ តម្លាភាព និងសមស្រប អាចជំនះឧបសគ្គចំណេះដឹងផ្នែកហិរញ្ញវត្ថុ ដោយមិនចាំបាច់តម្រូវឲ្យអតិថិជនមានជំនាញខ្ពស់

ផ្នែកហិរញ្ញវត្ថុ។ សហគ្រិនជាស្ត្រីដែលមានសក្តានុពលខ្ពស់ ចាំបាច់ត្រូវកសាងសមត្ថភាពផ្នែកហិរញ្ញវត្ថុ និងជំនាញគ្រប់គ្រង តាមរយៈការអនុវត្តចំណេះដឹងផ្នែកហិរញ្ញវត្ថុ។ ជាមួយគ្នានេះ បទប្បញ្ញត្តិ និងយន្តការការពារអតិថិជនផ្តោតលើយេនឌ័រមានសារៈសំខាន់ណាស់ ដើម្បីធានាសុវត្ថិភាពនិងដោះស្រាយការកេងប្រវ័ញ្ចលើការផ្តល់សេវាហិរញ្ញវត្ថុ។

**៨៥- ពង្រឹងបទប្បញ្ញត្តិកិច្ចការពារអតិថិជន** : ការអនុម័តនិងដាក់ឲ្យអនុវត្តបទប្បញ្ញត្តិដ៏រឹងមាំ ស្តីពីកិច្ចការពារអតិថិជន និងឧបាស្រ័យ ជាគន្លឹះសំខាន់ដើម្បីបង្កើនការប្រើប្រាស់សេវាហិរញ្ញវត្ថុ និងការចូលរួម និងទំនាក់ទំនងរបស់អតិថិជនជាមួយគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ។ យន្តការការពារអតិថិជនចាំបាច់ត្រូវមានការធានាសុវត្ថិភាព និងដំណោះស្រាយលើការកេងប្រវ័ញ្ចដល់អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ។ លើសពីនេះ ដោយសារការប្រើប្រាស់ឥណទានមានកម្រិតខ្ពស់ យន្តការការពារត្រូវធានាថាអ្នកប្រើប្រាស់ដែលមិនមានតម្រូវការឥណទាន ឬមិនមានលទ្ធភាពសង មានជម្រើសក្នុងការបដិសេធឥណទាន។ ដោយសារចំណេះដឹងផ្នែកហិរញ្ញវត្ថុមានកម្រិតទាប បទប្បញ្ញត្តិត្រូវធានាថា គ្រឹះស្ថានបានផ្តល់ព័ត៌មានដល់អតិថិជនប្រកបដោយភាពច្បាស់លាស់និងងាយយល់។ ក្រៅពីការផ្តល់លទ្ធភាពឲ្យអ្នកប្រើប្រាស់ទទួលព័ត៌មានក្នុងការសម្រេចចិត្តបានត្រឹមត្រូវ បទប្បញ្ញត្តិក៏ត្រូវបង្កើតបរិយាកាសប្រកួតប្រជែងសមស្របសម្រាប់គ្រឹះស្ថាន។

**៨៦- យន្តការដោះស្រាយវិវាទដែលមានប្រសិទ្ធភាព** : បញ្ហាប្រឈមចម្បងចំពោះការផ្តល់ឥណទានធានាដោយអចលនវត្ថុ គឺនីតិវិធីតុលាការមានភាពស្មុគស្មាញក្នុងការដោះស្រាយវិវាទ និងជម្លោះពាណិជ្ជកម្ម។ បញ្ហាផ្នែកច្បាប់ភាគច្រើនពាក់ព័ន្ធនឹងទ្រព្យធានាដែលត្រូវចំណាយពេលពី២ទៅ៣ឆ្នាំ មុនពេលបញ្ហានេះត្រូវបានដោះស្រាយតាមប្រព័ន្ធតុលាការ និងអាចចំណាយពេលដោះស្រាយរហូតដល់៥ឆ្នាំ។ គ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការភាគច្រើនជ្រើសយកការដោះស្រាយបញ្ហាឥណទានក្រៅប្រព័ន្ធតុលាការ ដូចជា ផ្តល់បុនហិរញ្ញប្បទាន ឬសម្របសម្រួលជាមួយអតិថិជនដើម្បីលក់ទ្រព្យធានាសងបំណុល[៣]។ ការដោះស្រាយបណ្តឹងតាមនីតិវិធីច្បាប់ចំពោះឥណទានតូចៗ ជាទូទៅ មានចំណាយច្រើនជាងទឹកប្រាក់ឥណទាន។ ដូច្នេះ ដើម្បីកាត់បន្ថយហានិភ័យឲ្យបានជាអតិបរមា គ្រឹះស្ថានដែលផ្តល់ឥណទានតម្រូវឲ្យអ្នកខ្ចីមានទ្រព្យធានាគ្រប់គ្រាន់សម្រាប់សងបំណុលនិងចំណាយក្នុងការលក់ទ្រព្យធានានិងលទ្ធភាពសងបំណុល។ បច្ចុប្បន្ន ការដោះស្រាយវិវាទ និងជម្លោះពាណិជ្ជកម្មផ្សេងៗ ពឹងផ្អែកតែលើប្រព័ន្ធតុលាការ ដែលនេះជាកាលានុវត្តភាពក្នុងការធ្វើឲ្យប្រសើរឡើងនូវយន្តការដោះស្រាយវិវាទ។ គំនិតផ្តួចផ្តើមដ៏មានសក្តានុពលគឺការបង្កើតយន្តការច្បាស់លាស់ដើម្បីដោះស្រាយវិវាទក្នុងវិស័យហិរញ្ញវត្ថុ តាមរយៈអាជ្ញាធរមានសមត្ថកិច្ចដោះស្រាយបណ្តឹងសាធារណៈ មជ្ឈត្តករនិង/ឬតុលាការពាណិជ្ជកម្ម និងតុលាការអ្នកប្រើប្រាស់ឬដំណើរការសវនាការដែលប្រើរយៈពេលខ្លី។ យន្តការនេះអាចមានចំណាយសមស្របនិងដោះស្រាយវិវាទបានទាន់ពេលវេលារវាងអ្នកប្រើប្រាស់និងគ្រឹះស្ថាន។

៨៧- យុទ្ធសាស្ត្រលើកកម្ពស់សិទ្ធិនិងបង្កើនកិច្ចការពារអតិថិជន ព្រមទាំងបង្កើនតម្លាភាពក្នុងវិស័យហិរញ្ញវត្ថុ :

- គាំទ្រក្រសួងអប់រំ យុវជន និងកីឡា ដើម្បីដាក់បញ្ចូលចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សា
- ពិនិត្យឡើងវិញនូវប្រសិទ្ធភាពរបស់កម្មវិធីចំណេះដឹងផ្នែកហិរញ្ញវត្ថុបច្ចុប្បន្ននិងអភិវឌ្ឍយុទ្ធសាស្ត្ររយៈពេលវែង ដោយផ្តោតលើអតិថិជនដែលមានចំណូលទាប
- រៀបចំប្រកាសពាក់ព័ន្ធនឹងកិច្ចការពារអតិថិជនក្នុងវិស័យហិរញ្ញវត្ថុ ឲ្យស្របទៅនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ដែលនឹងត្រូវបង្កើតឡើងនាពេលខាងមុខ
- ពិនិត្យលទ្ធភាពនៃការកំណត់អាជ្ញាយុកាលបំណុល ដើម្បីតាមដានការផ្តល់ឥណទានលើសលប់ និង
- អភិវឌ្ឍយន្តការច្បាស់លាស់សម្រាប់ដោះស្រាយវិវាទ។

## IV. ការកសាងសមត្ថភាព

**៨៨- ផែនការអភិវឌ្ឍន៍ជំនាញបច្ចេកទេសជាការចាំបាច់ដើម្បីកសាងសមត្ថភាពនិយ័តករនិងគ្រឹះស្ថាន :** ដោយសារជំនាញក្នុងវិស័យហិរញ្ញវត្ថុគ្រប់កម្រិតនៅមានការខ្វះខាត យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ បានកំណត់អាទិភាពក្នុងការវាយតម្លៃតម្រូវការបណ្តុះបណ្តាលជំនាញហិរញ្ញវត្ថុ សម្រាប់គ្រប់វិស័យ។ ការណ៍នេះនឹងធានាបាននូវធនធានគ្រប់គ្រាន់សម្រាប់គាំទ្រមុខងារវិស័យហិរញ្ញវត្ថុ និងលទ្ធភាពក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុបន្ថែមទៀត។ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវការមានកាតព្វកិច្ចរៀបចំនិងអនុវត្តនីតិវិធីក្នុងការកសាងសមត្ថភាពផងដែរ។

**៨៩- ការកសាងសមត្ថភាពនិយ័តករ :** ការកើនឡើងចំនួនអ្នកផ្តល់សេវាហិរញ្ញវត្ថុនិងការពង្រីកសេវាហិរញ្ញវត្ថុនិងសំពៀតឥណទាន ទាមទារឲ្យមានការតាមដាននិងត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ដែលជាបញ្ហាប្រឈមដ៏ចម្បងចំពោះនិយ័តករ។ ដោយសារធនធានមនុស្សនិងហិរញ្ញវត្ថុនៅមានកម្រិត ចាំបាច់ត្រូវមានការវិនិយោគលើជំនាញបច្ចេកទេសរបស់និយ័តករ ដើម្បីតាមដាននិងត្រួតពិនិត្យវិស័យហិរញ្ញវត្ថុឲ្យកាន់តែមានប្រសិទ្ធភាព។ ផ្អែកលើស្ថានភាពបច្ចុប្បន្ន សមត្ថភាពនិយ័តករធានារ៉ាប់រងស្ថិតនៅក្នុងកម្រិតមួយមិនទាន់សមស្របទៅនឹងនិន្នាការនៃការវិវត្តរបស់ឧស្សាហកម្មធានារ៉ាប់រង។ កត្តានេះហើយនាំទៅដល់ការគិតគូរលើការបង្កើនសមត្ថភាពនៃអ្នកត្រួតពិនិត្យ ស្តីពីការត្រួតពិនិត្យដោយផ្អែកលើហានិភ័យ ជំនាញត្រួតពិនិត្យលើសេវា ជំនាញពាក់ព័ន្ធនឹងការផ្សះផ្សាវិវាទ និងបង្កើនសមត្ថភាពមន្ត្រីពាក់ព័ន្ធនឹងជំនាញបច្ចេកទេសផ្សេងៗ ដូចជា ជំនាញគណនាតម្លៃហានិភ័យធានារ៉ាប់រង និងជំនាញវាយតម្លៃហានិភ័យធានារ៉ាប់រងជាដើម។ នៅក្នុងវិស័យធានារ៉ាប់រង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគ្រោងបង្កើនការយល់ដឹងជាសាធារណៈ ក្នុងគោលបំណងលើកកម្ពស់ គាំទ្រ និងជំរុញការប្រើប្រាស់សេវាធានារ៉ាប់រង។ ដើម្បីបំពាក់បំប៉នជំនាញនិងពង្រឹងសមត្ថភាពអ្នកផ្តល់សេវាក្នុងស្រុក និយ័តករអាចតម្រូវឲ្យមានការបណ្តុះបណ្តាលជាកាតព្វកិច្ចឬស្ម័គ្រចិត្ត ដោយមានឧបត្ថម្ភធន សម្រាប់ភ្នាក់ងារ ជើងសា និងបុគ្គលិកក្រុមហ៊ុនធានារ៉ាប់រង។

**៩០- ការពង្រឹងការអនុវត្តបទប្បញ្ញត្តិ** : វិស័យហិរញ្ញវត្ថុកំពុងមានការវិវឌ្ឍយ៉ាងឆាប់រហ័ស តាមរយៈបច្ចេកវិទ្យាឌីជីថល ដែលទាមទារឲ្យមានការត្រៀមលក្ខណៈសមស្រប។ ម្យ៉ាងវិញទៀត របាយការណ៍វិភាគស្ថានភាពបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៧ លើការរាយការណ៍អំពីឥណទាន ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងសហគមន៍ សង្គហសមាគម ការដោះស្រាយបណ្ដឹងអតិថិជន និងការដោះស្រាយវិវាទជាដើម បានបង្ហាញថាគ្រឹះស្ថានពុំបានអនុវត្តតាមបទប្បញ្ញត្តិប្រកបដោយប្រសិទ្ធភាពជាប្រចាំនោះទេ។ និយ័តករត្រូវរៀបចំផែនការ និងបង្កើនសមត្ថភាព ដើម្បីពង្រឹងការអនុវត្តបទប្បញ្ញត្តិឲ្យបានត្រឹមត្រូវនិងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព។

**៩១- ការកសាងសមត្ថភាពគ្រឹះស្ថាន** : ការអភិវឌ្ឍជំនាញវិស័យហិរញ្ញវត្ថុគួរត្រូវកំណត់អាទិភាពដើម្បីធ្វើឲ្យប្រសើរឡើងនូវការផ្ដល់សេវាហិរញ្ញវត្ថុជូនអតិថិជន និងការបណ្ដុះបណ្ដាលក្នុងការចែកចាយសេវាហិរញ្ញវត្ថុទៅតាមតម្រូវការរបស់អតិថិជន និងអាជីវកម្ម។ វិទ្យាស្ថានធនាគារនិងហិរញ្ញវត្ថុកម្ពុជារបស់សមាគមធនាគារនៅកម្ពុជាត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៦ មានបេសកកម្មរួមចំណែកដល់វឌ្ឍនភាពនៃការសិក្សានិងការបណ្ដុះបណ្ដាលនាយកគ្រប់គ្រងជាន់ខ្ពស់និងអ្នកជំនាញ តាមរយៈកម្មវិធីបណ្ដុះបណ្ដាលស្របតាមតម្រូវការ និងដោយមានការសហការជាមួយភាគីពាក់ព័ន្ធ។ មូលនិធិអភិវឌ្ឍន៍ត្រូវបានបង្កើតឡើងដើម្បីជំរុញការអភិវឌ្ឍចំណេះដឹង ដោយផ្ដល់ជូនកម្មវិធីដែលមានការទទួលស្គាល់និងមានគុណភាព និងតាមរយៈការឧបត្ថម្ភធន ដើម្បីទ្រទ្រង់តម្រូវការផ្នែកហិរញ្ញវត្ថុសម្រាប់ធនធានមនុស្សនៅក្នុងវិស័យនេះ និងសម្រាប់គំនិតផ្ដួចផ្ដើមសំខាន់ៗដទៃទៀតក្នុងវិស័យធនាគារ ដូចជា ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ការស្រាវជ្រាវការអង្កេត ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធនាគារ និងអាហារូបករណ៍ ជាដើម។

**៩២- យុទ្ធសាស្ត្របង្កើនសមត្ថភាព៖**

- បង្កើនការតាមដាន ការពង្រឹង និងនវានុវត្តន៍ឈានមុខក្នុងវិស័យហិរញ្ញវត្ថុ
- ពង្រឹងសមត្ថភាពត្រួតពិនិត្យនិងបច្ចេកទេសរបស់និយ័តករ និងសមត្ថភាពបច្ចេកទេសរបស់គ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ និង
- ជំរុញការវិនិយោគបន្ថែមលើការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យហិរញ្ញវត្ថុ។

# ជំពូក៥

# ការអនុវត្តយុទ្ធសាស្ត្របរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥

## I. អត្ថប្រយោជន៍ដែលរំពឹងទុក

**៩៣-** បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជាមានកម្រិតល្អ សំដៅដល់ការទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ លើកលែងតែការប្រើប្រាស់សេវាធានារ៉ាប់រងដែលនៅមានកម្រិតទាបនៅឡើយ[៣៧]។ ការទទួលបាននិងការប្រើប្រាស់សេវាហិរញ្ញវត្ថុមានសក្តានុពលក្នុងការលើកកម្ពស់សុខុមាលភាពទូទៅរបស់ប្រជាជន និងជំរុញឲ្យមានកំណើនសេដ្ឋកិច្ច បង្កើតការងារ និងអភិវឌ្ឍធនធានមនុស្ស។ ក្នុងស្ថានភាពបច្ចុប្បន្ន ការស្ថិតនៅឆ្ងាយរបស់អ្នកផ្តល់សេវាហិរញ្ញវត្ថុ និងកង្វះសេវាហិរញ្ញវត្ថុសមស្របតាមតម្រូវការ នៅតែជាបញ្ហាសម្រាប់ប្រជាជនពេញវ័យ ហើយការមានចំណេះដឹងផ្នែកហិរញ្ញវត្ថុតិចតួច ក៏ជាកត្តាធ្វើឲ្យការប្រើប្រាស់សេវាហិរញ្ញវត្ថុនៅមានកម្រិតទាបផងដែរ។ សកម្មភាពដែលស្នើឡើងនៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ មានបំណងដោះស្រាយបញ្ហាទាំងនេះ និងផ្តល់អត្ថប្រយោជន៍ជាក់លាក់មួយចំនួនដូចខាងក្រោម៖

**៩៤-** ការបង្កើតឲ្យមានសេវាសន្សំ សេវាឥណទាន សេវាទូទាត់ និងសេវាធានារ៉ាប់រង ដែលមានតម្លៃសមរម្យតាមរយៈបណ្តាញចែកចាយប្រសើរជាងមុន នឹងជួយឲ្យប្រជាជនបង្កើនការប្រើប្រាស់ និងមានលទ្ធភាពធ្វើពិពិធកម្មហានិភ័យ និងគ្រប់គ្រងហិរញ្ញវត្ថុកាន់តែប្រសើរ។ នៅពេលគ្រួសារអាចគ្រប់គ្រងលំហូរសាច់ប្រាក់ កាត់បន្ថយហានិភ័យ ចាយវាយត្រឹមត្រូវ និងបង្កើនទម្លាប់សន្សំកាន់តែប្រសើរ ការណ៍នេះនឹងជួយពង្រឹងសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់។

**៩៥-** ការបង្កើតឲ្យមានមធ្យោបាយទូទាត់ឌីជីថលដែលមានប្រសិទ្ធភាពនិងតម្លៃទាប នឹងជួយសម្រួលដល់ការផ្ទេរប្រាក់ក្នុងស្រុកនិងអន្តរជាតិដែលមានឥទ្ធិពលខ្លាំងមកលើប្រជាជន ដែលភាគច្រើនពឹងផ្អែកលើការផ្ទេរប្រាក់ជាប្រភពចំណូលទី២។

**៩៦-** យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ និងផែនការសកម្មភាព នឹងជួយសម្រួលដល់ការបង្កើតក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ។ ការណ៍នេះ រួមជាមួយការពង្រឹងសមត្ថភាពជំនាញរបស់និយ័តករនឹងជួយជំរុញកំណើនវិស័យហិរញ្ញវត្ថុ រួមទាំង វិស័យធានារ៉ាប់រង និងទូទាត់ចល័ត ជាមួយបណ្តាញផ្តល់សេវាប្រកបដោយប្រសិទ្ធភាព ដល់ប្រជាជនដែលទទួលបានសេវាហិរញ្ញវត្ថុតិចតួច និងមិនទាន់ទទួលបានសេវាហិរញ្ញវត្ថុ។ ភាពប្រសើរឡើងនៃបរិយាបន្នហិរញ្ញវត្ថុនឹងជួយដល់កំណើនសេដ្ឋកិច្ច និងគាំទ្រដល់ការកាត់បន្ថយវិសមភាពប្រាក់ចំណូល។

**៩៧-** ផែនការសកម្មភាពនឹងជួយគាំទ្រដល់ការកំណត់និងតាមដានប៉ារ៉ាម៉ែត្រ ដើម្បីវាស់វែងកម្រិតបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា ដូចមានបង្ហាញក្នុងយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥។

## II. ផែនការសកម្មភាពក្នុងបរិបទគោលនយោបាយហិរញ្ញវត្ថុបច្ចុប្បន្ន

គោលនយោបាយបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា ផ្អែកលើឯកសារគោលនយោបាយសំខាន់ៗ ដូចខាងក្រោម :

៩៨- **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤សម្រាប់នីតិកាលទី៦នៃរដ្ឋសភា** ជាយុទ្ធសាស្ត្ររួមដែលដឹកនាំការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជាដែលសមាសធាតុ រួមមានកំណើនសេដ្ឋកិច្ច ភាពមានការងារធ្វើ សមភាព និងប្រសិទ្ធភាព។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក៏មានគោលបំណងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ពិសេសការផ្តល់សេវាហិរញ្ញវត្ថុខ្នាតតូច និងមធ្យម ព្រមទាំងសេវាឥណទានជនបទសម្រាប់សហគ្រាសធុនតូចនិងមធ្យម និងប្រជាជនដែលមានចំណូលទាប ក្នុងអត្រាការប្រាក់សមរម្យ និងបន្តពង្រឹង និងពង្រីកផលិតផលធានារ៉ាប់រងថ្មីៗ ពិសេសសេវាធានារ៉ាប់រងអាយុជីវិត និងធានារ៉ាប់រងខ្នាតតូច។

៩៩- **ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រថ្នាក់ជាតិ ឆ្នាំ២០១៤-២០១៨** មានគោលដៅលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុតាមរយៈការទទួលបានឥណទានដែលមានតម្លៃសមរម្យ ដោយពង្រីកទាំងវិសាលភាពនិងតំបន់ប្រតិបត្តិការនៃវិស័យមីក្រូហិរញ្ញវត្ថុ ដើម្បីផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាជន និងសហគ្រាសធុនតូចនិងមធ្យម។

១០០- **គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥** កំណត់អាទិភាពក្នុងការពង្រឹងយន្តការហិរញ្ញប្បទានក្នុងស្រុក និងធានាឲ្យមានឥណទានគ្រប់គ្រាន់ដែលមានអត្រាការប្រាក់សមរម្យ។ ការបង្កើតយន្តការសន្សំនិងហិរញ្ញប្បទានតាមតម្រូវការ នឹងផ្តល់អត្ថប្រយោជន៍ច្រើនជាងមុនដល់អ្នកប្រើប្រាស់។

១០១- **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥** លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុតាមរយៈការពង្រីកសេវាមីក្រូហិរញ្ញវត្ថុដែលផ្តោតលើប្រជាជនក្រីក្រ សហគមន៍កសិកម្ម និងសហគ្រាសធុនតូចនិងមធ្យម។ ការពង្រីកសេវានេះរួមមាន ការធ្វើពិពិធកម្មឧបករណ៍និងសេវាហិរញ្ញវត្ថុ ដែលមានតម្លៃសមរម្យនិងលក្ខខណ្ឌសមស្រប។ យុទ្ធសាស្ត្រនេះ ក៏ពង្រីកវិសាលភាពធានារ៉ាប់រងជាកាតព្វកិច្ច តាមរយៈការអភិវឌ្ឍ និងលើកកម្ពស់ក្របខ័ណ្ឌបទប្បញ្ញត្តិ និងពង្រឹងសមត្ថភាពនិយ័តករ។ ជាងនេះទៀត ប្រព័ន្ធសំណាញ់សុវត្ថិភាពសង្គមនឹងត្រូវបានពង្រឹងតាមរយៈការធ្វើមជ្ឈការនិងសមាហរណកម្មនៃប្រព័ន្ធនេះ។

១០២- **គោលនយោបាយ ស្តីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅដ្ឋានតម្លៃសមរម្យ** មានគោលបំណងដោះស្រាយបញ្ហាលំនៅឋាន ហើយនឹងក៏រួមចំណែកលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ដោយជំរុញឲ្យគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ ជាពិសេស ធនាគារពាណិជ្ជអាចផ្តល់ហិរញ្ញប្បទានជូនប្រជាជនដែលពុំមានលទ្ធភាពគ្រប់គ្រាន់ មានប្រាក់ចំណូលទាប និង/ឬមិនមានបណ្ណកម្មសិទ្ធិដីធ្លី ដែលមិនអាចឲ្យពួកគាត់អាចខ្ចីឥណទានពីធនាគារដើម្បីទិញលំនៅឋានជាដើម។ ដើម្បីសម្រេចបានគោលបំណងខាងលើ រាជរដ្ឋាភិបាលតាមរយៈគោលនយោបាយនេះ នឹងដោះស្រាយនូវបញ្ហាតាមរយៈ៤ចំណុចៈ ១)- កាត់បន្ថយថ្លៃដើមដើម្បីឲ្យតម្លៃអចលនទ្រព្យអាចលក់បានក្នុងកម្រិតតម្លៃសមរម្យ ដោយផ្តល់ការលើកទឹកចិត្តជូនអ្នកអភិវឌ្ឍលំនៅឋាន តាមរយៈការបន្ធូរបន្ថយផ្នែកសារពើពន្ធ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងការសម្រួលបន្ទុកនិយ័តកម្ម ២)- សិក្សាអំពីវិធានអប្បបរមានៃការអនុលោមតាម សម្រាប់អ្នកផ្តល់កម្ចីតាមតម្រូវការភ្លាមៗ

បន្ទាប់បន្សំនៅក្រោមបទប្បញ្ញត្តិសមស្រប ៣)- ជាមួយនឹងលទ្ធភាពក្នុងការកាន់កាប់ផ្ទះផ្ទាល់ខ្លួន គ្រួសារជាច្រើនអាចនឹងលើកទឹកចិត្តបន្ថែមទៀតដើម្បីសន្សំប្រាក់ ដែលចំណុចនេះក៏អាចនឹងជួយលើកកម្ពស់វប្បធម៌នៃការសន្សំផងដែរ និង ៤)- នៅពេលម្ចាស់ផ្ទះទទួលបានបណ្ណកម្មសិទ្ធិដីធ្លី ពួកគេក៏អាចបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទានផ្សេងទៀតនៅពេលអនាគត ជាពិសេស នៅពេលតម្លៃផ្ទះរបស់ពួកគេមានការកើនឡើងជាបន្តបន្ទាប់។

**១០៣-** បរិយាបន្នហិរញ្ញវត្ថុគឺជាការងារអាទិភាពរបស់រាជរដ្ឋាភិបាល ដោយយកចិត្តទុកដាក់លើការលើកកម្ពស់គំនិតផ្តួចផ្តើមដែលជំរុញឲ្យមានកំណើនប្រកបដោយចីរភាពនិងបរិយាបន្ន។ ធនាគារជាតិនៃកម្ពុជាបានចូលជាសមាជិករបស់សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុនៅឆ្នាំ២០១៥។ បច្ចុប្បន្ននេះ ធនាគារជាតិនៃកម្ពុជាកំពុងអនុវត្ត "យុទ្ធនាការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ" ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនិងជួយដល់អ្នកប្រើប្រាស់ដែលងាយរងគ្រោះ។ រាជរដ្ឋាភិបាលមានគោលដៅនឹងដាក់ចេញយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុនៅក្នុងរយៈពេលវែង។ ការដាក់បញ្ចូលបរិយាបន្នហិរញ្ញវត្ថុឲ្យទៅជាផ្នែកមួយនៃគោលនយោបាយអភិវឌ្ឍនឹងជួយជំរុញដល់ការអភិវឌ្ឍគោលនយោបាយបរិយាបន្នហិរញ្ញវត្ថុដែលលើកឡើងពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យហិរញ្ញវត្ថុ និងបណ្តាញផ្តល់សេវា ដែលនឹងបង្កើនដល់ការទទួលបានសេវាហិរញ្ញវត្ថុកាន់តែទូលំទូលាយ។

**១០៤-** យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ ប្រមូលផ្តុំរាល់កិច្ចខិតខំប្រឹងប្រែងលើបរិយាបន្នហិរញ្ញវត្ថុរបស់ស្ថាប័នរាជរដ្ឋាភិបាល ដើម្បីជាមូលដ្ឋានក្នុងការបង្កើតក្របខ័ណ្ឌជាយុទ្ធសាស្ត្រសម្រាប់ការអនុវត្ត។ យុទ្ធសាស្ត្រជាតិនេះត្រូវបានរៀបចំដោយផ្អែកលើការវិភាគលម្អិតនៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា និងតាមរយៈការកំណត់នូវចំណុចដែលមានសក្តានុពលខ្លាំង ព្រមទាំងមានការពិគ្រោះយោបល់ជាច្រើនជាមួយដៃគូពាក់ព័ន្ធ។ យុទ្ធសាស្ត្រជាតិនេះនឹងផ្តល់ជាវេទិកាប្រមូលផ្តុំកិច្ចខិតខំប្រឹងប្រែងរវាងស្ថាប័នរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍនានាក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងជួយផ្តល់ការណែនាំដល់គំនិតផ្តួចផ្តើមនាពេលអនាគតពាក់ព័ន្ធនឹងបរិយាបន្នហិរញ្ញវត្ថុ។

## III. ការអនុវត្ត និងការវាយតម្លៃ

**១០៥-** ក្រុមការងាររៀបចំយុទ្ធសាស្ត្របរិយាបន្នហិរញ្ញវត្ថុ(អន្តរក្រសួង)ទទួលខុសត្រូវលើការសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥។ ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ក្រសួងកិច្ចការនារី គណៈកម្មការមូលបត្រកម្ពុជា និងភាគីពាក់ព័ន្ធទាំងអស់ រួមមាន និយ័តករ គ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ ក្រសួងពាក់ព័ន្ធ និងអ្នកផ្តល់ជំនួយនឹងដើរតួនាទីស្នូលក្នុងការទទួលខុសត្រូវលើការអនុវត្ត។

## IV. ការទាស់ខែង

១០៦- ការអនុវត្តបានជោគជ័យពឹងផ្អែកមួយផ្នែកទៅលើលទ្ធភាពក្នុងការវាស់វែងវឌ្ឍនភាព ការដាក់ចេញនូវសកម្មភាពកែតម្រូវតាមការចាំបាច់ និងការពិភាក្សាអំពីលទ្ធផលនៃការធ្វើអន្តរាគមន៍នានា។ ក្របខ័ណ្ឌតាមដាននិងវាយតម្លៃ ចាំបាច់ត្រូវរៀបចំសម្រាប់វាស់វែងវឌ្ឍនភាពទូទាំងប្រទេស និងតាមដានរាល់សកម្មភាព លទ្ធផល និងសមិទ្ធផល។

## V. អ្នកសម្របសម្រួលការអនុវត្ត

**១០៧- បរិយាបន្នហិរញ្ញវត្ថុត្រូវបានអនុវត្តតាមរយៈកិច្ចសម្របសម្រួលដូចខាងក្រោម :**

- ការបង្កើនការចូលរួមពីវិស័យឯកជន តាមរយៈការបង្កើតសេវាហិរញ្ញវត្ថុថ្មីៗ ការលើកទឹកចិត្តឲ្យមានការបង្កើតសេវាហិរញ្ញវត្ថុដែលមានតម្លៃទាប និងការសហការពង្រីកសេវាហិរញ្ញវត្ថុបន្ថែមទៀត
- ការធ្វើកំណែទម្រង់ការិយាធិបតេយ្យដើម្បីបង្កើនឆន្ទៈក្នុងការអនុវត្តតាមអនុសាសន៍ និងការផ្តល់អាទិភាពខ្ពស់ដល់ការធ្វើកំណែទម្រង់ អាចលើកកម្ពស់ក្របខ័ណ្ឌគាំទ្រដែលចាំបាច់ក្នុងការជំរុញកិច្ចខិតខំប្រឹងប្រែងផ្នែកបរិយាបន្នហិរញ្ញវត្ថុ
- ការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធទូទាត់រាយ ដូចជា ម៉ាស៊ីន ATM ម៉ាស៊ីន POS និងទីតាំងសម្រាប់ដកប្រាក់ ជាដើម អាចសម្រួលដល់ការអនុវត្តប្រព័ន្ធអេកូទូទាត់ តាមរយៈការបង្កើនការធ្វើប្រតិបត្តិការឌីជីថល។ វិស័យឯកជនអាចជាអ្នកនាំមុខក្នុងការលើកកម្ពស់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូទាត់រាយ ដោយធនាគារជាតិនៃកម្ពុជាជាអ្នកបង្កើតឲ្យមានបរិយាកាសសមស្របសម្រាប់ការអភិវឌ្ឍ
- ការលើកកម្ពស់សមត្ថភាពនិយ័តករ និងការគាំទ្រដោយបទប្បញ្ញត្តិនានា អាចសម្រួលដល់ការអនុវត្តយុទ្ធសាស្រ្តជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ និង
- ការធានាបាននូវការផ្តល់របាយការណ៍ឥណទានរបស់គ្រឹះស្ថានហិរញ្ញវត្ថុឲ្យទាន់ពេលវេលាទៅកាន់ការិយាល័យព័ត៌មានឥណទានកម្ពុជា នឹងធ្វើឲ្យរបាយការណ៍និងការវិភាគឥណទានមានសុក្រឹតភាព ហើយអាចជួយកាត់បន្ថយឥណទានមិនល្អ។ ដូច្នេះ ព័ត៌មានឥណទានរបស់អ្នកខ្ចីអាចធ្វើជាមូលដ្ឋានសម្រាប់ការវាយតម្លៃឥណទាន។

# ជំពូក៦

# សេចក្តីសន្និដ្ឋាន

១០៨- ប្រជាជនពេញវ័យ២៩%មិនបានប្រើប្រាស់សេវាហិរញ្ញវត្ថុ ហើយប្រជាជនដែលទទួលបានសេវាហិរញ្ញវត្ថុនៅមានចំនួនតិចតួចនៅឡើយ។ ការពង្រីកវិសាលភាពនិងគុណភាពនៃការទទួលបានសេវាហិរញ្ញវត្ថុនឹងផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់ប្រជាជនដែលទទួលបានសេវាហិរញ្ញវត្ថុតិចតួច និងមិនបានប្រើប្រាស់សេវាហិរញ្ញវត្ថុ។ ដូច្នេះ ការពង្រីកនិងការបញ្ជ្រាបបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា គឺជាការងារអាទិភាព។ យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ បានដាក់ចេញនូវគោលដៅអាទិភាពថ្នាក់ជាតិសម្រាប់ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥។ ទោះយ៉ាងណា ការសម្រេចបានបរិយាបន្នហិរញ្ញវត្ថុជាការលំបាកដែលទាមទារឲ្យមានចក្ខុវិស័យច្បាស់លាស់ ធនធានគ្រប់គ្រាន់ និងការសហការដ៏មានប្រសិទ្ធភាពពីគ្រប់ភាគីពាក់ព័ន្ធ។

១០៩- យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ បានបង្ហាញសកម្មភាពអាទិភាពចំនួន៦ដែលអាចជួយដល់ភាគីពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ៖ ១)- លើកទឹកចិត្តឲ្យមានការសន្សំនៅតាមគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ ២)- ជំរុញនវានុវត្តន៍សេវាឥណទានសម្រាប់សហគ្រាសធុនតូចនិងមធ្យម ៣)- ពង្រីកសមត្ថភាពប្រព័ន្ធទូទាត់ ៤)- ពង្រីកការផ្តល់សេវាធានារ៉ាប់រងឲ្យបានទូលំទូលាយ ៥)- ពង្រឹងសមត្ថភាពនិយ័តករវិស័យហិរញ្ញវត្ថុ និង ៦)- លើកកម្ពស់សិទ្ធិនិងបង្កើនកិច្ចការពារអតិថិជន ព្រមទាំងបង្កើនតម្លាភាពក្នុងវិស័យហិរញ្ញវត្ថុ។

១១០- ការអនុវត្តដោយជោគជ័យនូវសកម្មភាពអាទិភាពទាំងនេះ នឹងផ្តល់ផលវិជ្ជមានដល់បរិយាបន្នហិរញ្ញវត្ថុ ហើយតាមរយៈនេះជួយដល់កំណើនសេដ្ឋកិច្ច និងសុខុមាលភាពសង្គម។ ទោះយ៉ាងណា ដើម្បីធានានូវការអនុវត្តតាមយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ ឲ្យបានជោគជ័យ ចាំបាច់ត្រូវយកចិត្តទុកដាក់លើហានិភ័យនានានិងកត្តាពាក់ព័ន្ធសំខាន់ៗ។

១១១- ការអនុវត្តសកម្មភាពទាំងនេះនឹងជួយបញ្ជ្រាបនិងពង្រីកសេវាហិរញ្ញវត្ថុនិងលើកកម្ពស់សុខុមាលភាពក្រុមគ្រួសារ ហើយទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចនិងចូលរួមអភិវឌ្ឍធនធានមនុស្ស។

១១២- ការអនុវត្តតាមយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ នឹងរួមចំណែកពិតប្រាកដដល់បរិយាបន្នហិរញ្ញវត្ថុ តាមរយៈការបង្កើតយុទ្ធសាស្ត្រ សេវាហិរញ្ញវត្ថុ និងម៉ូដែលអាជីវកម្ម ដែលមានគុណតម្លៃកាន់តែប្រសើរចំពោះប្រជាជនមានប្រាក់ចំណូលទាប។

១១៣- សកម្មភាពអាទិភាពនៅក្នុងយុទ្ធសាស្ត្រជាតិនេះ មានរៀបរាប់លម្អិតនៅក្នុងផែនការសកម្មភាព ដែលត្រូវរៀបចំជាផែនការអនុវត្តដើម្បីសម្រេចគោលដៅបរិយាបន្នហិរញ្ញវត្ថុ។

១១៤- បន្ទាប់ពីយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ ត្រូវបានអនុម័តនិងដាក់ចេញជាគោលនយោបាយ ហើយស្ថាប័នដឹកនាំការអនុវត្តមានភារកិច្ចសម្របសម្រួលការអនុវត្តផែនការសកម្មភាព និងធានាកិច្ចសហការរវាងភាគីពាក់ព័ន្ធទាំងអស់ ក្នុងការសម្រេចគោលដៅបរិយាបន្នហិរញ្ញវត្ថុ។ ធនាគារជាតិនៃកម្ពុជាដែលជាប្រធានក្រុមការងាររៀបចំយុទ្ធសាស្ត្របរិយាបន្នហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធ មានដូចជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងមហាផ្ទៃ ជាដើម ដើរតួនាទីដឹកនាំនិងសម្របសម្រួលការអនុវត្ត ដោយមានការគាំទ្រពីមូលនិធិអភិវឌ្ឍន៍មូលធនអង្គការសហប្រជាជាតិ។ ស្ថាប័នដឹកនាំនឹងមានក្រុមការងារជួយជ្រោមជ្រែងដំណើរការអនុវត្ត។ ការងារសំខាន់គឺការធានាការបែងចែកផែនការសកម្មភាពប្រកបដោយប្រសិទ្ធភាព និងការប្រឹក្សាយោបល់ជាមួយភាគីពាក់ព័ន្ធដើម្បីកំណត់ស្ថាប័នសមស្របក្នុងការដឹកនាំសកម្មភាពផ្សេងៗដែលមាននៅក្នុងផែនការសកម្មភាពនេះ។

# ជំពូក៧

## ផែនការសកម្មភាពសម្រាប់យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥

| សកម្មភាពអាទិភាព | រយៈពេលខ្លី (២០១៩-២០២០) | រយៈពេលមធ្យម (២០២១-២០២២) | រយៈពេលវែង (២០២៣-២០២៥) | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| I. វិស័យធនាគារ | | | | |
| **ក. គ្រឹះស្ថានធនាគារ** | | | | |
| **បង្កើនលទ្ធភាពទទួលបានសេវាឥណទានសម្រាប់សហគ្រាសធុនតូចនិងមធ្យម និងសហគមន៍អភិវឌ្ឍកសិកម្មនិងអភិវឌ្ឍជនបទ** | ១. ជំរុញនិងគាំទ្រដល់គ្រឹះស្ថានធនាគារក្នុងការបង្កើតសេវាឥណទានដោយគ្មានទ្រព្យធានាសម្រាប់សហគ្រាសធុនតូចនិងមធ្យម (ផ្អែកលើលំហូរសាច់ប្រាក់ ឬវិធីសាស្ត្រផ្សេងទៀត) | ២. គាំទ្រនិងជំរុញការផ្តល់ឥណទានផ្អែកលើសន្និធិ គណនីត្រូវទទួល និងហ្វាក់ធើរីង សម្រាប់សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ព្រមទាំងសហគ្រាសបម្រើប្រយោជន៍សង្គម | | • ធនាគារជាតិនៃកម្ពុជា (ស្ថាប័នដឹកនាំ)<br>• ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>• ក្រសួងពាណិជ្ជកម្ម<br>• ក្រសួងឧស្សាហកម្មនិងសិប្បកម្ម<br>• ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| | | ៣. ពិនិត្យលើវិស័យដែលអាចទទួលបានឥណទានដែលមានការធានាពីគម្រោងធានាឥណទាន (កសិកម្ម ថាមពលកកើតឡើងវិញ សហគ្រាសធុនតូចនិងមធ្យមដែលជាកម្មសិទ្ធិរបស់ស្ត្រី ជាដើម) | | • ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ស្ថាប័នដឹកនាំ)<br>• ធនាគារជាតិនៃកម្ពុជា<br>• ក្រសួងឧស្សាហកម្មនិងសិប្បកម្ម<br>• ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>• ក្រសួងកិច្ចការនារី |
| | | ៤. គាំទ្រនិងជំរុញការផ្តល់ឥណទានដល់សហគមន៍អភិវឌ្ឍកសិកម្មនិងអភិវឌ្ឍជនបទ | | • ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ស្ថាប័នដឹកនាំ)<br>• ធនាគារជាតិនៃកម្ពុជា<br>• ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| សកម្មភាពគោលនយោបាយ | រយៈពេលខ្លី (២០១៩-២០២០) | រយៈពេលមធ្យម (២០២១-២០២២) | រយៈពេលវែង (២០២៣-២០២៥) | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|
| បង្កើតឲ្យមានការលើកទឹកចិត្តគេណ្ដាប្រមូលប្រាក់សន្សំ | ៥. ជំរុញនិងគាំទ្រការបង្កើតសេវាសន្សំដែលភ្ជាប់នឹងការផ្ញើប្រាក់ចូល (ជាពិសេស ការផ្ញើប្រាក់ក្នុងដែន) | | | • ធនាគារជាតិនៃកម្ពុជា (ស្ថាប័នដឹកនាំ)<br>• ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| | | ៦. ធ្វើយុទ្ធនាការផ្សព្វផ្សាយប្រព័ន្ធការពារប្រាក់បញ្ញើ | | • ធនាគារជាតិនៃកម្ពុជា (ស្ថាប័នដឹកនាំ)<br>• ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| **ខ. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** | | | | |
